# មាតាបិតុឧបដ្ឋានកថា

## សោណនន្ទជាតក ពិស្តារ



ព.ស.២៥៥៩

ការផ្សាយរបស់ពុទ្ធិកសមាគមសមណនិស្សិតកម្ពុជា-ស្រីលង្កា

# មាតាបិតុឧបដ្ឋានកថា

ប្រែរៀបរៀងដោយ

ភិក្ខុ ធម្មសិរី
វត្ត ធិតាពុទ្ធិការាម
10702 W Pecan Rd,
Tolleson, AZ, 85353 USA.

បោះពុម្ពលើកទី ១
សម្រាប់ចែកក្នុងបុណ្យកតញ្ញូកតវេទី
ចំនួន ៣០០០ ក្បាល
ព.ស.២៥៥៩

ការផ្សាយរបស់ពុទ្ធិកសមាគមសមណនិស្សិតកម្ពុជា-ស្រីលង្កា

# នាមលោកអ្នកជួយពិនិត្យ

១. ព្រះមហា វិមលពុទ្ធិ ទី ប៊ុនថា

២.ព្រះមហាធម្មបញ្ញោ ស៊ឹម សំអួន បេក្ខបណ្ឌិត ស្រីលង្កា

៣. ឧបាសិកា ម៉ម នរម

៤. ឧបាសិកា ជា សុដាលីន

៥. ឧបាសិកា វណ្ណារី ទេពប្រណម្យ

# សៀវភៅដែលខ្ញុំធ្លាប់ចេញផ្សាយ

| | |
|---|---|
| ១. សីលមយញ្ញាណកថា | ២៥៤៦ |
| ២. កង្ខាវិតរណី ភាគ ១ ភាគ ២ | ២៥៤៧ |
| ៣. សរណកថា និងប្រវត្តិពោធិព្រឹក្សស្រីលង្កា | ២៥៤៨ |
| ៤. មូលសិក្ខា មូលសិក្ខា ដីកា | ២៥៤៨ |
| ៥. ឯកសារបង្រៀនអំពីកម្មបថ ១០ | ២៥៤៨ |
| ៦. បូជនីយដ្ឋានដែនកោះលង្កា | ២៥៥៣ |
| ៧. អានុភាពត្រៃរតន៍ បទព្រហ្មគីតិ | ២៥៥៧ |
| ៨. មូលសិក្ខា-ដីកា | ២៥៥៨ |
| ៩. សក្កទេវរាជ បទកាព្យចម្រុះ | ២៥៥៨ |
| ១០. សីលានិសង្សគាថា | ២៥៥៨ |

ពុទ្ធិកសមាគមសមណនិស្សិតកម្ពុជា-ស្រីលង្កា

CAMBODIAN BUDDHIST STUDENT-MONKS' ASSOCIATION

សន្តិភាព អហិង្សា ធាតុ៤ ប្រែក្លាយជាមាស



១. ព្រះមហា **ធម្មប្បញ្ញោ** ស៊ឹម សំអូន បេក្ខភាពបណ្ឌិត

តួនាទី៖ ប្រធានពុទ្ធិកសមាគមសមណនិស្សិតកម្ពុជា-ស្រីលង្កា



២. ព្រះមហា **តបរតោ** ជៀង ស៊ីថុល បេក្ខភាពបណ្ឌិត

តួនាទី៖ ប្រធានផ្នែក រដ្ឋបាល និងហិរញ្ញវត្ថុ



៣. ព្រះមហា **សន្តិចាលោ** សំ សារ៉ូន, អនុបណ្ឌិត

តួនាទី៖ ប្រធានផ្នែកអប់រំ



៤. ព្រះមហា **ពុទ្ធមុនី** ព្រំ ឌី, អនុបណ្ឌិត

តួនាទី៖ ប្រធានផ្នែកគ្រប់គ្រងកម្មវិធី



៥. ព្រះមហា **ធម្មសិរី** សែម ចន្ទធីរ៍ អនុបណ្ឌិត

តួនាទី៖ ប្រធានគណកម្មការនិពន្ធ



៦. ព្រះមហា **ធម្មកោវិទ** ធី ចាន់ណា សមាជិក



៧. ឧបាសិកា វណ្ណារី ទេពប្រណម្យ  សមាជិកា

# សៀវភៅដែលគ្រោងបោះបន្ត
# និងបោះជាថ្មីឡើងវិញ

១. កង្ខាវិតរណី អដ្ឋកថា បាតិមោក្ខ បោះបញ្ចូលគ្នា

២. បូជនីយដ្ឋានដែនកោះលង្កា

៣. សីលានិសង្សគាថា

៤. ឯកសារបង្រៀនអំពីកម្មបថ ១០

៥. មធុរសវាហិណី

៦. កិន្នរីកក្តីស្នេហ៍ កាព្យចម្រុះ

៧. The Family Counseling Approaches

# អារម្ភកថា

ឪពុក ម្ដាយ, ពុក ម៉ែ ឬ ប៉ា ម៉ាក់ ជាពាក្យដែលកូនប្រុសស្រីរៀនមុនគេ និងចេះហៅមុនគេ ក្នុងចំណោមពាក្យដែលកូនចេញស្ដីទាំងឡាយ ។ ពាក្យថា ឪពុក ម្ដាយ ជាដើមនេះ ពេលខ្លះក៏យើងហៅតាមភាសាបាលីថា មាតាបិតាដែរ ហេតុនេះហើយ ទើបខ្ញុំឲ្យនាមសៀវភៅនេះ តាមសំនៀងបាលិភាសាយ៉ាងនេះ ។

តាមពិតទៅ មាតាបិតុឧបដ្ឋានកថា នេះ មានលោកអ្នកប្រាជ្ញចេះដឹងច្រើន បានសរសេររៀបរាប់ជាច្រើនហើយដែរ ហើយក៏សុទ្ធសឹងតែបានដកស្រង់ចេញពីព្រះពុទ្ធដីកានានាក្នុងគម្ពីរព្រះត្រៃបិដកដែរ ។ ចំណែកឯសៀវភៅនេះ ខ្ញុំគ្រាន់តែស្រង់យកមាតាបិតុឧបដ្ឋានកថាក្នុងមង្គលត្ថទីបនី របស់ព្រះមហា សួង ណែម មកជាកថាមុខតែប៉ុណ្ណោះ ព្រោះដើម្បីតម្រូវទៅតាមបុណ្យកតញ្ញូកតវេទីដែលម្ចាស់ដើមបុណ្យបំណងនឹងប្រារព្ធ រីឯអ្វីដែលរាប់រៀបពិស្ដារក្នុងសៀវភៅនេះ នុ៎ះគឺ សោណនន្ទជាតក

ដែលជារឿងរ៉ាវពិស្តារមួយ បរិយាយអំពីគុណនៃការបម្រើមាតាបិតា ។

ព្រះជាតកនេះ ខ្ញុំបានសរសេរយូរហើយដែរ តែមិនបានជាមានបំណងនឹងបោះផ្សាយដោយឡែកយ៉ាងនេះទេ តែដោយបងឧបាសិកា ជា សុជាលីន នៅលិនដៅប្រទេសអាល្លឺម៉ង់ មានបំណងនឹងធ្វើបុណ្យ កតញ្ញូកតវេទីជូនចំពោះលោកអ្នកមានគុណទាំងពីរ គឺ លោកឧបាសក **ជា សុថាវី** និងឧបាសិកា **គឹម លីម** នៅថ្ងៃអាទិត្យ ៩ កើត ខែស្រាពណ៍ ឆ្នាំមមែ សប្តស័ក ព.ស.២៥៥៩ ដែលត្រូវនឹងថ្ងៃទី ២៣ ខែសីហា ឆ្នាំ ២០១៥ នាប្រទេសកម្ពុជា ក្នុងពេលដែលគាត់ព្រមទាំងគ្រួសារចុះទៅនាពេលខាងមុខនេះ ទើបខ្ញុំព្យាយាមចាត់ធ្វើជាកូនសៀវភៅតូចនេះឡើង ដើម្បីចែកជាធម្មទាន នឹងចូលរួមបុណ្យកុសលជាមួយពួកគាត់ផង ។

តាមរយៈកូនសៀវភៅនេះ ខ្ញុំសង្ឃឹមថា ញាតិមិត្តព្រះករុណា ញោមញាតិទាំងអស់ នឹងបានដឹងអំពីគុណ

តម្លៃ និងនាមាភិធេយ្យរបស់មាតាបិតា ដែលបានប្រសិទ្ធិដោយព្រះបរមពោធិសត្វផ្ទាល់ពិតជាមិនខាន ។

រាល់ប្រយោគ ឃ្លា ភាសាបាលី និងអក្ខរាវិរុទ្ធផ្សេង ៗ ដែលមានដោយអចេតនា សូមប្រគេន និងជូនចំពោះព្រះវេយ្យាករណបណ្ឌិតទាំងឡាយ ជួយកែតម្រូវផងចុះ ។

សូមប្រសិទ្ធិពរជ័យដល់ឧបាសក ឧបាសិកា ទាំងពីររូប និងកូនចៅប្រុសស្រី ដែលដល់ព្រមដោយកតញ្ញុតាធម៌ ព្រមទាំងញាតិមិត្តទាំងអស់ក្នុងសង្សារវដ្តបានរួចចាកទុក្ខក្នុងអនាគតដ៏ខ្លីកុំបីខាន ។

សូមអនុមោទនា !!!

ថ្ងៃអង្គារ ១៤ រោច ខែបឋមាសាឍ ឆ្នាំមមែ សប្តស័ក
ព.ស. ២៥៥៩ ត្រូវនឹងថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ ២០១៥
ភិក្ខុធម្មសិរី អនុបណ្ឌិតទស្សនវិជ្ជា ព្រះពុទ្ធសាសនា

# មាតិកា

**មាតាបិតុឧបដ្ឋានកថា**........................................១
- កូនត្រូវតបគុណមាតាបិតាដោយធម៌ ៤ យ៉ាង..........២
- ព្រះសុវណ្ណសាម..................................................៥
**កត្តញ្ញុតកថា**........................................................៩
- បុគ្គលរកបានដោយកម្រក្នុងលោក......................១០
**សោណនន្ទជាតកវណ្ណនា**...................................១៩
- សេចក្តីផ្តើម និងកំណើតបណ្ឌិតទាំងពីរ...............១៩
- អ្នកទាំង ៤ ចេញសាងផ្នួស...............................២១
- សោណបណ្ឌិតបណ្តេញនន្ទបណ្ឌិតចេញ.............២៥
- នន្ទបណ្ឌិតរកវិធីសុំខមាទោសតាបសបង............២៦
- ការវាយដណ្តើមយកប្រទេសទាំង ១០១.............៣១
- នន្ទបណ្ឌិតមិនត្រូវការរាជ្យក្នុងជម្ពូទ្វីប..................៣៤
- នន្ទបណ្ឌិតនិងស្តេច១០១ ចូលព្រៃ សុំខមាទោស...៤៤
- សោណបណ្ឌិតជួបនឹងព្រះបាទមនោជ................៤៩

- នន្ទបណ្ឌិតសុំខមាទោសសោណបណ្ឌិត...............៧១
- សោណបណ្ឌិតបរិយាយគុណមាតា.....................៩៤
- ព្រះសាស្ដាទ្រង់ប្រជុំជាតក.............................១១១
**អវសានកាព្យ**..........................................១១៣
គុណពុកម៉ែ..................................................១២០
ទឹកចិត្តម្ដាយ..................................................១២១
កម្រងសន្ទនា ព្រហ្មវិហារធម៌ ៤ .......................១២៣
**កម្មវិធីកូនប្រុសស្រី**...........................................១២៨
-ស្រណោះព្រលឹងម៉ែអាសូរចិត្តម្ដាយ..................១៣១
-បទសុំខមាទោសមាតាបិតា............................១៣៣
**កម្មវិធីស្រោចស្រពសុគន្ធវារី**...............................១៣៥
-ភរិយាពណ៌នាគុណរបស់ស្វាមី........................១៣៦
-ស្វាមីវិយោគតប...............................................១៣៩
-ភរិយាខមាទោសស្វាមី.....................................១៤១
-ស្វាមីអត់ទោសឲ្យ.............................................១៤៣
នាមសប្បុរសជនចូលរួមបោះពុម្ព.......................១៤៦

# មាតាបិតុឧបដ្ឋានកថា

**មាតាបិតុឧបដ្ឋានំ** ការបម្រើនូវមាតា ១ ការបម្រើនូវបិតា ១ ជាមង្គលដ៏ឧត្តម, បទបាលីថា **មាតា នាម ជនិកា** ជាអ្នកបង្កើត ឈ្មោះថា មាតា **បិតា នាម ជនកោ** ជាអ្នកបង្កើតឈ្មោះថា បិតា ។

ព្រះដ៏មានព្រះភាគត្រាស់ក្នុងសោណនន្ទជាតកថា៖

ព្រហ្មាតិ មាតាបិតរោ
បុញ្ញាចរិយាតិ វុច្ចរេ
អាហុនេយ្យា ច បុត្តានំ
បជាយ អនុកម្បកា ។

**បណ្ឌិតហៅនូវមាតាបិតាទាំងឡាយថា ជាព្រះព្រហ្ម ដូច្នេះផង ឲ្យឈ្មោះថា បុញ្ញាចារ្យ ដូច្នេះផង ជាអ្នកអនុគ្រោះដល់ពពួកបុត្រទាំងឡាយ ជាអាហុនេយ្យបុគ្គលគួរបូជា ។**

ដូច្នេះ កូនត្រូវតបគុណមាតាបិតាដោយធម៌ ៤ យ៉ាង គឺ ៖

**១. យោ ច ខោ ភិក្ខវេ មាតាបិតរោ អស្សទ្ធេ សទ្ធាសម្បទាយ សមាទបេតិ និវេសេតិ បតិដ្ឋាបេតិ** ម្នាលភិក្ខុទាំងឡាយ បើកូនណាមួយ មាតាបិតាមិនមានសទ្ធា ត្រូវបបួលមាតាបិតាឲ្យតម្កល់ក្នុងសទ្ធាសម្បទា ។

**២. ទុស្សីលេ សីលសម្បទាយ** បើមាតាបិតាមិនមានសីល ត្រូវឲ្យមានសីលសម្បទា ។

**៣. មច្ឆរិនោ ចាគសម្បទាយ** បើមាតាបិតាមានសេចក្តីកំណាញ់ ត្រូវឲ្យមានចាគសម្បទាឡើង ។

**៤. ទុប្បញ្ញេ បញ្ញាសម្បទាយ សមាទបេតិ** បើមិនមានបញ្ញា ត្រូវបបួលមាតាបិតាឲ្យមានបញ្ញាសម្បទាឡើង ចាត់ជាមង្គលដ៏ឧត្តម ។

**នមោ ការេយ្យ សាយំ ចាតិ ឧបដ្ឋានំ គន្ត្វា** ត្រូវកូនគប្បីធ្វើនមស្សការមាតាបិតា ហើយបម្រើមាតាបិតាព្រឹកល្ងាច ។

ឥទំ មយ្ហំ ឧត្តមំ បុញ្ញក្ខេត្តំ បម្រើនេះ ជាបុញ្ញក្ខេត្ត ដ៏ឧត្តមរបស់អាត្មាអញ យាគុភត្តខាទ-នីយេន ដោយបបរ និងបាយ គឺបុគ្គលគប្បីបរិភោគ និវាសនចីវរេន ដោយសំពត់ស្លៀក និងសំពត់ដណ្តប់ សីតុណ្ហោទកេហិ ច ដោយទឹកត្រជាក់ និងទឹកក្តៅផង បាទធោវនេន ចេវ ដោយកិរិយាលាងនូវជើងផង តេលមក្ខនេន ច ដោយកិរិយាលាបនូវប្រេងផង នេះជាវត្តប្រតិបត្តិរបស់កូនប្រុសស្រី ចាត់ថាជាមង្គលដ៏ឧត្តម, បើបព្វជិតវិញ បទបាលីថា បិតា បន យថា សាមណេរោ ឯវំ សហត្ថេន នហាបន-សម្ពាហនាទីនិ កាតព្វា ឧបដ្ឋាតព្វោ ចំណែកបិតាសាមណេរ គប្បីបម្រើដោយដៃ មានធ្វើនូវកិច្ចទាំងឡាយមានផ្ងូតទឹក និងគក់ប្របាច់នូវជើងជាដើម ភិក្ខុក៏យ៉ាងនោះដែរ បើមាតា ភិក្ខុ អាមសតោបិ ទុក្កដំ ត្រូវអាបត្តិទុក្កដ ព្រោះចាប់ពាល់ តេន កាយសំ-

**សគ្គវណ្ណនាយំ** ព្រោះហេតុនោះ អដ្ឋកថាពោលថា ជាប់ដោយកាយសំសគ្គ **សចេ នទីសោតេន វុយ្ហមានំ មាតរំ បស្សតិ** បើភិក្ខុឃើញមាតា អណ្តែតក្នុងទឹកស្ទឹង **នេវ ហត្ថេន បរាមសិតព្វា** មិនគប្បីពាល់ត្រូវដោយដៃទេ ត្រូវរកទូកក្តី ផែនក្តារក្តី បើមិនមានទេ ត្រូវភិក្ខុឲ្យសំពត់កាសាវៈទៅមាតា **កឌ្ឍិតព្វំ** គឺភិក្ខុគប្បីទាញមក បើមាតាខ្លាច ភិក្ខុគប្បីលួងលោម បើមាតាចាស់ជាប់កក់ **យោត្តំ វា វត្ថំ វា** ភិក្ខុត្រូវរកខ្សែក្តី សំពត់ក្តីឲ្យមាតាកាន់ទាញមាតាមក នេះជាវត្តដ៏សមគួរតាមសិក្ខាបទ ។

**អយំ បុគ្គលោ មេត្តេយ្យោ បេត្តេយ្យ សគ្គវត្តនិយំ បដិបទំ បូរេតិ** បើបុគ្គលនេះ បំពេញនូវបដិបទា មានប្រយោជន៍ដល់មាតា មានប្រយោជន៍ដល់បិតា មនុស្សក្នុងលោកតែងសរសើរថា ជាមនុស្សប្រព្រឹត្តដើម្បីបានសួគ៌ ។

## ព្រះសុវណ្ណសាម

ព្រះពោធិសត្វទ្រង់សម្ដែងនូវព្រះគាថា ២ ថ្វាយស្ដេចពារាណសី ៖ [១]

យោ មាតរំ បិតរំ វា
មច្ចោ ធម្មេន បោសតិ
ទេវាបិ នំ តិកិច្ឆន្តិ
មាតាបេតិភរំ នរំ ។

នរជនណាចិញ្ចឹមនូវមាតាក្ដី បិតាក្ដីតាមធម៌ សូម្បីទេវតាតែងរក្សានូវនរជននោះ ដែលចិញ្ចឹមនូវមាតាបិតា ។

យោ មាតរំ បិតរំ វា
មច្ចោ ធម្មេន បោសតិ
ឥធេវ នំ បសំសន្តិ
បេច្ច សគ្គេ បមោទតិ

សត្វឯណាចិញ្ចឹមនូវមាតាក្ដី បិតាក្ដីតាមធម៌ បណ្ឌិត

---

[១] សុត្តន្ត. ខុ.និ. ជាតក ភាគ ៦២ ទំព័រ ៦៥

**លោកសរសើរនូវសត្វនោះក្នុងលោកនេះ ទៅកាន់លោក ខាងមុខតែងរីករាយក្នុងឋានសួគ៌ ។**

**បពិត្រមហារាជបុគ្គលប្រព្រឹត្តធម៌ ១០ យ៉ាង**

១. ធម្មំ ចរ មហារាជ មាតាបិតូសុ ខត្តិយ ឥធ ធម្មំ ចរិត្វាន រាជ សគ្គំ គមិស្សសិ មហារាជ ព្រះអង្គជាក្សត្រ ព្រះអង្គចូរប្រព្រឹត្តនូវធម៌ ចំពោះមាតាបិតា លុះប្រព្រឹត្តនូវធម៌ ក្នុងលោកនេះ ព្រះអង្គនឹងបានយាងទៅកាន់សួគ៌ ។

២. ធម្មំ ចរ មហារាជ បុត្តទារេសុ ខត្តិយ បពិត្រមហារាជ ព្រះអង្គជាក្សត្រ ចូរប្រព្រឹត្តនូវធម៌ ចំពោះបុត្រា និងមហេសី ។

៣. ធម្មំ ចរ មហារាជ មិត្តាមច្ចេសុ ខត្តិយ មហារាជ ព្រះអង្គជាក្សត្រ ចូរទ្រង់នូវធម៌ចំពោះពួកមិត្តនិងអាមាត្យ

៤. ធម្មំ ចរ មហារាជ វាហនេសុ ពលេសុ ច មហារាជចូរទ្រង់នូវធម៌ចំពោះសត្វពាហនៈនិងពួកពល។

៥. ធម្មំ ចរ មហារាជ គាមេសុ និគមេសុ ច បពិត្រមហារាជ ចូរព្រះអង្គប្រព្រឹត្តនូវធម៌ ចំពោះស្រុក និងនិគម

៦. ធម្មំ ចរ មហារាជ រដ្ឋេសុ ជនបទេសុ ច មហារាជ ព្រះអង្គចូរប្រព្រឹត្តធម៌ចំពោះអ្នកដែននិងជនបទ

៧. ធម្មំ ចរ មហារាជ សមណព្រាហ្មណេសុ ច ព្រះមហាក្សត្រ ចូរប្រព្រឹត្តធម៌ ចំពោះសមណៈផង ព្រាហ្មណ៍ផង

៨. ធម្មំ ចរ មហារាជ មិគបក្ខីសុ ខត្តិយ មហារាជ ចូរទ្រង់នូវធម៌ចំពោះសត្វម្រឹគ និងសត្វស្លាបទាំងឡាយ

៩. ធម្មញ្ចរ មហារាជ ធម្មោ ចិណ្ណោ សុខាវហោ ឥធ ធម្មំ ចរិត្វាន រាជ សគ្គំ គមិស្សសិ មហារាជ សូមទ្រង់ប្រព្រឹត្តនូវធម៌ ធម៌ដែលប្រព្រឹត្តល្អហើយ តែងនាំមកនូវសុខ លុះប្រព្រឹត្តធម៌ក្នុងលោកនេះហើយ មហារាជនឹងបានយាងទៅកាន់ឋានសួគ៌ ។

១០. ធម្មំ ចរ មហារាជ ឥន្ទា ទេវា សព្រហ្មកា សុចិណ្ណេន ទិវំ បត្តា មា ធម្មំ រាជ បាមទោតិ មហារាជ សូមទ្រង់ប្រព្រឹត្តនូវធម៌ ព្រោះទេវតា ឥន្ទ ព្រហ្មដែលបានដល់នូវឋានសួគ៌ ក៏ព្រោះធម៌ ដែលខ្លួនប្រព្រឹត្តល្អហើយ បពិត្រព្រះរាជា ព្រះអង្គកុំប្រហែសធ្វេសនឹងធម៌ឡើយ។

**មហារាជចូរកុំប្រមាទនូវធម៌ទាំង ១០ នេះ**

ស្តេចពារាណសីស្តាប់ធម៌ព្រះពោធិសត្វចប់ពេលណា ក៏មានព្រះទ័យជ្រះថ្លាទ្រង់កាន់យកបញ្ចសីល ថ្វាយ

បង្គំយាងទៅកាន់នគររបស់ព្រះអង្គ ធ្វើនូវបុណ្យមានទាន ជាដើម រក្សាសីល ៥ លះបង់សម្បត្តិតាមធម៌ អស់ព្រះជន្ម ទៅកើតឋានសួគ៌ ចំណែកព្រះពោធិសត្វញុំាងឈាន និង អភិញ្ញាជាមួយនឹងមាតាបិតាឲ្យកើតឡើង ទៅកើតព្រហ្ម លោកទាំងអស់គ្នា ស្ដេចបានមកជាព្រះអានន្ទ ។

**រាជធម៌ ១០ យ៉ាង**

១. ទានំ ទ្រង់លះបង់ទេយ្យវត្ថុព្រះរាជទាន

២. សីលំ ទ្រង់រក្សាសីល ៥ និងសីល ១០

៣. បរិច្ចាគំ ទ្រង់លះបង់ទេយ្យធម៌បរិច្ចាគ

៤. អាជ្ជវំ ទ្រង់តាំងព្រះទ័យឲ្យត្រង់ក្នុងសាសនា

៥. មទ្ទវំ ភាពមានព្រះទ័យទន់ភ្លន់

៦. តបំ ទ្រង់ធ្វើឧបោសថ

៧. អក្កោធំ ទ្រង់មានព្រះទ័យមេត្តាទូទៅក្នុង ព្រះរាជអាណាចក្រ

៨. អវិហឹសា ទ្រង់មានព្រះទ័យដោះទុក្ខគេឲ្យរួច

៩. ខន្តី ទ្រង់មានព្រះទ័យអត់សង្កត់

១០. អវិរោធនំ ទ្រង់មានព្រះទ័យមិនពិរោធហួស ប្រមាណ ។

# កតញ្ញុតាកថា

ដោយបាលីថា **កតញ្ញុតា** ភាវៈនៃបុគ្គលអ្នកដឹងនូវឧបការៈដែលអ្នកដទៃធ្វើដល់ខ្លួន ជាមង្គលដ៏ឧត្តម, ដោយបាលី **កតញ្ញុតា នាម អប្បស្ស វា ពហុស្ស វា យេន កេនចិ កតស្ស ឧបការស្ស បុនប្បុនំ អនុស្សរណភាវេន ជាននតា** ភាវៈនៃបុគ្គលអ្នកដឹងនូវឧបការៈ មានប្រមាណតិចតួចក្ដី ច្រើនក្ដី គឺបុគ្គលណាមួយធ្វើហើយ ដោយភាវៈនៃកិរិយារឭករឿយ ៗ ដល់ឧបការគុណដែលគេបានធ្វើ ដល់ខ្លួន មានឧបការៈច្រើនក្ដី តិចក្ដី ឈ្មោះថា **កតញ្ញូ** ។

**អបិច នេរយិកាទិទុក្ខបរិត្តាណតោ បុញ្ញានិ ឯវ បាណីនំ ពហូបការានិយតោ តេសម្បិ ឧបការានុស្សរណតា កតញ្ញុតាតិ វេទិតព្វា** ម្យ៉ាងវិញទៀតថា បុគ្គលមានបុណ្យច្រើន

ធ្វើនូវឧបការៈច្រើន ដល់សត្វទាំងឡាយ ព្រោះកិរិយាការពារនូវទុក្ខមានទុក្ខក្នុងនរកជាដើម ព្រោះភាវៈនៃកិរិយារឭកឃើញនូវឧបការៈនៃជនទាំងឡាយនោះ ដោយបញ្ញាឯណា បញ្ញានោះ គឺបណ្ឌិតគប្បីដឹងថា **កតញ្ញូ** ។

**ទ្វេមេ ភិក្ខវេ បុគ្គលា ទុល្លភា លោកស្មឹ** ម្នាលភិក្ខុទាំងឡាយ បុគ្គលមានពីរពួកក្នុងលោកនេះ គេរកបានដោយកម្រណាស់ គឺ **បុព្វការីបុគ្គល ១ កតញ្ញូកតវេទីបុគ្គល ១ បុព្វការី** សំដៅយកមាតាបិតា ។

**សម្មាបដិបន្នោ** ដែលកូនប្រុសស្រី ត្រូវប្រតិបត្តិដោយប្រពៃ ចំពោះមាតាបិតារបស់ខ្លួន, ពាក្យថា **បុព្វការី** គឺ **បុព្វការីតិ បឋមំ ឧបការស្ស ការកោ** ជាអ្នកធ្វើឧបការៈមុនគេ ឲ្យឈ្មោះថា **បុព្វការី ។ កតវេទីតិ កតំ វេទេតិ វិទិតំ ចាកដំ** ពាក្យថា ដឹងគុណ គឺបុគ្គលដឹង ច្បាស់នូវគុណ

ដែលគេធ្វើហើយ តែងធ្វើឲ្យដឹងច្បាស់ប្រាកដ ឈ្មោះថា **កតវេទីបុគ្គល** ។

បុព្វការី មាន ៤ ពួកទៀត គឺៈ

**បព្វជ្ជាចរិយា ១ ឧទ្ទេសាចរិយា ១ ឧបសម្បទាចរិយា ១ និស្សយាចរិយា ១** ។

បទបាលីថា **បុត្តធីតរោ បន មាតាបិតរោ បដិជគ្គន្តា អភិវាទនាទីនិ តេសំ ករោន្តា កតវេទិនោ នាម** ចំណែកកូនប្រុសស្រីទាំងឡាយ កាលទំនុកបម្រុងមាតានិងបិតា ត្រូវធ្វើកិច្ចទាំងឡាយ មានការក្រាបសំពះជាដើម ដល់មាតាបិតាទាំងឡាយនោះ ឈ្មោះថា **កតវេទីបុគ្គល** ។

ចំណែកអន្តេវាសិក សទ្ធិវិហារិក ត្រូវធ្វើវត្តប្រតិបត្តិ ដូចគ្នាខ្លះ ខុសគ្នាខ្លះ ប៉ុន្តែចំណែក **បុព្វការី** គឺមាតាបិតាក្តី អាចារ្យ និងឧបជ្ឈាយ៍ក្តី មិនត្រូវសម្លឹងយកឧបការៈ ដែលគេមិនបានធ្វើតបវិញនោះទេ ។

**សោ ទុល្លភោ សត្តានំ តណ្ហាភិភូតត្តា**
បុគ្គលនោះ គឺគេរកបានដោយក្រ ព្រោះភាវៈនៃសត្វទាំងឡាយ គឺតណ្ហាគ្របសង្កត់ហើយ ។

បុគ្គលប្រព្រឹត្តដ៏សមគួរនូវឧបការៈ ដែលអ្នកដទៃធ្វើហើយ កាលដឹងច្បាស់នូវឧបការៈដែលគេធ្វើចំពោះខ្លួនត្រូវធ្វើតបវិញ ឈ្មោះថា **កតញ្ញូកតវេទី** គឺត្រូវប្រតិបត្តិដោយប្រពៃ ចំពោះមាតាបិតា អាចារ្យនិងឧបជ្ឈាយ៍ ។

**សោបិ ទុល្លភោ សត្តានំ អវិជ្ជាភិភូតត្តា**
ចំណែកបុគ្គលនោះឯង គឺគេរកបានដោយក្រ ព្រោះភាវៈនៃសត្វទាំងឡាយ គឺអវិជ្ជាគ្របសង្កត់ហើយ ។

ពាក្យថាឧបជ្ឈាយ៍គឺ **វជ្ជាវជ្ជំ ឧបនិជ្ឈាយតីតិ ឧបជ្ឈាយោតិ អាហ វជ្ជាវជ្ជំ និស្វា ចោទេតា សារេតា ចាតិ** បុគ្គលឯណា ចូលទៅជិតសម្លឹងយកនូវទោស និងមិនមែនទោស ព្រោះហេតុដូច្នោះ បុគ្គលនោះឈ្មោះថា ឧបជ្ឈាយ៍ ព្រោះថាឃើញនូវទោសនិងមិនមែនទោស ពោលដាស់តឿនផង ក្រើនរំឭកផង គឺ **វជ្ជាវជ្ជន្តិ**

**ខុទ្ទកំ មហន្តញ្ច វជ្ជន្តិ** ព្រោះថាឃើញទោសតូចផង ធំផង ឈ្មោះថា **វជ្ជាវជ្ជំ** ពាក្យថាដាស់តឿន គឺ **ចោទេតាតិ ឥទំ តយា ទុក្កដំ ឥទំ ទុព្ភាសិតន្តិ អាទីនិ វត្វា ចោទេតា** បុគ្គលពោលដាស់តឿននូវពាក្យទាំងឡាយ មានពាក្យថាដូច្នេះជាដើម អំពើនេះ គឺអ្នកធ្វើហើយ ត្រូវអាបត្តិទុក្កដ អំពើនេះ គឺអ្នកធ្វើហើយត្រូវអាបត្តិទុព្ភាសិត មានអាបត្តិបារាជិក និងសង្ឃាទិសេសជាដើម ឈ្មោះថា **ចោទេតា** គឺពោលដាស់តឿន ។

ពាក្យថា ពោលរំឭកគឺ **សារេតាតិ អត្តនោ វជ្ជំ អសរន្តស្ស សតឹ ឧប្បាទេតា សម្មាបដិបត្តិយំ វា សារេតា បវត្តេតាតិ អត្ថោ** សេចក្ដីថា បុគ្គលណាមួយ កាលញុំាងសតិរបស់បុគ្គលដែលគេមិនទាន់រឭកឃើញ នូវទោសរបស់ខ្លួនឲ្យកើតឡើង ឬមួយញុំាងបុគ្គលឲ្យរឭកប្រក្រតី ប្រព្រឹត្តទៅក្នុងសេចក្ដីប្រតិបត្តិ

ដោយប្រពៃឲ្យឈ្មោះថា **សារេតា** គឺពោលរំឭកដាស់តឿន ។

ពាក្យថា អាចារ្យ បាលីថា

**ឯវំ តយា ពុទ្ធវចនំ សជ្ឈាយិតព្វំ ឯវំ អភិក្កមិតព្វំ ឯវំ បដិក្កមិតព្វន្តិអាទិនា-អាចារស្ស សិក្ខាបនតោ អាចរិយោ នាមាតិ អាហ ឥមស្មឹ សាសនេ សិក្ខិតព្វកាជម្មេសុ បតិដ្ឋាបេតាតិ** បុគ្គលណាមួយ ញុំាងគេឲ្យសិក្សានូវមារយាទ ដោយន័យមានពាក្យថាដូច្នេះជាដើម ពុទ្ធវចនៈ គឺអ្នកគប្បីស្វាធ្យាយយ៉ាងនេះ គឺអ្នកគប្បីឈានចូលយ៉ាងនេះ អ្នកគប្បីឈានថយយ៉ាងនេះ ឲ្យឈ្មោះថា អាចារ្យ ព្រោះហេតុដូច្នោះ ទើបលោកពោលថា ញុំាងបុគ្គលឲ្យគង់នៅចំពោះក្នុងធម៌ទាំងឡាយ គឺបុគ្គលគប្បីសិក្សាក្នុងសាសនានេះ។

**បព្វជ្ជាចារ្យ** គឺអ្នកឲ្យនូវសិក្ខាបទ(បំបួសឲ្យបានសាមណេរ) **ឧបសម្បទាចារ្យ** គឺកម្មវាចាជាហេតុ

ញុំាងបុគ្គលឲ្យដល់នូវភារៈនាំខ្លួនខាងលើ គឺឧបសម្បទា (សូធ្យកម្មវាចាឲ្យឡើងជាភិក្ខុ) ។

**ឧទ្ទេសាចារ្យ** គឺអ្នកសម្ដែងប្រាប់នូវបាលី និងអដ្ឋកថា ឲ្យឈ្មោះថា ធម្មាចារ្យ ។

ក្នុងបញ្ចមបណ្ណាសកៈ ទុតិយវគ្គ សម្ដែងថា **អបិច កាតញ្ញុស្ស សម្បរាយោ សុគតិ អកាតញ្ញុស្ស ទុគ្គតិ** ន័យមួយវិញទៀត បុគ្គលជាកតញ្ញូមានសុគតិប្រព្រឹត្តទៅខាងមុខ បុគ្គលអកតញ្ញូមានទុគ្គតិប្រព្រឹត្តទៅខាងមុខ ។

**បុគ្គលមកអំពីងងឹត ទៅងងឹតទៀត** ព្រោះបាលីថា **នីចកុលបច្ចាជាតិអាទិកេន តមេន យុត្តោ តមោ** បុគ្គលណា ប្រកបដោយងងឹត មានកិរិយាកើតក្នុងកាលជាក្រោយ មានត្រកូលថោកទាបជាដើម ព្រោះហេតុដូច្នោះ បុគ្គលនោះ ឈ្មោះថា **តមៈ** គឺមកអំពីងងឹត, ជាបទបាលីថា **កាយទុច្ចរិតាទីហិ បុន និរយត-ម្ហូបគមនតោ តមបរាយនោ** បុគ្គលមានងងឹត

ប្រព្រឹត្តទៅខាងមុខ ព្រោះហេតុនៃកិរិយាចូលទៅជិតកាន់នរកម្តងទៀត ព្រោះទុច្ចរិតទាំងឡាយ មានកាយទុច្ចរិតជាដើម ឈ្មោះថា ទៅងងឹតនោះទៀត ។

**បុគ្គលមកភ្លឺ ទៅភ្លឺទៀត** បាលីថា **អឌ្ឍកុលបច្ចាជាតិអាទិកោន ជោតិនា យុត្តោ ជោតិ អាលោកភូតោតិ វុត្តំ ហោតិ** បុគ្គលឯណា មានពន្លឺកើតហើយប្រកបដោយជាតិមានត្រកូលស្តុកស្តម្ភ ក្នុងកាលជាខាងក្រោយជាដើម ឈ្មោះថា **ជោតិ** មានពន្លឺទៅខាងមុខទៀត ។ បាលីថា **កាយសុចរិតាទីហិ បុន សគ្គូបបត្តិ ជោតិ-ភាវូបគមនតោ ជោតិបរាយនោ** បុគ្គលឯណា មានពន្លឺប្រព្រឹត្តទៅខាងមុខ ព្រោះហេតុនៃកិរិយាចូលទៅជិតដល់នូវភាវៈកើតក្នុងឋានសួគ៌ម្តងទៀត ដោយសុចរិតទាំងឡាយមានកាយសុចរិតជាដើម ឈ្មោះថា **ជោតិបរាយនោ** គឺបាលីពោលថា **បុញ្ញផលំ ឧបជីវន្តោ** ព្រោះកាលរស់នៅដោយផលបុណ្យ ជាពួកបក្សខាងកតញ្ញូ ។

**ទ្វេមេ ភិក្ខវេ បុគ្គលា ទុល្លភា លោកស្មឹ**
ម្នាលភិក្ខុទាំងឡាយ បុគ្គលពីរពួក រកបានដោយកម្រក្នុងលោក គឺបុព្វការី ១ កតញ្ញូកតវេទី ១ ។

**បុព្វការី** អ្នកឲ្យនូវបំណុល មាតាបិតាជាបុព្វការី បុត្តធីតាជា **កាតវេទី** សងបំណុល ។ ឧបជ្ឈាយាចារ្យជាបុព្វការី អន្តេវាសិកសទ្ធិវិហារិក ជាកតវេទី ។

**តមោ ជោតិបរាយណោ** មានងងឹតនិងភ្លឺនៅខាងដើម ជាបុព្វការី **ជោតិ ជោតិបរាយណោ** មានពន្លឺភ្លឺទៅខាងមុខ ជាកតញ្ញូកតវេទី, អ្នកបង្ហាញផ្លូវជាបុព្វការី អ្នកបដិបត្តិជាកតញ្ញូកតវេទី ព្រះសម្មាសម្ពុទ្ធជាបុព្វការី អរិយសាវ័កជាកតញ្ញូកតវេទី ។

**នីចកុលបច្ចាជាតិ** បុគ្គលមានកាយទុច្ចរិតជាដើម តែងទៅកើតក្នុងត្រកូលថោកទាប មាននរកជាដើម ហៅថា **តមោ តមបរាយណោ** ។ **អឌ្ឍកុលបច្ចាជាតិ** អ្នកមានកាយសុចរិតជាដើម

តែងទៅកើតក្នុងត្រកូលខ្ពង់ខ្ពស់មានសុគតិជាដើម ហៅថា **ជោតិបរាយណោ** ។

**តមោជោតិបរាយណោ** មកងងឹតត្រឡប់ទៅភ្លឺវិញ គឺចូលទៅកាន់យកបុញ្ញផល ។

**ឯវំ កាតញ្ញូ បុគ្គលោ ទុល្លភោ ហោតិ** បុគ្គលអ្នកដឹងគុណរកបានដោយកម្រយ៉ាងនេះ **អកាត-ញ្ញុនោ ហិ ពហូ ហោន្តុ** សេចក្តីពិតថាអ្នកមិនដឹងគុណមានច្រើនណាស់ ។ **តត្ថ កាតញ្ញុ ឥធ បសំសានិហិតំ ចាបុណាតិ អកាតញ្ញូ ឥធ និន្ទានិហិតំ** បុគ្គលទាំងពីរពួកនេះ អ្នកដឹងគុណតែងបាននូវសេចក្តីសរសើរ នាំមកនូវប្រយោជន៍ និងសេចក្តីសុខក្នុងលោកនេះ បុគ្គលអ្នកមិនដឹងគុណតែងនាំមកនូវពាក្យនិន្ទា មិនមានប្រយោជន៍ និងមិនមានសេចក្តីសុខ ក្នុងលោកនេះ ។

តទៅ គឺព្រះជាតកសម្តែងអំពីការទំនុកបម្រុងមាតាបិតា ដែលមានសេចក្តីពិស្តារះ

# សោណនន្ទជាតកវណ្ណនា[២]

## សេចក្ដីផ្ដើម និងកំណើតបណ្ឌិតទាំងពីរ

ព្រះសាស្ដាកាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុចិញ្ចឹមម្ដាយមួយអង្គ ទើបទ្រង់ត្រាស់សម្ដែងនូវព្រះជាតកនេះ ដែលមានពាក្យជាដើមថា **ទេវតា នុសិ គន្ធព្វោ** ដូច្នេះ។ រឿង(ភិក្ខុចិញ្ចឹមម្ដាយនេះ)មានដំណើរសេចក្ដីដូចដែលបានសម្ដែងក្នុងសាមជាតក[៣] រួចហើយ។

មានសេចក្ដីតំណាលថា ក្នុងគ្រានោះ ព្រះបរមគ្រូទ្រង់ប្រដៅពួកភិក្ខុសង្ឃថា "ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ កុំតិះដៀលភិក្ខុអង្គនេះឡើយ, បោរាណកបណ្ឌិតទាំងឡាយ សូម្បីបានហើយនូវរាជសម្បត្តិក្នុងជម្ពូទ្វីបទាំងមូលក៏មិនកាន់យកនូវរាជសម្បត្តិនោះឡើយ សុខចិត្តនៅចិញ្ចឹមមាតាបិតាវិញដែរ" ទើបទ្រង់នាំអតីតនិទានមកតំណាលថា៖

---

[២] សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក ភាគ ៦១ ទំព័រ ៨១

[៣] សុវណ្ណសាមជាតក សុត្តន្ត. ខុ.និ. ជាតក ភាគ ៦២ ទំព័រ ៤៩

**អតីតេ ពារាណសី** ក្នុងកាលដ៏កន្លងទៅហើយ ទីក្រុងពារាណសីបានជានគរមានឈ្មោះថា ព្រហ្មវឌ្ឍន៍ ។ ព្រះរាជាព្រះនាម មនោជ បានសោយរាជ្យក្នុងនគរនោះ ។ ក្នុងនគរនោះដែរ មានត្រកូលព្រាហ្មណមហាសាលមួយ មានទ្រព្យ ៨០ កោដិ ជាត្រកូលមិនមានបុត្រស្នងសោះ ។ នាងព្រាហ្មណីនៃត្រកូលនោះត្រូវព្រាហ្មណ៍ជាស្វាមីបង្គាប់ថា នែ៎នាង នាងចូរប្រាថ្នានូវបុត្រ ដូច្នេះ នាងក៏ប្រាថ្នាតាមទៅ ។ គ្រានោះ ព្រះពោធិសត្វបានច្យុតចាកព្រហ្មលោក មកកាន់យកបដិសន្ធិក្នុងផ្ទៃនៃនាងព្រាហ្មណីនោះ, កាលព្រះពោធិសត្វប្រសូតហើយ មាតាបិតាក៏បានដាក់នាមថា សោណកុមារ ដូច្នេះ ។ កាលដែលសោណកុមារនោះចេះដើរហើយ មានសត្វសូម្បីដទៃទៀតក៏បានច្យុតចាកព្រហ្មលោក មកចាប់កំណើតក្នុងផ្ទៃនៃនាងព្រាហ្មណីនោះឯងមួយនាក់ទៀត, មាតាបិតាក៏បានដាក់នាមទារកដែលកើតហើយនោះថា នន្ទកុមារ ដូច្នេះ ។ ព្រាហ្មណ៍ជាស្វាមីកាលបានពិនិត្យឃើញនូវរូបសម្បត្តិនៃបុត្រទាំងពីរនោះ ដែល

ពេញវ័យហើយ មានត្រៃវេទរៀនចប់ហើយ ដល់នូវជំនាញក្នុងសិល្បៈចិញ្ចឹមជីវិតគ្រប់យ៉ាងហើយ ក៏ប្រឹក្សាជាមួយនាងព្រាហ្មណីជាភរិយាថា នែ៎នាងដ៏ចម្រើន យើងនឹងចងនូវកូនសោណកុមារដោយចំណងផ្ទះឲ្យបាន ដូច្នេះ ។ នាងព្រាហ្មណីជាភរិយាបានទទួលថា សាធុ ល្អណាស់ ហើយក៏ប្រាប់សេចក្ដីនោះដល់កូន ។ សោណកុមារតបទៅម្ដាយថា បពិត្រអ្នកមេ ការរស់នៅជាឃរាវាសរបស់ពួកខ្ញុំប៉ុណ្ណឹងគ្រប់គ្រាន់ហើយ កូននឹងបម្រើលោកទាំងពីរដរាបដល់អស់ជីវិត អំណើះអំពីលោកទាំងពីរទៅ កូននឹងចូលទៅកាន់ព្រៃហេមពាន្តបួសហើយ ។ នាងព្រាហ្មណីនោះ ក៏បានជម្រាបសេចក្ដីនុ៎ះដល់ព្រាហ្មណ៍ជាស្វាមីវិញ។

## អ្នកទាំង ៤ ចេញសាងផ្នួស

សូម្បីមាតាបិតានោះ ឃាត់អង្វរជាច្រើនដងយ៉ាងណាក៏ដោយ ក៏មិនអាចបង្វែរចិត្តរបស់សោណកុមារបានឡើយ ក៏ប្រឹក្សានឹងនន្ទកុមារថា នែ៎បា!បើដូច្នោះបាឯង ចូរគ្រប់គ្រងនូវទ្រព្យសម្បត្តិចុះ នន្ទកុមារក៏ប្រកែកថា ខ្ញុំមិន

ឱនក្បាលលិទ្ធទឹកមាត់ ដែលបងប្រុសខ្ជាក់ចោលជាដាច់ខាត តែអំណឹះអំពីលោកទាំងពីរទៅ ខ្ញុំក៏នឹងទៅបួសជាមួយបងប្រុសមិនខានឡើយ ។ មាតាបិតាកាលបើបានស្តាប់សម្តីនៃកូនប្រុសទាំងពីរច្បាស់ហើយ ក៏គិតថា បុត្រទាំងពីរនេះនៅក្មេងកម្លោះស្រស់ត្រកាលយ៉ាងនេះគង់លះបង់នូវកាមទាំងឡាយបាន ចុះនឹងបាច់ពោលទៅថ្វីដល់ពួកយើង ពួកយើងនឹងបួសទាំងអស់គ្នាតែម្តងទៅចុះ លុះគិតដូច្នោះហើយ ក៏ហៅកូនមកប្រាប់ថា ហៃបាទាំងឡាយពួកបាមិនចាំបាច់អស់ពីពួកយើងទៅ សឹមបួសនោះទេ ពួកយើងនឹងបួសទាំងអស់គ្នាឥឡូវនេះតែម្តង មិនល្អទេឬ រួចក៏ក្រាបទូលដំណឹងដល់ព្រះរាជាហើយ លះនូវទ្រព្យធនទាំងអស់ឲ្យទៅជាទាន ដោះអ្នកបម្រើឲ្យទៅជាអ្នកជាវិញ (និង) ឲ្យទ្រព្យដែលគួរតែឲ្យដល់ពួកញាតិទាំងឡាយស្រេចបាច់ហើយ ពួកជនទាំងបួននាក់ ដើរចេញពីព្រហ្មវឌ្ឍននគរទៅអាស្រ័យនូវស្រះដ៏ដេរដាស ដោយឈូកមានពណ៌ប្រាំទៀបហិមវន្តប្រទេស ក្បែរដងព្រៃដ៏គួរជាទី

វិករាយ បានសាងអាស្រមហើយបួសសម្នាក់ នៅទីនោះទៅ ។ បងប្អូនប្រុសទាំងពីរនាក់បានទំនុកបម្រុងមាតាបិតាដោយប្រការយ៉ាងនេះគឺៈ ពេលព្រឹករៀបចំជូននូវឈើជម្រះធ្មេញ [៤] និងទឹកសម្រាប់លុបមុខដល់លោកទាំងពីរ បោសសម្អាតនូវបណ្ណសាលាផង បរិវេណជុំវិញផង ទៅដងទឹកសម្រាប់ប្រើប្រាស់ និងទឹកសម្រាប់បរិភោគមកតំកល់ទុកជាស្រេច រួចហើយទើបយកផ្លែឈើទុំខ្ចីដ៏មានឱជារសផ្អែមឈ្ងុយឆ្ងាញ់ទាំងឡាយ មកអំពីព្រៃជូនមាតាបិតាពិសា, ផ្ងូតលោកទាំងពីរដោយទឹកក្ដៅ ទឹកត្រជាក់ សម្អាតផ្ទះងសក់(និង)កាតព្វកិច្ចទាំងឡាយ ដែលគួរធ្វើដល់លោកផ្សេងទៀតមានទាំងលាងជើងលោកទាំងពីរជាដើម ។

ការទំនុកបម្រុងដោយប្រការយ៉ាងនេះកន្លងទៅអស់កាលដ៏យូរ (ថ្ងៃមួយ) នៅតាមផ្លូវកំពុងស្វែងរកផ្លែឈើ

[៤] សម័យបច្ចុប្បន្ន បានដល់ ច្រាស និងថ្នាំដុសធ្មេញ

នន្ទបណ្ឌិតក៏គិតថា អាត្មាអញនឹងជូនមាតាបិតាឲ្យលោក
ពិសានូវផលាផលដែលអញបានបេះមកហើយឲ្យបានមុន
ដូច្នេះ ក៏ស្រូតទៅមុនបងហើយយកផ្លែឈើផ្សេង ៗ ដែល
ខ្លួនបានបេះយកមកតាំងពីម្សិលមិញ ឬម្សិលម៉្ងៃ នាំមកពី
ព្រឹកបង្អោនជូនមាតាបិតាពិសា ។ លោកទាំងពីរបរិភោគ
ផ្លែឈើទាំងនោះហើយក៏ខ្ចុរមាត់រក្សាឧបោសថ។ ចំណែក
សោណបណ្ឌិតទៅកាន់ទីឆ្ងាយ បេះយកផ្លែឈើទុំក្រហម
ផ្ទៅល្អ ៗ មានរសផ្អែមឈ្ងុយឆ្ងាញ់ដូចទឹកឃ្មុំ បង្អោនចូល
មកជូនលោកពិសា ។ គ្រានោះ មាតាបិតាពោលទៅកាន់
គាត់ថា នែបា! ពួកយើងបានបរិភោគផលាផលដែលប្អូន
ឯងយកមកតាំងពីព្រឹករួចទៅហើយ ពួកយើងជាអ្នករក្សា
ឧបោសថ ពេលនេះមិនត្រូវការរបស់បាទៀតទេ ។ ផលា-
ផលទាំងឡាយរបស់សោណបណ្ឌិតនោះ ដោយមិនត្រូវ
បរិភោគក៏ស្អុយអស់ទៅដោយប្រការយ៉ាងនេះ សូម្បីថ្ងៃ
ស្អែកឡើង នន្ទបណ្ឌិតក៏នៅតែធ្វើយ៉ាងនោះដដែល ។
សោណបណ្ឌិតជាបងនោះ ក៏នៅតែនិមន្តទៅទីឆ្ងាយដូច

គ្នា ព្រោះលោកបានសម្រេចហើយនូវអភិញ្ញាប្រាំហោះទៅបេះយកមក តែពួកលោកទាំងពីរមិនបរិភោគ ។

## សោណបណ្ឌិតបណ្ដេញនន្ទបណ្ឌិតចេញ

គ្រានោះ ព្រះមហាសត្វគិតថា មាតាបិតារបស់អាត្មាអញជាសុខុមាលជាតិ ប្អូននន្ទ តែងតែនាំយកផលាផលផ្សេង ៗ ពីនេះពីនោះ ដែលមិនទាន់ទុំល្អមកជូនលោកពិសា កាលបើយ៉ាងនេះ ពួកគាត់នេះ នឹងមិនមាំទាំបានយូរអង្វែងឡើយ អញត្រូវតែឃាត់ប្អូននន្ទ ។ គ្រានោះតាបសបងក៏ហៅតាបសប្អូនមកប្រាប់ថា នៃនន្ទ ! ចាប់ពីថ្ងៃនេះទៅ កាលដែលប្អូនបេះផ្លែឈើទុំខ្ចីបានមកហើយចូរចាំបងមកដល់សិន សឹមយើងទាំងពីរនាក់បង្អោនជូនលោកបរិភោគជាមួយគ្នាតែម្ដង ។ នន្ទជាប្អូននោះ សូម្បីសោណជាបងប្រាប់យ៉ាងនេះហើយក៏ដោយ នៅគិតចង់បានបុណ្យតែម្នាក់ឯង ក៏មិនបានធ្វើតាមពាក្យរបស់បងឡើយ ។ ព្រះមហាសត្វគិតថា នន្ទមិនស្ដាប់បង្គាប់យើងទេ ហើយធ្វើការណ៍មិនសមគួរសោះ យើងនឹងបណ្ដេញ

គេចេញ ហើយរាប់ពីពេលនោះទៅ យើងនឹងបម្រើមាតាបិតាតែម្នាក់ឯងចុះ, លុះគិតហើយ ក៏ហៅតាបសប្អូនបណ្តេញចេញដោយពាក្យថា នែនន្ទ ! ឯងជាមនុស្ស មិនលុះក្នុងឱវាទ មិនធ្វើតាមពាក្យបណ្ឌិតទាំងឡាយ យើងជាបង ភារៈចិញ្ចឹមមាតាបិតាជារបស់យើងពិត យើងនឹងទំនុកបម្រុងពួកលោកតែម្នាក់ឯងក៏បាន ឯងមិនត្រូវបានឲ្យនៅទីនេះទៀតទេ ចូរទៅនៅក្នុងទីដទៃទៅ ថាហើយ ក៏វាយម្រាមដៃនន្ទបណ្ឌិតនោះ ។

## នន្ទបណ្ឌិតរកវិធីសុំខមាទោសតាបសបង

នន្ទបណ្ឌិតជាប្អូននោះ ត្រូវតាបសជាបងនោះបណ្តេញហើយ ក៏មិនអាចដើម្បីនឹងឈរនៅក្នុងសំណាក់សោណបណ្ឌិតនោះបានទៀតឡើយ ហើយក៏ថ្វាយបង្គំលាបងចូលទៅរកមាតាបិតារៀបរាប់ប្រាប់ សេចក្តីនោះសព្វគ្រប់ បន្ទាប់មកក៏ចូលទៅក្នុងបណ្ណសាលារបស់ខ្លួនសម្លឹងកសិណនិមិត្ត ញ៉ាំងអភិញ្ញាប្រាំ និងសមាបត្តិប្រាំបីឲ្យកើតឡើងក្នុងថ្ងៃនោះឯង រួចក៏គិតថា បើអាត្មាអញទៅ

កើបយកគ្រាប់ពេជ្រ ឬរតនៈទាំងឡាយដែលប្រៀបបាន នឹងគំនរខ្សាច់ពីជើងភ្នំសិនេរុ មកចាក់រោយត្រង់បរិវេណ នៃបណ្ណសាលានៃបងប្រុសរបស់យើង តើសមល្មមដើម្បី នឹងឲ្យបងប្រុសអត់ទោសឲ្យបានដែរទេ! ទេ! សូម្បីធ្វើ យ៉ាងនេះ ក៏នៅតែមិនសមរម្យឡើយ, តែបើអាត្មាអញទៅ ដងយកទឹកអំពីអនោតត្តស្រះ មកចាក់ស្រោចស្រពត្រង់ បរិវេណបណ្ណសាលានៃបងប្រុសរបស់យើង តើសមល្មម ដើម្បីនឹងឲ្យបងប្រុសអត់ទោសឲ្យដែរទេហ្ន៎! ទេ ! សូម្បី ធ្វើយ៉ាងនេះ ក៏នៅតែមិនសមរម្យដែរ, ប្រសិនបើបងប្រុស អាចអត់ទោសឲ្យយើងបាន ដោយអំណាចនៃពួកទេវតា ទាំងឡាយ តើយើងនាំនូវស្តេចមហារាជទាំងបួននិងស្តេច សក្កទេវរាជមកល្មមនឹងឲ្យបងប្រុស អត់ទោសឲ្យបានដែរ ឬហ្ន៎! ទេ! សូម្បីធ្វើយ៉ាងនេះ ក៏នៅតែមិនសមរម្យដែរ, អញ្ជឹងមានតែយើងនឹងនាំនូវព្រះរាជាទាំងឡាយ មានព្រះ បាទមនោជជាអគ្គរាជាជាប្រធានមកខមាទោសចុះ, កាល បើធ្វើយ៉ាងនេះ កិត្តិគុណនៃបងប្រុសរបស់យើងនឹងផ្សាយ

គ្រប់ដណ្តប់ទៅទូទាំងសកលជម្ពូទ្វីប នឹងចិញ្ចែងចិញ្ចាច ដូចជាព្រះចន្ទ និងព្រះអាទិត្យ ដូច្នោះ ។ នន្ទបណ្ឌិតនោះ ហោះទៅដោយឫទ្ធិតែម្តង ទៅចុះនៅត្រង់មាត់ទ្វារព្រះរាជវាំងនៃព្រះរាជាអង្គនោះ ឯព្រហ្មវឌ្ឍននគរ ឲ្យគេទៅក្រាបទូលព្រះរាជឱង្ការថា បានឮថា មានតាបសមួយអង្គ ចង់ចូលគាល់ព្រះអង្គ ដូច្នេះ ។ ព្រះរាជាក៏ទ្រង់ព្រះតម្រិះថា ប្រយោជន៍អ្វីដោយការដែលយើងជួបបព្វជិត លោកមកដើម្បីតែអាហារប៉ុណ្ណោះ ក៏បញ្ជូននូវចង្ហាន់ទៅប្រគេនទៅ (តែ)តាបសមិនប្រាថ្នាចង្ហាន់ឡើយ ។ ទ្រង់ក៏បញ្ជូនអង្ករទៅប្រគេន លោកមិនត្រូវការអង្ករទៀត ។ ទ្រង់បញ្ជូនសំពត់ទាំងឡាយទៅប្រគេន លោកក៏មិនត្រូវការសំពត់ទាំងនោះដែរ ។ ទ្រង់ក៏បញ្ជូនម្លូទៅប្រគេន លោកក៏មិនទទួលម្លូដែរ ។ គ្រានោះ ព្រះរាជាក៏ទ្រង់បញ្ជូនទូតទៅកាន់សំណាក់នន្ទតាបសនោះថា តើព្រះតេជគុណនិមន្តដើម្បីអ្វី ។ នន្ទបណ្ឌិតតាបសដែលទូតសួរហើយ ក៏ពោលថា អាត្មាមកដើម្បីគាល់បម្រើព្រះរាជា ។ ព្រះរាជាទ្រង់ព្រះ

សណ្ដាប់ពាក្យនោះហើយក៏បញ្ជូនទូតទៅថា អ្នកគាល់បម្រើរបស់យើងមានច្រើនហើយ ចូរព្រះតេជគុណ និមន្តចម្រើនតាបសធម៌របស់ខ្លួនលោកចុះ ។ តាបសឮពាក្យនោះហើយក៏ពោលថា អាត្មានឹងដណ្ដើមយករាជសម្បត្តិក្នុងជម្ពូទ្វីបទាំងមូល ដោយកម្លាំងរបស់អាត្មា មកថ្វាយព្រះអង្គ ។ ព្រះរាជាទ្រង់ព្រះសណ្ដាប់ដំណឹងនោះហើយទ្រង់ព្រះតម្រិះថា ធម្មតាបព្វជិតទាំងឡាយ គឺជាបណ្ឌិតតែងនឹងដឹងឧបាយណាមួយមិនខាន លុះទ្រង់ព្រះតម្រិះយ៉ាងនេះហើយ ក៏ឲ្យគេទៅនិមន្តនន្ទតាបសនោះមកនិមន្តឲ្យគង់លើអាសនៈ ថ្វាយបង្គំតាបសរួចទ្រង់មានព្រះបន្ទូលសួរទៅថា បពិត្រលោកម្ចាស់ដ៏ចម្រើន ឮថា លោកម្ចាស់អាចដណ្ដើមយកនូវរាជសម្បត្តិទូទាំងសកលជម្ពូទ្វីបមកប្រគល់ដល់ខ្ញុំព្រះករុណាឬ? នន្ទតាបសថ្វាយព្រះពរថា បពិត្រមហារាជ ចម្រើនពរ ។ តើលោកម្ចាស់នឹងដណ្ដើមយកយ៉ាងម៉េចបាន? បពិត្រមហារាជ អាត្មាភាពនឹងមិនបង្ហូរឈាមជនណាម្នាក់ ដោយហោចទៅសូម្បីតែ

ត្រឹមកូនរុយតូចមួយផឹកបានឡើយ ទាំងមិនចំណាយព្រះរាជទ្រព្យរបស់ព្រះអង្គទេ អាត្មានឹងដណ្តើមយកមកថ្វាយព្រះអង្គដោយឫទ្ធិនៃអាត្មាតែម្យ៉ាង, តែថាព្រះអង្គមិនគួរធ្វើឲ្យយឺតយូរអស់ពេលមានប្រមាណប៉ុណ្ណោះឡើយ គួរតែចេញដំណើរក្នុងថ្ងៃនេះឯង។ ព្រះបាទមនោជនោះទ្រង់ជឿសម្តីរបស់នន្ទតាបស ទ្រង់រៀបចំហែហមដោយពលសេនារក្សាអង្គចេញចាកព្រះនគរទៅហើយ ។ ថាបើមានកម្តៅថ្ងៃ ក្តៅទៅលើកងទ័ព នន្ទបណ្ឌិតក៏និមិតនូវស្រមោលម្លប់ដោយឫទ្ធិរបស់ខ្លួន ធ្វើឲ្យត្រជាក់វិញ, ទុកណាបើកាលមានភ្លៀងបង្អុរចុះមក ក៏លោកមិនឲ្យភ្លៀងទទឹកកងទ័ពឡើយ, លោកតែងការពារបញ្ចៀសត្រជាក់ផង ក្តៅផង ញ៉ាំងអន្តរាយទាំងឡាយទាំងពួងមានទាំងដង្គត់ឈើ និងបន្លាជាដើមឲ្យវិនាសបាត់ទៅ លោកធ្វើនូវផ្លូវឲ្យស្មើប្រៀបដូចជាកសិណមណ្ឌល[៥] ក្រាលនូវច្រម-

---

[៥] ទីរាបស្មើគ្នាទាំងអស់ មិនមានរដិបរដុប ទល់ទើសអ្វីឡើយ

ខណ្ឌ[៦] ឭដ៏អាកាសដោយខ្លួនឯងអង្គុយពែនភ្នែនហែហម ដោយពលសេនានិមន្តទៅ ។

## ការវាយដណ្តើមយកប្រទេសទាំង ១០១

នន្ទបណ្ឌិតតាបស ដឹកនាំកងទ័ពមានប្រការយ៉ាងនេះ ក៏បានទៅដល់ដែនកោសលជាដំបូង ឲ្យកងទ័ពបោះបន្ទាយស្នាក់នៅជិតព្រះនគរ រួចបញ្ជូនទូតទៅថ្វាយស្តេចកោសលរាជថា ព្រះរាជាចូរប្រយុទ្ធ ឬប្រគល់ស្វេតច្ឆត្រ ។ ព្រះបាទកោសលរាជទ្រង់ព្រះពិរោធជាខ្លាំង ដោយទ្រង់ព្រះតម្រិះថា ពួកនេះ មិនទុកយើងជាស្តេចទេឬអ្វី ក៏តបព្រះរាជឱង្ការទៅថា យើងព្រមប្រយុទ្ធតតាំងគ្នា ហើយក៏យាងចេញនាំមុខពលសេនាទៅ។ កងទ័ពទាំងពីរប្រារព្ធនឹងច្បាំងគ្នា ។ នន្ទបណ្ឌិតក៏និមិតនិសីទនៈ[៧] ស្បែកខ្លារខិនរបស់ខ្លួនយ៉ាងធំ ពាំងត្រង់ចន្លោះនៃកងទ័ពទាំងពីរលាតសន្ធឹងចាំទទួលនូវផ្លែព្រួញ ដែលកងទ័ពទាំងសង

---

[៦] កម្រាលស្បែក ឬកំណាត់ស្បែក

[៧] សំពត់សម្រាប់ទ្រាប់អង្គុយ ឬកម្រាលទ្រាប់អង្គុយរបស់អ្នកបួស

ខាងបាញ់ចេញទៅហើយដោយកម្រាលស្បែកមែនពិត ។ មិនមានសូម្បីទាហានម្នាក់ នៃកងទ័ពម្ខាងណា ត្រូវបាញ់មុតដោយព្រួញឡើយ មិនតែប៉ុណ្ណោះ កងទ័ពទាំងសងខាងក៏ឈប់បាញ់តទៅទៀតដែរ ព្រោះអស់កូនសរ (ផ្លែព្រួញ) ពីដៃរលីង ។ នន្ទបណ្ឌិតក៏ចូលទៅកាន់សំណាក់ព្រះបាទមនោជលួងលោមព្រះអង្គថា បពិត្រមហារាជ សូមទ្រង់កុំភ័យឡើយ ហើយក៏និមន្តទៅកាន់សំណាក់ព្រះបាទកោសល ហើយថ្វាយព្រះពរទូលទៅថា បពិត្រមហារាជ សូមទ្រង់កុំភ័យឡើយ សេចក្ដីអន្តរាយនឹងមិនមានដល់ព្រះអង្គឡើយ រាជ្យរបស់ព្រះអង្គនឹងនៅតែជារបស់ទ្រង់ដដែល តែសូមទ្រង់ស្ថិតនៅក្រោមអំណាចរបស់ព្រះបាទមនោជប៉ុណ្ណោះ ។ ព្រះអង្គស្ដាប់តាមពាក្យតាបសហើយក៏ទទួលថា សាធុ ប្រពៃហើយ ។ នន្ទបណ្ឌិតក៏នាំព្រះបាទកោសល ទៅកាន់សំណាក់ព្រះបាទមនោជពេលនោះ ហើយទូលព្រះឱង្ការថា បពិត្រមហារាជ ព្រះបាទកោសលរាជ ព្រមចំណុះក្នុងអាជ្ញារបស់ទ្រង់ហើយ

រាជសម្បត្តិរបស់ស្តេចអង្គនេះ ចូរនៅជារបស់ស្តេចអង្គ
នេះដដែលចុះ ក្រាបទូល ។ ព្រះបាទមនោជទទួលព្រម
ថា សាធុ ប្រពៃហើយ ក៏ឲ្យព្រះបាទកោសលរាជ អង្គនោះ
ប្រព្រឹត្តតាមអាជ្ញារបស់ទ្រង់ ហើយនាំយកកងទ័ពទាំងពីរ
នគរទៅកាន់ដែនអង្គៈ ដណ្តើមយកដែនអង្គៈហើយ ក៏
ចេញពីទីនោះទៅយកដែនមគធៈទៀត ទ្រង់ក៏ដណ្តើម
បានដែនមគធៈដោយឧបាយនេះឯង ព្រះបាទ មនោជ
ញុំាងព្រះរាជាទាំងឡាយក្នុងជម្ពូទ្វីបទាំងមូល ឲ្យចំណុះ
ក្នុងអំណាចរបស់ព្រះអង្គហើយ លំដាប់តពីនោះ ទ្រង់
ហែហមចោមជុំដោយកងទ័ព និងព្រះរាជាមានប្រមាណ
ប៉ុណ្ណោះ យាងត្រឡប់សំដៅទៅព្រហ្មវឌ្ឍននគរវិញដោយ
ប្រការយ៉ាងនេះ ។ ព្រះអង្គបានចំណាយពេលប្រាំពីរឆ្នាំ
ប្រាំពីរខែ ប្រាំពីរថ្ងៃ ច្បាំងដណ្តើមយករាជសម្បត្តិ (ទាំង
នោះ)។ ព្រះបាទមនោជនោះទ្រង់ត្រាស់បញ្ជាឲ្យព្រះរាជា
ទាំងនោះ នាំយកនូវបង្អែម និងចង្អាបមានប្រការប្លែក ៗ
ផ្សេងៗ មកអំពីរាជធានីនីមួយៗ ទ្រង់នាំព្រះរាជាទាំង

១០១ ព្រះអង្គសោយទឹកបានយ៉ាងច្រើនប្រភេទជាមួយព្រះរាជាទាំងនោះអស់ ៧ ថ្ងៃ ។

## ននូបណ្ឌិតមិនត្រូវការរាជ្យក្នុងជម្ពូទ្វីប

ននូបណ្ឌិតគិតថា យើងនឹងមិនបង្ហាញខ្លួនដល់ព្រះរាជាឡើយ ទុកឲ្យទ្រង់សោយនូវឥស្សរិយសុខ ដរាប ៧ ថ្ងៃសិនចុះ ហើយក៏នឹងទៅបិណ្ឌបាតនៅឧត្តរកុរុទ្វីប និងអាស្រ័យនៅទៀបទ្វារកញ្ចនគុហា ឯហិមវន្តប្រទេស អស់ ៧ ថ្ងៃដែរ ។ ក្នុងថ្ងៃទី ៧ ព្រះបាទមនោជ កាលទ្រង់សម្លឹងពិចារណាមើលសិរីសម្បត្តិដ៏មហិមារបស់ទ្រង់ ទើបរឭកដល់ននូបណ្ឌិតថា យសសម្បត្តិនេះ មិនមែនជារបស់ដែលព្រះមាតាព្រះបិតា ឲ្យហើយដល់យើងទេ ទាំងមិនមែនបុគ្គលទាំងឡាយដទៃណាឲ្យដល់យើងឡើយ យស-សម្បត្តិនុ៎ះ កើតឡើង ព្រោះអាស្រ័យននូតាសបមែនពិត តែថ្ងៃនេះជាថ្ងៃទី ៧ ហើយ ដែលយើងមិនបានឃើញលោក ឱ! ហ្ន៎ តើអ្នកឲ្យយសសម្បត្តិដល់យើងនិមន្តទៅទីណាហើយ ។ ននូបណ្ឌិតនោះ បានដឹងនូវភាពដែល

ព្រះបាទមនោជនឹករឭកដល់ខ្លួន ក៏និមន្តមកតាំងនៅឰដ៏អាកាសខាងមុខ (ព្រះអង្គ) ។ ព្រះរាជាបានទ្រង់ទតឃើញហើយក៏ទ្រង់ព្រះតម្រិះថា យើងមិនទាន់ដឹងនូវការៈនៃតាបសនេះជាទេវតា ឬជាមនុស្សនៅឡើយទេ ប្រសិនបើ លោកជាមនុស្ស យើងនឹងប្រគល់នូវរាជសម្បត្តិទូទាំងសកលជម្ពូទ្វីបដល់លោកភ្លាម ។ តែបើជាទេវតា យើងនឹងធ្វើសក្ការបូជាដល់លោក ។ ព្រះអង្គកាលចង់ដឹងនូវការៈតាបសក៏ត្រាស់គាថាទីមួយថា៖

១. ទេវតា នុសិ គន្ធព្វោ
អទុ សក្កោ បុរិន្ទទោ
មនុស្សភូតោ ឥទ្ធិមា
កថំ ជានេមុ តំ មយន្តិ ។

**លោកជាទេវតាឬជាគន្ធព្វ ជាសក្ក បុរិន្ទទៈ ឬជា**
**មនុស្សមានឫទ្ធិ ធ្វើដូចម្ដេច យើងនឹងស្គាល់លោក?**

នន្ទបណ្ឌិតតាបសនោះបានស្ដាប់ពាក្យនោះហើយកាលប្រាប់នូវសភាពពិតក៏ពោលគាថាទីពីរថា៖

២.　នាបិ ទេវោ ន គន្ធព្វោ
នាបិ សក្កោ បុរិន្ទទោ
មនុស្សភូតោ ឥទ្ធិមា
ឯវំ ជានាហិ ភារជាតិ ។

**អាត្មាភាពមិនមែនជាទេវតា មិនមែនជាគន្ធព្វ មិនមែនជាសក្កបុរិន្ទទះទេ អាត្មាភាពជាមនុស្សមានឫទ្ធិ បពិត្រព្រះរាជាទ្រទ្រង់នូវភារៈ(ដែន) សូមព្រះអង្គជ្រាប យ៉ាងនេះចុះ ។**

បណ្ដាបទទាំងនោះ បទថា **ភារជ** សេចក្ដីថា តាបសហៅនូវការទ្រទ្រង់នូវភារៈនោះយ៉ាងនេះព្រោះភារៈ នៃព្រះរាជាទ្រង់ជាអ្នកទ្រទ្រង់នូវភារៈគឺដែនដី ។

ព្រះរាជាបានទ្រង់ព្រះសណ្ដាប់ហើយទ្រង់ព្រះតម្រិះ ថា បានឮថា មនុស្សភូតនេះ មានឧបការៈ ដ៏ធំធេងយ៉ាង នេះចំពោះយើង យើងនឹងញ៉ាំងមនុស្សនុ៎ះឲ្យរីករាយស្កប់ ស្កល់ដោយយសដ៏ខ្ពង់ខ្ពស់ ទើបត្រាស់៦ គាថាកន្លះថា៖

៣.　កតរូបមិទំ ភោតោ
វេយ្យាវច្ចំ អនប្បកំ

ទេវម្ហិ វស្សមានម្ហិ
អនោវស្សំ ករំ អកា ។

៤. តតោ វាតាតបេ ឃោរេ
សីតច្ឆាយំ ករំ អកា
តតោ អមិត្តមជ្ឈេសុ
សរតាណំ ករំ អកា ។

៥. តតោ ជីតានិ វត្ថានិ
វសិនោ តេ ករំ អកា
តតោ ឯកាសតំ ខត្យេ
អនុយន្តេ ករំ អកា ។

៦. បតិតាស្សុ មយំ កោតោ
វទ តំ កញ្ចមិច្ឆសិ
ហត្ថិយានំ អស្សរថំ
នារិយោ ច អលង្កតា
និវេសនានិ រម្មានិ

មយំ ភោតោ ឧបាមសេ ។

៧. អជវេឌ្ឍ វា មតជេ
មយំ ភោតោ ឧបាមសេ
អថ វា អស្សកាវេឌ្ឍ
សុមជា ឧម្ម តេ មយំ ។

៨. ឧបឌ្ឍំ វាបិ វេជ្ជស្ស
មយំ ភោតោ ឧបាមសេ
សចេ តេ អត្ថោ វេជ្ជេន
អនុសាស យទិច្ឆសិ ។

ការខ្វល់ខ្វាយបម្រើ មានភាពដែលលោកដ៏ចម្រើនធ្វើហើយ នេះជាការមិនមែនតិច កាលដែលភ្លៀងកំពុងធ្លាក់ចុះ លោកដ៏ចម្រើនអាចធ្វើមិនឲ្យមានភ្លៀងបាន ។ តពីនោះមក លោកដ៏ចម្រើនអាចធ្វើឲ្យម្លប់ដ៏ត្រជាក់បានក្នុងទីមានខ្យល់និងកំដៅថ្ងៃដ៏ខ្លាំង តពីនោះមក លោកដ៏ចម្រើន អាចធ្វើគ្រឿងការពារព្រួញ ក្នុងកណ្ដាលនៃសត្រូវទាំងឡាយបាន ។ តពីនោះមក លោកដ៏ចម្រើនអាចធ្វើ

ដែនទាំងឡាយដ៏សម្បូណ៌ (និង) អ្នកដែនទាំងនោះ ឲ្យលុះក្នុងអំណាច (របស់យើងខ្ញុំ) តពីនោះមក លោកដ៏ចម្រើន អាចធ្វើក្សត្រិយ៍ ១០១ ឲ្យជាចំណុះ (នៃយើងខ្ញុំបាន) ។ យើងខ្ញុំត្រេកអរនឹងលោកដ៏ចម្រើន លោកចង់បានរតនៈ (ណា) ចូរទទួលយករតនៈនោះចុះ យើងខ្ញុំប្រគេនយានដំរី រថសេះ ពួកនាងនារីដែលប្រដាប់ស្រេច ទាំងលំនៅគួរឲ្យត្រេកអរទាំងឡាយដល់លោកដ៏ចម្រើន ។ មួយទៀត យើងខ្ញុំប្រគេនដែនអង្គៈ ឬមគធៈ ដល់លោកដ៏ចម្រើន មួយទៀត យើងខ្ញុំសប្បាយចិត្តប្រគេនដែនអស្សកៈ ឬដែនអវន្តិដល់លោក ។ យើងខ្ញុំប្រគេនរាជ្យពាក់កណ្តាល ដល់លោកដ៏ចម្រើន បើលោកត្រូវការដោយរាជ្យ លោកចង់បានរបស់ណា សូមត្រួតត្រារបស់នោះចុះ ។

បណ្តាបទទាំងនោះ បទថា កតរូបមិទំ ប្រែថា មានភាពដែលលោកដ៏ចម្រើនធ្វើហើយ ។ បទថា វេយ្យាវច្ចំ បានដល់ ការងារដែលជាប់ដោយការខ្វល់ខ្វាយតាមផ្លូវកាយ ។ បទថា អនោវស្សំ ប្រែថា មិនឲ្យ

មានភ្លៀង អធិប្បាយថា ធ្វើឲ្យដូចដែលមិនមានភ្លៀងបង្អុរចុះមកសោះ ។ ពាក្យថា **សីតច្ឆាយំ** ប្រែថា ម្លប់ដ៏ត្រជាក់ ។ ពីរបទថា **វសិនោ តេ** សេចក្តីថា (លោកធ្វើ) នូវជនទាំងឡាយ ដែលមានប្រក្រតីរស់នៅក្នុងដែននោះ ឲ្យលុះក្នុងអំណាចនៃយើងខ្ញុំ ។ បទថា **ខត្យេ** ប្រែថា ក្សត្រិយ៍ (ស្តេច) ព្រោះបាលីថា **ខត្តិយេ** នេះឯងមានប្រាកដក្នុងអដ្ឋកថា ។ បទថា **បតិតាស្សុមយំ** ប្រែថា ពួកយើងខ្ញុំមានសេចក្តីរីករាយត្រេកអរហើយ ។ បទថា **ភញ្ញំ** ក្នុងបាទព្រះគាថាថា **វរ តំ ភញ្ញមិច្ឆសិ** នុ៎ះ ជាឈ្មោះនៃរតនវត្ថុ សេចក្តីអធិប្បាយថា យើងខ្ញុំប្រគេនពរដល់លោកដ៏ចម្រើន លោកដ៏ចម្រើនប្រាថ្នា ចង់បាននូវរតនៈណា ចូរប្រាប់ចំពោះនូវរតនៈនោះមកចុះ ។ ព្រះរាជាតែងសម្តែងដល់រតនៈនោះៗ ដោយសរុប ដោយពាក្យទាំងឡាយមានពាក្យថា **ហត្ថិយានំ** ជាដើម ។ បទថា **អស្សកាវន្តី** ប្រែញែកថា ដែនអស្សកៈ ឬក៏ដែនអវន្តី ។ បទថា **វជ្ជេឝ** សេចក្តីថា ទោះបីណាបើ

លោកដ៏ចម្រើនត្រូវការដោយរាជ្យ ក្នុងជម្ពូទ្វីបទាំងមូល អធិប្បាយថា យើងខ្ញុំក៏នឹងប្រគេនសូម្បីនូវរាជសម្បត្តិដល់លោកដ៏ចម្រើន ហើយយើងខ្ញុំនឹងកាន់ខែលនិងអាវុធក្នុងដៃរត់ទៅខាងមុខរថរបស់លោកដ៏ចម្រើន ។ បទថា **យទិច្ឆសិ** សេចក្ដីថា បើលោកដ៏ចម្រើនចង់បាននូវរបស់ណា បណ្ដារបស់តាមប្រការដែលយើងខ្ញុំរៀបរាប់មកហើយនុ៎ះ ចូរលោកដ៏ចម្រើនបង្គាប់ត្រួតត្រានូវរបស់នោះចុះ ។

នន្ទបណ្ឌិតបានស្ដាប់ព្រះបន្ទូលនោះហើយ កាលបញ្ជាក់នូវបំណងរបស់ខ្លួនក៏ពោលគាថាទី៩ ថា៖

៩. **ន មេ អត្ថោបិ រជ្ជេន**
**នគរេន ធនេន វា**
**អថោបិ ជនបទេន**
**អត្ថោ មយ្ហំ ន វិជ្ជតិ ។**

**អាត្មាភាព មិនត្រូវការដោយរាជ្យ ដោយនគរ ឬដោយទ្រព្យ ទាំងមិនត្រូវការដោយជនបទទេ។**

បន្ទាប់មកក៏សំណូមពរថា ប្រសិនបើ ព្រះអង្គមាន

សេចក្តីស្រឡាញ់ពេញចិត្តនឹងអាត្មា សូមព្រះអង្គ ធ្វើតាមពាក្យអាត្មាមួយម៉ាត់ចុះ រួចក៏ពោលពីរគាថាទៀតថា ៖

១០. ភោតោរ រដ្ឋេ វិជិតេ
អរញ្ញេ អត្ថិ អស្សមោ
បិតា មយ្ហំ ជនេត្តី ច
ឧភោ សម្មន្តិ អស្សមេ ។

១១. តេសាហំ បុព្វាចរិយេសុ
បុញ្ញំ ន លភាមិ កាតវេ
ភវន្តំ អជ្ឈាវរំ កត្វា
សោណំ យាចេមុ សំវរំ ។

ក្នុងព្រៃក្នុងដែនជាអាណាខេត្តរបស់ព្រះអង្គដ៏ចម្រើន មានអាស្រមមួយ បិតាមាតារបស់អាត្មាភាព ទាំងពីរនាក់នៅក្នុងអាស្រមនោះ ។ អាត្មាភាពមិនបានធ្វើបុណ្យចំពោះបុព្វាចារ្យទាំងនោះ យើងធ្វើព្រះអង្គដ៏ចម្រើនឲ្យប្រសើរលើសលុប ឲ្យសូមនូវការរួបរួមជាមួយនឹងសោណបណ្ឌិតតាបស។

បទថា **រដ្ឋេ** ប្រែថា ក្នុងរាជ្យ ។ បទថា **វិជិតេ** ប្រែថា ក្នុងទីដែលប្រព្រឹត្តទៅក្នុងអាជ្ញា ។ បទថា **អស្សមោ** សេចក្តីថា មានអាស្រមមួយក្បែរព្រៃហេមពាន្ត ។ បទថា **សម្មន្តិ** សេចក្តីថា មាតាបិតារបស់ អាត្មាភាពអាស្រ័យនៅក្នុងអាស្រមនោះ ។ បទថា **តេសាហំ** កាត់បទជា **តេសុ អហំ** ។ បទថា **ភាតរេ** សេចក្តីថា អាត្មាមិនបានការធ្វើនូវបុណ្យពោលគឺការប្រតិបត្តិវត្តតូចធំ និងការនាំយកផលាផល (ជូនលោកពិសា) បងប្រុសរបស់អាត្មាភាពឈ្មោះ សោណបណ្ឌិត ព្រោះតែទោសកំហុសមួយរបស់អាត្មា លោកក៏បណ្តេញអាត្មាដោយពាក្យថា ឯងកុំនៅក្នុងទីនេះទៀត ដូច្នេះ ។ បទថា **អជ្ឈាវរំ** សេចក្តីថា យើងធ្វើនូវការរៀបចំដ៏ប្រសើរលើសលុប ដ៏ចម្រើនព្រមទាំងបរិវារដល់ព្រះអង្គ ឲ្យសូមនូវការរួបរួមជាមួយនឹងសោណបណ្ឌិត អធិប្បាយថា យើងទាំងឡាយសូមនូវការរួបរួមតទៅ ។ បាលីថា **យាចេមិមំ វរំ** ក៏មាន សេចក្តីថា យើងទាំងឡាយគប្បីសូម គឺថាខមាទោសចំពោះសោណ-បណ្ឌិត ជាមួយនឹងព្រះអង្គ អាត្មាភាព កាន់យកពរនេះ

អំពីសំណាក់ព្រះអង្គ ។

ឆន្ទបណ្ឌិតនិជ៍ស្តេច ១០១ ចូលព្រៃ ដើម្បីសុំខមាទោសសោណបណ្ឌិត

គ្រានោះ ព្រះរាជាក៏មានព្រះរាជឱង្ការទៅតាបសថា

១២. ករោមិ តេ តំ វចនំ
យំ មំ ភណសិ ព្រាហ្មណ
ឯតញ្ច ខោ នោ អក្ខាហិ
កីវន្តោ ហោន្តុ យាចកា ។

បពិត្រព្រាហ្មណ៍ ខ្ញុំធ្វើតាមពាក្យរបស់លោកដែលលោកពោលនឹងខ្ញុំ សូមលោកប្រាប់នូវហេតុនោះ ដល់យើងខ្ញុំ តើឲ្យពួកជនប៉ុន្មាននាក់ ជាអ្នកជួយអង្វរករ ។

បណ្ដាបទទាំងនោះ បទថា **ករោមិ** សេចក្ដីថា ព្រះរាជាត្រាស់ថា ខ្ញុំកាលហ៊ានឲ្យនូវរាជសម្បត្តិ ក្នុងជម្ពូ-ទ្វីបទាំងមូលបាន រឿងអីដែលនឹងមិនធ្វើតាមប្រការត្រឹមប៉ុណ្ណោះ ខ្ញុំនឹងធ្វើតាម ។ ពាក្យថា **កិត្តកា** ប្រែថា ប៉ុន្មាននាក់ ។

នន្ទបណ្ឌិតពោលថា ៖

១៣. បរោសតំ ជាឯបទា
មហាសាលា ច ព្រាហ្មណា
ឥមេ ច ខត្តិយា សព្វេ
អភិជាតា យសស្សិនោ
ភវញ្ច រាជា មនោជោ
អលំ ហោស្សន្តិ យាចកា ។

ពួកគហបតីមហាសាលជាងមួយរយ ពួកព្រាហ្មណ៍មហាសាលជាងមួយរយ និងពួកក្សត្រិយ៍ទាំងអស់ ដែលមានជាតិដ៏ខ្ពស់ មានយសនេះ ទាំងព្រះបាទ មនោជះដ៏ចម្រើន ទើបល្មមជាអ្នកជួយអង្វរករ ។

បណ្តាបទទាំងនោះ បទថា ជានាបទា ប្រែថា ពួកគហបតី ។ បាទគាថាថា មហាសាលា ច ព្រាហ្មណា សេចក្តីថា ពួកព្រាហ្មណ៍ដែលដល់ព្រមដោយសារប្រយោជន៍ជាងមួយរយមែនពិត ។ ពីរបទថា អលំ ហោស្សន្តិ សេចក្តីថា នឹងជាការសមល្មម ។

បទថា យាចកា សេចក្តីថា ដើម្បីអាត្មាភាពសូមខមាទោសចំពោះសោណបណ្ឌិត ។

គ្រានោះ ព្រះរាជាត្រាស់ចំពោះមុខនន្ទបណ្ឌិតថា៖

១៤. ហត្ថី អស្សេ ច យោជេន្តុ
រថំ សន្នយ្ហ សារថិ
អាពន្ធនានិ គណ្ហាថ
បាទាសុស្សារយទ្ធជេ
អស្សមំ តំ គមិស្សាមិ
យត្ថ សម្មតិ កោសិយោ ។

ពួកអ្នករក្សាដំរី ពួកអ្នករក្សាសេះ ចូរនាំគ្នាចាត់ចែងនូវពួកដំរីពួកសេះ ម្នាលសារថី អ្នកចូរជ្រាមរថអ្នកទាំងឡាយ ចូរយកគ្រឿងប្រដាប់សម្រាប់ចង (ឯដំរីសេះរថ) ជនទាំងឡាយ ចូរលើកទង់ជ័យ ត្រង់ជើងទង់ជ័យដែលតម្កល់លើរថ អញនឹងទៅកាន់អាស្រមជាទីនៅនៃកោសិយគោត្ត ។

ជំនុំបទទាំងនោះ បទថា យោជេន្តុ សេចក្តីថា

ពួកអ្នករក្សាដំរីចូរចាត់ចែងនូវដំរី ពួកអ្នករក្សាសេះ ចូរចាត់ចែងនូវសេះ ។ បាទព្រះគាថាថា **រថំ សន្នយ្ហ សារថិ** ប្រែថា ម្នាលសារថីសម្លាញ់ សូម្បីអ្នកក៏ចូរជ្រាមនូវរថដែរ។ បទថា **អាពន្ធនានិ** សេចក្ដីថា អ្នកទាំងឡាយ ចូរយកនូវគ្រឿងប្រដាប់សម្រាប់ចងប្រដាប់ឰដ៏ដំរី សេះ និងរថទាំងឡាយ ។ បាទព្រះគាថាថា **ធាជាសុស្សាបយន្តុ** សេចក្ដីថា ជនទាំងឡាយ ចូរត្រួតពិនិត្យ ចូរលើកនូវទង់ជ័យទាំងឡាយ ត្រង់ជើងទង់ជ័យដែលតម្កល់លើរថ។ បទថា **កោសិយោ** សេចក្ដីថា ក្នុងអាស្រមណាដែលកោសិយគោត្តអាស្រ័យនៅ ។

ព្រះសម្ពុទ្ធកាលប្រកាសសេចក្ដីនេះ ទើបទ្រង់ត្រាស់អភិសម្ពុទ្ធគាថានេះថា ៖

១៥. **តតោ ច រាជា ធាយាសិ**
**សេនាយ ចតុរង្គិនី**
**អគមា អស្សមំ រម្មំ**
**យត្ថ សម្មតិ កោសិយោ ។**

**លំដាប់ពីនោះមក ព្រះរាជាបានយាងទៅដោយសេនាប្រកបដោយអង្គ ៤ ទ្រង់ស្តេចទៅកាន់អាស្រមជាទីរីករាយ ជាទីនៅនៃកោសិយគោត្ត ។**

ចំណោមបទទាំងនោះ បទថា **តតោ ច** អធិប្បាយថា ម្នាលភិក្ខុទាំងឡាយ លំដាប់ពីនោះ ព្រះរាជាអង្គនោះ បាននាំស្តេចទាំង ១០១ ព្រះអង្គ ហែហមដោយសេនាដ៏ច្រើន ឲ្យនន្ទបណ្ឌិតនាំមុខ ចេញចាកព្រះនគរហើយ ។ បទថា **ចតុរង្គិនី** គឺបានយាងទៅហើយដោយសេនាប្រកបដោយអង្គ ៤, សូម្បីអន្តរាយដែលប្រព្រឹត្តទៅតាមផ្លូវ ក៏លោកពោលហើយយ៉ាងនេះ ព្រោះនន្ទបណ្ឌិតបញ្ចៀសភ្លៀងឲ្យទៅជាមិនមានភ្លៀងហើយ ។ ព្រះរាជាកាលយាងទៅតាមផ្លូវ មួយអន្លើដោយកងពលប្រមាណ ២៤ អក្ខោភិនី [៨] នន្ទបណ្ឌិតបាននិមិតជាផ្លូវដ៏រាបស្មើមាន

[៨] ឫស្សី ៦០ បាច់ ក្នុងមួយបាច់ ៦០ ដើម ពួកសេនាទាហាន ដើរជាន់បាក់បែកខ្ទេចខ្ទីអស់ សេនាដូច្នេះ ហៅថា ១ អក្ខោភិណី, ឈ្មោះសំខ្យាម្យ៉ាងដាក់ លេខ ១ មានពិន្ទុ ៤២, បាលីខ្លះថា អក្ខោហិណីក៏មាន ។

ទទឹងប្រមាណ ៨ ឧសភៈ [៩] ហើយលោកក្រាលច្រមខណ្ឌ ព្វដ៏អាកាសអង្គុយពែនភ្នែនលើច្រមខណ្ឌនោះ ហែហម ដោយពលសេនា កាលសម្ដែងកថាដ៏សមគួរដល់ធម៌ ជាមួយនឹងព្រះរាជាដែលទ្រង់គង់លើកដំរី ដែលគេប្រដាប់តាក់តែងយាងទៅហើយ លោករារាំងបញ្ចៀសនូវរាល់អន្តរាយផ្សេងៗ មានត្រជាក់ក្ដៅជាដើម ធ្វើដំណើរទៅ ។

## សោណបណ្ឌិតជួបនឹងព្រះចាងមនោជ

គ្រានោះ ក្នុងថ្ងៃដែលនន្ទបណ្ឌិត និងពលសេនាមកដល់នោះដែរ សោណបណ្ឌិតកំពុងពិចារណាថា ប្អូនប្រុសរបស់យើងបានចាកចេញទៅអស់ជាង ៧ ឆ្នាំ ៧ ខែ ៧ ថ្ងៃហើយ តើឥឡូវនេះ លោកនៅទីណាហ្ន៎! កាលប្រមើលមើលដោយទិព្វចក្ខុ ក៏បានឃើញនន្ទបណ្ឌិតនាំព្រះរាជា ១០១ មួយអន្លើដោយបរិវារ ប្រមាណ ២៤ អក្ខោភិនី មកបំណងនឹងសូមខមាទោសចំពោះលោកនោះឯង ក៏គិតថា ក៏កាលដែលពួកស្ដេច និងបរិស័ទទាំងឡាយ ដែល

---

[៩] មួយឧសភៈ ស្មើនឹង ២០ យដ្ឋិ មួយយដ្ឋិ ត្រូវជា ៧ ហត្ថ ពីរហត្ថ ត្រូវជាមួយម៉ែត្រ ដូច្នេះ ៨ ឧសភៈ ត្រូវជា ៥៦០ ម៉ែត្រ

បានឃើញនូវបាដិហារ្យដ៏ច្រើន នៃប្អូនប្រុសរបស់យើង មិនដឹងនូវអានុភាពនៃយើង គប្បីនាំគ្នាពោលត្មះតិះដៀល យើង ប្រាកដជាធ្លាក់ទៅអវចីមិនខានឡើយ (ដូច្នេះ) យើង នឹងសម្ដែងឥទ្ធិបាដិហារ្យឲ្យអ្នកទាំងនោះបានឃើញ រួចលោកក៏ដាក់ដងរែកក្នុងលំហអាកាស មិនឲ្យប៉ះស្មា ដោយប្រមាណ ៤ ធ្នាប់ ហោះទៅតាមអាកាសក្បែរ ព្រះរាជាដើម្បីទៅដងទឹកពីអនោតត្តស្រះ ។ នន្ទបណ្ឌិត កាលបានឃើញបងកំពុងនិមន្តមក មិនហ៊ាននឹងបង្ហាញ ខ្លួន ក៏បាត់ចាកទីអង្គុយភ្លាម រត់ចូលទៅព្រៃហេមពាន្ត។ លំដាប់នោះ ព្រះបាទមនោជរាជ កាលបានឃើញ សោណបណ្ឌិតកំពុងនិមន្តមក ដោយភេទជាឥសីដ៏ស្រស់ ត្រកាលដូចនោះ ក៏ត្រាស់គាថាថា ៖

១៦. កស្ស កាជម្ពយោ កាជោ
វេហាសំ ចតុរង្គុលំ
អំសំ អសំផុសំ ឯតិ
ឧទហារស្ស គច្ឆតោ ។

ដងរែកជាវិការៈនៃឈើក្ទម្ពរបស់អ្នកណា ដែលទៅដង

ទឹកហើយមិនប៉ះពាល់ស្មា ទៅលើអាកាសចំនួន ៤ ធ្នាប់ ។

បណ្ដាបទទាំងនោះ បទថា **ភាជម្ពយោ** ប្រែថា ដងរែកដែលសម្រេចដោយឈើក្នុម្ព ។ ពីរបទថា **អំសំ អសំផុសំ** សេចក្ដីថា មិនពាល់ត្រូវស្មាស្មោះ អណ្ដែតមកដោយខ្លួនឯងតែម្ដង ។ បទថា **ឧទហារស្ស** សេចក្ដីថា ដងរែកនុ៎ះរបស់អ្នកណាដែលកំពុងទៅដងទឹកអណ្ដែតមកយ៉ាងនេះ តើអ្នកឈ្មោះអ្វី ហើយតើអ្នកមកអំពីទីណា ។

កាលព្រះរាជាត្រាស់សួរយ៉ាងនេះហើយ ព្រះមហាសត្វទើបពោលពីរគាថាថា៖

១៧. អហំ សោណោ មហារាជ
តាបសោ សហិតព្វតោ
ភរាមិ មាតាបិតរោ
រត្តិន្ទិវមតន្ទិតោ ។

១៨. វនេ ផលញ្ច មូលញ្ច
អាហរិត្វា ទិសម្បតិ

ចោសេមិ មាតាបិតរោ

បុព្វេ កាតមនុស្សរំ ។

បពិត្រមហារាជ អាត្មាភាពជាតាបសឈ្មោះសោណៈ ប្រកបដោយវត្ត មិនខ្ជិលច្រអូស ចិញ្ចឹមមាតាបិតាទាំងយប់ទាំងថ្ងៃ ។ បពិត្រព្រះអង្គជាម្ចាស់នៃទិស អាត្មាភាព រឭកឃើញឧបការៈដែលមាតាបិតាធ្វើក្នុងកាលមុន ហើយក៏យកផ្លែឈើ និងមើមឈើក្នុងព្រៃ មកចិញ្ចឹមមាតាបិតា ។

ជំនុំបទទាំងនោះ បទថា **សហិតព្វតោ** គឺសោណបណ្ឌិតឆ្លើយតបថា អាត្មាភាពជាតាបសមួយអង្គមានវត្តនាំមកល្អហើយដល់ព្រមដោយសីលាចារ។ បទថា **ភរាមិ** ប្រែថា ចិញ្ចឹម ។ បទថា **អតន្ទិតោ** គឺជាអ្នកមិនខ្ជិលច្រអូសហើយ ។ បាទគាថាថា **បុព្វេ កាតមនុស្សរំ** សេចក្ដីថា កាលរឭកនូវគុណរបស់យើងដែលមាតាបិតានោះបានធ្វើហើយក្នុងកាលមុន ។

ព្រះរាជាបានទ្រង់ព្រះសណ្ដាប់ពាក្យនោះហើយ ទ្រង់មានប្រាថ្នានឹងធ្វើសេចក្ដីស្និទ្ធស្នាល ជាមួយតាបសនោះ ក៏ត្រាស់គាថាដទៃទៀតថា ៖

១៩. ឥច្ឆាម អស្សមំ គន្តុំ
យត្ថ សម្មតិ កោសិយោ
មគ្គំ នោ សោណ អក្ខាហិ
យេន គច្ឆេមុ អស្សមំ ។

**យើងខ្ញុំចង់ទៅកាន់អាស្រម ជាទីនៅរបស់កោសិយគោត្ត បពិត្រសោណៈ សូមលោកប្រាប់ផ្លូវដល់យើង យើងនឹងទៅកាន់អាស្រម ។**

បណ្តាបទទាំងនោះ បទថា **អស្សមំ** គឺអាស្រមបទរបស់លោកម្ចាស់ ។

គ្រានោះ ព្រះមហាសត្វ បាននិមិតផ្លូវទៅកាន់អាស្រមបទដោយអានុភាពរបស់ខ្លួន ទើបពោលគាថាថា៖

១០. អយំ ឯកបទី រាជ
យេនេតំ មេឃសន្និភំ
កោវិឡារេហិ សញ្ឆន្នំ
ឯត្ថ សម្មតិ កោសិយោ ។

**បពិត្រព្រះរាជា ផ្លូវដើរចុះតែជើង ១ នេះ មានព្រៃ**

**មានពណ៌ដូចជាផ្ទៃមេឃដ៏ដេរដាសដោយដើមរលួសផ្អុង នុ៎ះ ជាទីនៅរបស់កោសិយគោត្ត ។**

សេចក្តីអធិប្បាយនៃព្រះគាថានោះ ដូចតទៅនេះ ៖ បពិត្រមហារាជ នេះជាផ្លូវដើរចុះតែជើងមួយ ជាផ្លូវទៅដោយស្មង សូមព្រះអង្គយាងទៅតាមផ្លូវនេះចុះ កោសិយគោត្ត ជាបិតារបស់អាត្មាភាពតែងគង់ អាស្រ័យនៅក្នុងទិសាភាគ ដែលប្រាកដមានព្រៃមានពណ៌ដូចជាផ្ទៃនៃមេឃដ៏មីរដេរដាសដោយដើមរលួសផ្អុង កំពុងសំយុងចេញផ្ការីកស្គុះស្គាយ អាស្រមនុ៎ះជារបស់កោសិយគោត្តនុ៎ះ ។

ព្រះបរមសាស្តាកាលប្រកាសសេចក្តីនោះ ទើបត្រាស់អភិសម្ពុទ្ធគាថាទាំងនេះថា៖

១១. ឥទំ វត្វាន បក្កាមិ
តរមានោ មហាឥសិ
វេហាសេ អន្តលិក្ខស្មឹ
អនុសាសិត្វាន ខត្តិយេ ។

១២. អស្សមំ បរិមជ្ជិត្វា

បញ្ញាបេត្វាន អាសនំ
បណ្ណសាលំ បវិសិត្វា
បិតរំ បដិពោធយិ ។

១៣. ឥមេ អាយន្តិ រាជានោ
អភិជាតា យសស្សិនោ
អស្សមា និក្ខមិត្វាន
និសីទ ត្វំ មហាឥសេ ។

១៤. តស្ស តំ វចនំ សុត្វា
តរមានោ មហាឥសិ
អស្សមា និក្ខមិត្វាន
សទ្វារម្ហិ ឧបាវិសិ ។

លុះមហាឥសីពោលពាក្យនេះទូលប្រាប់ពួកក្សត្រិយ៍ ហើយ ប្រញាប់ប្រញាល់ចៀសចេញទៅ (កាន់ស្រះអនោតត្ត) តាមអាកាសវេហាស៍ មហាឥសី ក៏បោសសម្អាតអាស្រម រៀបចំអាសនៈ ចូលទៅកាន់បណ្ណសាលា ហើយជម្រាបបិតាឲ្យជ្រាបថា បពិត្រមហាឥសី ព្រះរាជា

**ទាំងនេះ មានជាតិខ្ពស់ មានយស យាងមក សូមព្រះបិតាចេញអំពីអាស្រមមកគង់ចាំទទួល ។ មហាឥសីឮពាក្យនោះរបស់កូននោះហើយ ក៏ប្រញាប់ប្រញាល់ចេញអំពីអាស្រម មកអង្គុយជិតទ្វារ ។**

បណ្ដាបទទាំងនោះ បទថា **បក្កាមិ** សេចក្ដីថា ចៀសចេញទៅកាន់អនោតត្តស្រះ ។ ពីរបទថា **អស្សមំ បរិមជ្ជិត្វា** អធិប្បាយថា ម្នាលភិក្ខុទាំងឡាយ ឥសីនោះទៅកាន់អនោតត្តស្រះដោយរហ័ស ដងទឹកប្រើប្រាស់ត្រឡប់យកមកចាក់ក្នុងក្អមទឹក នារោងសម្រាប់តម្កល់ទឹកប្រើប្រាស់ ទាំងដែលពួកស្ដេចទាំងនោះ មិនទាន់មកដល់អាស្រមផងសោះ បានអប់ទឹកដោយផ្កាឈើក្នុងព្រៃទាំងឡាយ ដោយគិតថា មហាជននឹងផឹក រួចហើយក៏ទាញអំបោសមកបោសសំអាតអាស្រម ក្រាលអាសនៈប្រគេនបិតាត្រង់ទ្វារបណ្ណសាលា ទើបចូលទៅពិតដំណឹងដល់បិតាឲ្យបានជ្រាប ។ បទថា **ឧចាវិសិ** បានដល់ អង្គុយលើអាសនៈខ្ពស់ ។

រីឯព្រះមាតារបស់ព្រះពោធិសត្វ ក៏អង្គុយក្នុងកន្លែង

ទាបដ៏សមគួរមួយខាងក្រោយតាបសជាបិតានោះ ។ ព្រះមហាសត្វអង្គុយលើអាសនៈទាបក្បែរនោះដែរ ។ ចំណែកឯនន្ទបណ្ឌិត កាលដែលព្រះពោធិសត្វទៅដងទឹកពីអនោតត្តស្រះយកមកអាស្រមនោះ ក៏និមន្តទៅកាន់សំណាក់ព្រះរាជា តាំងបន្ទាយនៅទីជិតអាស្រម ។ គ្រានោះ ព្រះរាជាទ្រង់ស្រង់ទឹក ហើយទ្រង់ប្រដាប់តាក់តែងដោយគ្រឿងអលង្ការគ្រប់យ៉ាង មានស្តេច ១០១ ជាបរិវារ នាំនន្ទបណ្ឌិតចូលទៅកាន់អាស្រម ដើម្បីសូមខមាទោសព្រះពោធិសត្វដោយប្រការដ៏លើសលុប ដោយលម្អនៃសិរីដ៏អស្ចារ្យ ។ គ្រានោះ បិតារបស់ព្រះពោធិសត្វកាលបានឃើញព្រះរាជាកំពុងយាងមកយ៉ាងនោះ ក៏សួរទៅព្រះពោធិសត្វ ឯព្រះពោធិសត្វក៏ពិតដល់ព្រះបិតានោះ ។

ព្រះបរមសាស្តាកាលទ្រង់ប្រកាសនូវសេចក្តីនោះ ទើប ត្រាស់នូវព្រះគាថាទាំងឡាយនេះ ៖

១៨. តញ្ច ជិស្វាន អាយន្តំ
ជលន្តំរិវ តេជសា
ខត្តសង្ឃបរិព្យូឡ្ហំ

កោសិយោ ឯតទព្រវិ ។

១៦. កស្ស ភេរី មុទិង្គា ច
សង្ខា បណវទិន្ទិមា
បុរតោ បដិបន្នានិ
ហាសយន្តា រថេសភំ ។

១៧. កស្ស កញ្ចនបដ្ដេន
បុថុនា វិជ្ជុវណ្ណិនា
យុវា កលាបសន្នទ្ធោ
កោ ឯតិ សិរិយា ជលំ ។

១៨. ឧក្កាមុខបហដ្ឋំវ
ខទិរង្គារសន្និភំ
មុខញ្ច រុចិរាភាតិ
កោ ឯតិ សិរិយា ជលំ ។

១៩. កស្ស បគ្គហិតំ ឆត្តំ
សសលាកំ មនោរមំ

អាទិច្ចវំសាវរណំ
កោ ឯតិ សិរិយា ជលំ ។

២០. កស្ស អគ្គំ បរិគ្គយ្ហ
វាលវីជនិមុត្តមំ
ចរន្តិ វរបុញ្ញស្ស
ហត្ថិក្ខន្ធេន អាយតោ ។

២១. កស្ស សេតានិ ឆត្តានិ
អាជានីយា ច វម្មិតា
សមន្តា បរិកីរេន្តិ
កោ ឯតិ សិរិយា ជលំ ។

២២. កស្ស ឯកសតំ ខត្យា
អនុយន្តា យសស្សិនោ
សមន្តា អនុបរិយន្តិ
កោ ឯតិ សិរិយា ជលំ ។

២៣. ហត្ថិអស្សរថបត្តិ

សេនា ច ចតុរង្គិនី
សមន្តា អនុបរិយន្តិ
កោ ឯតិ សិរិយា ជលំ ។

២៤. កស្សេសា មហតី សេនា
បិដ្ឋិតោ អនុវត្តតិ
អក្ខោភិនី អបរិយន្តា
សាគរស្សេវ ឩមិយោ ។

២៥. រាជាភិរាជា មនោជោ
ឥន្ទោវ ជយតំ បតិ
នន្ទស្សជ្ឈាវរំ ឯតិ
អស្សមំ ព្រហ្មចារិនំ ។

២៦. តស្សេសា មហតី សេនា
បិដ្ឋិតោ អនុវត្តតិ
អក្ខោភិនី អបរិយន្តា
សាគរស្សេវ ឩមិយោ ។

កោសិយគោត្តតាបស បានឃើញស្តេចនោះ ដូចជារុងរឿងដោយតេជះ មានពួកក្សត្រិយ៍ហែហម កំពុងយាងមក ហើយបានពោលពាក្យនេះថា ស្គរ សម្ភោរ ស័ង្ខ ស្គរតូច និងមហោរធឹករបស់អ្នកណា ញុំាងស្តេចជាបុគ្គលប្រសើរលើរថ ឲ្យរីករាយទៅខាងមុខ ។ (ទីបំផុតថ្ងាស) នៃអ្នកណា (បិទបាំង) ដោយដំបារមាសដ៏ធំ មានពណ៌ដូចជាផ្លេកបន្ទោរ ប្រុសកំលោះណា សៀតបំពង់ព្រួញ រុងរឿងដោយសិរី ហើយដើរមក ។ អ្នកណាមានមុខរុងរឿងភ្លឺចាំង ដូចជាមាសភ្លឺចិញ្ចាចត្រង់មាត់បាវ ស្រដៀងនឹងរងើកភ្លើងនៃឧសគគីរ រុងរឿងដោយសិរី ហើយដើរមក ។ អ្នកណា បាំងឆត្រព្រមទាំងផ្ទឹងជាទីរីករាយនៃចិត្ត ការពាររស្មីព្រះអាទិត្យ អ្នកណារុងរឿងដោយសិរី ហើយដើរមក ។ ពួកជនបិទបាំងជុំវិញ ខ្លួននៃអ្នកណា ដែលមានបុណ្យដ៏ប្រសើរ កំពុងជិះលើកនៃដំរី ដោយផ្លិតរោមសត្វដ៏ឧត្តម ហើយដើរទៅ។ ពួកឆត្រស និងពួកអាជានេយ្យប្រដាប់ដោយក្រោះខ្នាន់ខ្នាប់ជុំវិញ នៃអ្នកណា អ្នកណារុងរឿងដោយសិរី ហើយដើរមក ។ ពួកក្សត្រិយ៍មួយរយមួយ សុទ្ធតែមានយសជាស្តេចចំណុះ

ដើរហែហមជុំវិញនៃអ្នកណា អ្នកណារុងរឿងដោយសិរី ដើរមក ។ ពួកសេនាប្រកបដោយអង្គ ៤ គឺ ដំរី ១ សេះ ១ រថ ១ ពលថ្មើរជើង ១ ដើរហែហមជុំវិញ (នៃអ្នកណា) អ្នកណារុងរឿងដោយសិរី ដើរមក ។ សេនាដ៏ធំនេះ មិនមានអ្នកណាមួយឲ្យរំភើបបាន មិនមានទីបំផុតដូច ជារលកនៃសាគរ ប្រព្រឹត្តទៅតាមខាងក្រោយនៃអ្នកណា ។ (ព្រះមហាសត្វតបថា) ព្រះបាទមនោជៈ ជាព្រះរាជា ប្រសើរជាងពួកព្រះរាជា ដូចជាព្រះឥន្ទ្រជាធំជាងពួកទេវតា ក្នុងឋានត្រៃត្រិង្ស ដែលមានជ័យជម្នះ បានដល់នូវភាព ជាបរិស័ទនៃនន្ទតាបស មកកាន់អាស្រមនៃពួកព្រហ្មចារី បុគ្គល (ដើម្បីខមាទោសយើង) ។ សេនាដ៏ធំនេះ មិនមានអ្នកណាមួយ ឲ្យរំភើបបាន មិនមានទីបំផុត ដូចជារលកនៃសាគរ ប្រព្រឹត្តទៅតាមខាងក្រោយនៃ ព្រះបាទមនោជៈនោះ។

បណ្តាបទទាំងនោះ បទថា *ជលន្តំរិវ* កាត់បទជា *ជលន្តំ ឥវ* ។ បទថា *បដិបន្នានិ* សេចក្តីថា គ្រឿង តូរ្យតន្ត្រីទាំងឡាយនុ៎ះ ដើរទៅខាងមុខនៃអ្នកណា ។

ពាក្យថា **ហាសយន្តា** ប្រែថា ឲ្យរីករាយ ។ ពាក្យថា **កាញ្ចនបដ្ដេន**សេចក្ដីថា តាបសកោសិយគោត្តសួរទៅសោណបណ្ឌិតថា នៃកូនប្រុស ទីបំផុតថ្វាសនៃអ្នកណាបិទបាំងហើយដោយដំបារថ្វាសមានពណ៌ដូចជាពណ៌ នៃផ្លែកបន្ទោរដ៏សម្រេចហើយដោយមាស ។ ពាក្យថា **យុវា** ប្រែថា ប្រុសកំលោះ ។ បទថា **កលាបសន្នទ្ធោ** គឺមានបំពង់នៃកូនសរសៀតជាប់ហើយ ។ ពាក្យថា **ឧក្កាមុខបហដ្ឋំ វ** សេចក្ដីថា មានមុខរីករាយភ្លឺចិញ្ចែង ដូចជាមាសឮដ៏ជើងក្រាននៃពួកជាងដំលត់ ។ ពាក្យថា **ខទិរង្គារសន្និភំ** សេចក្ដីថា មានពណ៌ ដូចជារងើកភ្លើងនៃឧសគគីរ ដែលប្រកបដោយអណ្ដាតភ្លើងប្រាសទៅហើយ ។ ពាក្យថា **អាទិច្ចរំសាវរណំ** សេចក្ដីថា ជាគ្រឿងរាំងនូវរស្មីនៃព្រះអាទិត្យ ។ ពីរបទថា **អង្គំ បរិគ្គយ្ហ** សេចក្ដីថា បិទបាំងនូវខ្លួន គឺថាបិទបាំងនូវសរីរៈ ។ ពាក្យថា **វាលវីជនិមុត្តមំ** កាត់បទជា **វាលវីជនី ឧត្តមំ** ។ បទថា **ចរន្តិ** ប្រែថា ដើរទៅ ។

ពាក្យថា **ឆត្តានិ** បានដល់ ឆត្រទាំងឡាយដែលគេបាំងដល់ព្រះរាជាទាំងឡាយដែលគង់នៅលើខ្នងអាជានេយ្យ។ ពាក្យថា **បរិគ៌ាវេដ្ឋិ** សេចក្តីថា ណែនណាន់ខ្នាន់ខ្នាប់ក្នុងចំណែកនៃទិសទាំងពួងជុំវិញអ្នកនោះ ។ បទថា **ចតុរង្គិនី** សេចក្តីថា សេនាដ៏ប្រកបដោយអង្គទាំងឡាយ ៤ មានដំរីជាដើមនុ៎ះ ។ បទថា **អក្ខោភិនី** គឺមិនអាចដើម្បីនឹងនរណាមួយញុំាំងឲ្យកម្រើកបានឡើយ ។ ពាក្យថា **សាគរស្សេវ** មានសេចក្តីថា ប្រៀបដូចរលកនៃសាគរ(សមុទ្រ)ដែលមិនមានទីបញ្ចប់ ។ ពាក្យថា **រាជាភិរាជា** សេចក្តីថា ជាស្តេចដែលស្តេចទាំង ១០១ បូជាហើយ ឬថា ជាស្តេចប្រសើរ ក្រៃលែងជាងស្តេចទាំង ១០១ នោះ ព្រោះហេតុនោះ បានជាហៅថា **រាជាភិរាជា** ។ ពីរបទថា **ជយតំ បតិ** សេចក្តីថា ជាចម្បងនៃតាវត្តិង្សទេវតាទាំងឡាយ ដែលដល់ហើយនូវជ័យជម្នះ ។ ពាក្យថា **អជ្ឈាវរំ** សេចក្តីថា ចូលដល់នូវភាពជាបរិស័ទនៃនន្ទ មកដើម្បីខមាទោសខ្ញុំ ។

ព្រះសាស្តាត្រាស់ (បន្តទៀត) ថា ៖

២៧. អនុលិត្តា ចន្ទនេន
កាសិកុត្តមធារិនោ
សព្វេ បញ្ជលិកា ហុត្វា
ឥសីនំ អជ្ឈុបាគមុំ ។

**ពួកព្រះរាជាទាំងអស់ លាបស្រឡាបដោយខ្លឹមចន្ទន៍ ទ្រង់កាសិកពស្ត្រដ៏ឧត្តម បានផ្គងអញ្ជលីទៅរកពួកឥសី ។**

ឃ្លាថា **ឥសីនំ អជ្ឈុបាគមុំ** ក្នុងព្រះគាថានោះ មានសេចក្តីអធិប្បាយថា ម្នាលភិក្ខុទាំងឡាយ ព្រះរាជាទាំងនោះសូម្បីទាំងអស់អង្គ លាបស្រឡាបហើយដោយខ្លឹមចន្ទន៍ដ៏ក្រអូប ទ្រង់កាសិកពស្ត្រដ៏ឧត្តម ជាអ្នកមានអញ្ជលីដាក់លើសិរសា ដើរចូលទៅកាន់សំណាក់ពួកឥសី

លំដាប់ពីនោះមក ព្រះបាទមនោជក៏ថ្វាយបង្គំនូវឥសីនោះ ហើយគង់ក្នុងទីដ៏សមគួរ ហើយកាលទ្រង់ធ្វើបដិសណ្ឋារកិច្ចទើបត្រាស់ពីរព្រះគាថា៖

២៨. កច្ចិ នុ ភោតោ កុសលំ
កច្ចិ ភោតោ អនាមយំ

កច្ចិ ឧញ្ហេន យាបេថ
កច្ចិ មូលផលា ពហូ ។
២៩. កច្ចិ ឌំសា មកសា ច
អប្បមេវ សិរឹសបា
វនេ ពាឡមិគាកិណ្ណេ
កច្ចិ ហឹសា ន វិជ្ជតិ ។

លោកដ៏ចម្រើន មានសេចក្ដីសុខស្រួលទេឬ លោកដ៏ចម្រើន មានអនាម័យទេឬ លោកទាំងឡាយ ចិញ្ចឹមជីវិតដោយការស្វែងរកឬ មើមឈើ និងផ្លែឈើ មានច្រើនដែរឬ ពួករបោម មូស ពស់ មានតិចតួចដែរឬ ក្នុងព្រៃដ៏ដេរដាសដោយម្រឹគសាហាវ មិនបៀតបៀនទេឬ ។

តពីនោះ ក៏មានគាថាដទៃទៀត ជាគាថាពោលតបរបស់តាបសទាំងពីរអង្គនោះ ៖

៣០. កុសលញ្ចេវ នោ រាជ
អថោ រាជ អនាមយំ
អថោ ឧញ្ឆេន យាបេម

អថោ មូលផលា ពហូ ។

៣១. អថោ ឌំសា មកសា ច

អប្បមេវ សិរីសបា

វនេ ពាឡមិគាកិណ្ណេ

ហឹសា មយ្ហំ ន វិជ្ជតិ ។

៣២. ពហូនិ វស្សបូគានិ

អស្សមេ សម្មតំ ឥធ

ជាតិជាតាមិ ឧប្បន្នំ

អាពាធំ អមនោរមំ ។

៣៣. ស្វាគតន្តេ មហារាជ

អថោ តេ អទុរាគតំ

ឥស្សរោសិ អនុប្បត្តោ

យំ ឥធត្ថិ បវេទយ ។

៣៤. តិណ្ឌុកានិ បិយាលានិ

មធុកេ កាសុមារិយោ

ផលានិ ខុទ្ទកប្បានិ

កុញ្ជ រាជ វរំ វរំ ។

៣៥. ឥទម្បិ ចានីយំ សីតំ

អាភតំ តិរិតព្ភរា

តតោ បិវ មហារាជ

សចេ ត្វំ អភិកង្ខសិ ។

៣៦. បដិគ្គហិតំ យំ ទិន្នំ

សព្វស្ស អគ្ឃិយំ កាតំ

នន្ទស្សាបិ និសាមេថ

វចនំ សោ បវក្ខតិ ។

៣៧. អជ្ឈាវរម្ហា នន្ទស្ស

ភោតោ សន្តិកមាគតា

សុណាតុ ភវំ វចនំ

នន្ទស្ស បរិសាយ ច ។

បពិត្រព្រះរាជា អាត្មាភាព មានសេចក្តីស្រួលទេ

បពិត្រព្រះរាជា មួយទៀត អាត្មាភាព មិនមានសេចក្តីឈឺចាប់ទេ អាត្មាភាព ចិញ្ចឹមជីវិតដោយការស្វែងរក (ផលាផល) ស្រួលទេ ទាំងមើមឈើ និងផ្លែឈើក៏មានច្រើន ។ មួយទៀត ពួករបោម មូស ពស់ ក៏មានតិចតួចទេ ក្នុងព្រៃដ៏ដេរដាសដោយម្រឹគសាហាវ ក៏មិនបៀតបៀនអាត្មាភាពទេ ។ អាត្មាភាព មកនៅក្នុងអាស្រមនេះ អស់ប្រជុំនៃឆ្នាំជាច្រើន មិនដែលស្គាល់អាពាធ មិនជាទីត្រេកអរនៃចិត្ត កើតឡើងទេ ។ បពិត្រមហារាជ ព្រះអង្គយាងមកល្អហើយ មួយទៀត ព្រះអង្គមិនមែនយាងមកអាក្រក់ទេ ព្រះអង្គជាឥស្សរៈ យាងមកដល់ហើយ វត្ថុណាមានក្នុងទីនេះ សូមព្រះអង្គមានព្រះបន្ទូល ។ បពិត្រព្រះរាជា សូមព្រះអង្គសោយផ្លែទន្លាប់ ផ្លែទ្រយឹង ផ្លែស្រគំ ផ្លែមាក់ដោក មានរសឆ្ងាញ់ពិសា ដូចជាទឹកឃ្មុំ ។ ទឹកត្រជាក់នេះ អាត្មាភាពបានដងមកអំពីជ្រោះភ្នំ បពិត្រមហារាជ សូមព្រះអង្គសោយទឹក នោះចុះ ប្រសិនបើទ្រង់ត្រូវការ ។ (ព្រះរាជាតបថា) របស់ណាដែលលោកឲ្យហើយ (របស់នោះ) ឈ្មោះថា យើងខ្ញុំទទួលហើយ ទាំងបានធ្វើឲ្យជាជំនួនដល់ជនទាំងពួង លោកទាំងឡាយ

**ចូរស្តាប់ពាក្យនន្ទបណ្ឌិតតាបសលោកនឹងនិយាយឥឡូវ នេះ ពួកយើងជាបរិស័ទនៃនន្ទបណ្ឌិតតាបស បានមក កាន់សំណាក់នៃលោកដ៏ចម្រើន សោណបណ្ឌិតដ៏ចម្រើន ចូរស្តាប់ពាក្យនៃខ្ញុំផង នៃបរិស័ទរបស់នន្ទបណ្ឌិតផង ។**

សេចក្តីសម្ពន្ធជាប់គ្នាទាំងនេះ មានប្រាកដដោយ ច្រើនមែនពិត តែពាក្យណាមិនទាន់ប្រាកដច្បាស់ ក្នុងទី នេះ យើងនឹងពោលនូវពាក្យនោះតែម្យ៉ាង ។ ពាក្យថា **បវេទយ** សោណបណ្ឌិតពោលថា វត្ថុណា ដែលជាទី ពេញព្រះទ័យរបស់ព្រះអង្គមានក្នុងទីនេះ សូមព្រះអង្គ មានព្រះបន្ទូលមកចុះ ។ ពាក្យថា **ខុទ្ទកាបានិ** សេចក្តី ថា ផ្លែឈើផ្សេងៗទាំងនុ៎ះ មានរសផ្អែមប្រហែលគ្នានឹង ទឹកឃ្មុំដ៏ផ្អែមឈ្ងុយ ។ ពីរបទថា *វរំ វរំ* សេចក្តីថា សូម ទ្រង់ចាប់យកនូវផ្លែឈើដ៏ឧត្តមប្រសើរ អំពីទីនោះសោយ ចុះ ។ ពាក្យថា **តិវិតព្ភា** គឺ អំពីអនោតត្តស្រះ ។ ពីរពាក្យថា **សព្វស្ស អត្ថិយំ** សេចក្តីថា របស់ណា ដែលលោកប្រាប់ឲ្យហើយដល់យើងទាំងឡាយ ឈ្មោះថា ជារបស់ដែលយើងខ្ញុំទទួលហើយផង ឈ្មោះថា គឺលោក

ដ៏ចម្រើនទាំងឡាយឲ្យហើយផងមែនពិត មិនត្រឹមតែប៉ុណ្ណោះ ឈ្មោះថាគឺលោកដ៏ចម្រើនធ្វើឲ្យជាជំនួន ដល់ជនទាំងពួងនេះផង ។ ពាក្យថា **ឯតស្សាបិ** សេចក្តីថា ពាក្យទាំងអស់ជាពាក្យដែលយើងខ្ញុំមកធ្វើការរាក់ទាក់មុនតែឥឡូវនេះ នន្ទបណ្ឌិតចង់និយាយពាក្យខ្លះៗ សូមលោកដ៏ចម្រើនទាំងឡាយ ស្តាប់នូវពាក្យរបស់លោកសិនផងចុះ ។ ព្រះរាជាត្រាស់ពាក្យថា **អញ្ញាវវម្ហា** ព្រោះចង់បញ្ជាក់ថា ព្រោះថា យើងខ្ញុំទាំងឡាយ មកហើយមិនមែនដោយការងារដទៃទេឡើយ ក៏គឺជាបរិស័ទនៃនន្ទបណ្ឌិតតាបសមក ដើម្បីសូមខមាទោសចំពោះលោកដ៏ចម្រើន ។ បទថា **ភវំ** សេចក្តីថា សោណបណ្ឌិតដ៏ចម្រើនចូរស្តាប់ ។

## នន្ទបណ្ឌិតសុំខមាទោសសោណបណ្ឌិត

កាលព្រះរាជាត្រាស់យ៉ាងនេះហើយ នន្ទបណ្ឌិតក៏ក្រោកចាកអាសនៈថ្វាយបង្គំមាតាបិតានិងបងប្រុស កាលនិយាយជាមួយនឹងបរិស័ទរបស់ខ្លួន ក៏ពោលថា ៖

៣៨. បរោសតំ ជានបទា
    មហាសាលា ច ព្រាហ្មណា

ឥមេ ច ខត្តិយា សព្វេ
អភិជាតា យសស្សិនោ
ករញ្ចុ រាជា មនោជោ
អនុមញ្ញន្តុ មេ វចោ ។
៣៩. យេ ច សន្តិ សមិតារោ
យក្ខានិ ឥធ មស្សមេ
អរញ្ញេ ភូតភព្យានិ
សុណន្តុ វចនំ មម ។
៤០. នមោ កត្វាន ភូតានំ
ឥសឹ វក្ខាមិ សុព្វតំ
សោត្យាហំ ទក្ខិណា ពាហុ
តវ កោសិយ សម្មតោ ។
៤១. បិតរំ មេ ជនេត្តឹ ច
ភត្តុកាមស្ស មេ សតោ
វីរ បុញ្ញមិទំ ឋានំ

មា មំ កោសិយ វារយ ។

៤២. សព្ពិហេតំ ឧបញ្ញាតំ
មមេតំ ឧបនិស្សជ
ឧដ្ឋានចារិចរិយាយ
ជីយរត្តំ តយា កាតំ
មាតាបិតូសុ បុញ្ញានិ
មម លោកទោ ភវ ។

៤៣. តថេវ សន្តិ មនុជា
ធម្មេ ធម្មបទំ វិទូ
មគ្គោ សគ្គស្ស លោកស្ស
យថា ជានាសិ ត្វំ ឥសេ ។

៤៤. ឧដ្ឋានចារិចរិយាយ
មាតាបិតុសុខាវហំ
តំ មំ បុញ្ញា និវារេតិ
អរិយមគ្គាវរោ នរោ ។

ពួកគហបតិមហាសាលជាងមួយរយ ពួកព្រាហ្មណ-មហាសាលជាងមួយរយ និងពួកក្សត្រិយ៍ទាំងអស់ ដែលមានជាតិខ្ពស់ មានយសនេះ ទាំងព្រះបាទមនោជៈដ៏ចម្រើន សូមជ្រាបតាមសំដីរបស់អាត្មាភាពចុះ ។ ពួកជនដែលមកជួបជុំគ្នា ពួកយក្ស ពួកភូត និងទេវតាក្មេងមានក្នុងអាស្រមក្នុងព្រៃនេះ ចូរស្តាប់នូវពាក្យរបស់អាត្មា ។ អាត្មាធ្វើនមស្ការដល់ពួកភូតហើយ នឹងនិយាយចំពោះឥសី (ឈ្មោះសោណបណ្ឌិត) ដែលមានវត្តល្អថា ខ្ញុំនោះហើយដែលកោសិយគោត្តសន្មតថាជាដើមដៃស្តាំរបស់លោក ។ បពិត្រអ្នកមានព្យាយាម ការទំនុកបម្រុងមាតាបិតានេះជាបុណ្យរបស់ខ្ញុំ ដែលជាអ្នកប្រាថ្នាចិញ្ចឹមបិតានិងមាតារបស់ខ្ញុំ បពិត្រព្រះកោសិយៈ សូមលោកកុំឃាត់ខ្ញុំឡើយ ។ ការទំនុកបម្រុងមាតាបិតានុ៎ះ ពួកសប្បុរស បានដឹងហើយ សូមលោកលះបង់នូវការទំនុកបម្រុងមាតាបិតានេះឲ្យដល់ខ្ញុំ លោកបានធ្វើ (កុសល) ដោយការខ្នះខ្នែង និងការបម្រើយូរយារណាស់មកហើយ (ឥឡូវនេះ ខ្ញុំចង់ធ្វើ) បុណ្យទាំងឡាយដល់មាតានិងបិតា សូមលោកប្រគល់សួគ៌ទេវលោកដល់ខ្ញុំ ។ បពិត្រឥសីលោកដឹងផ្លូវទៅកាន់

**សួគ៌ទេវលោកយ៉ាងណា ពួកមនុស្សក៏ដឹងចំណែកធម៌ក្នុងធម៌យ៉ាងនោះដែរ ។ កិរិយានាំមកនូវសេចក្ដីសុខដល់មាតាបិតា ដោយការខ្នះខ្នែង និងការបម្រើ ឥឡូវនេះជន (សោណបណ្ឌិត) ហាមឃាត់ខ្ញុំនោះចាកបុណ្យឈ្មោះថាជាអ្នករារាំងផ្លូវដ៏ប្រសើរ (ឋានសួគ៌) ។**

សេចក្ដីវិនិច្ឆ័យក្នុងព្រះគាថាទាំងនោះ បទថា **អនុមញ្ញន្តុ** ប្រែថា ចូរដឹងតាម អធិប្បាយថា ចូរស្ដាប់នូវពាក្យល្អប្រពៃហើយធ្វើតាមឲ្យប្រាកដ ។ ពាក្យថា **សមិតាភោ** ប្រែថា ដែលមកជួបជុំគ្នា ។ បាទព្រះគាថាថា **អរញ្ញេ ភូតភព្យានិ** អធិប្បាយថា ពួកភូតទាំងឡាយ ដែលដល់នូវវ័យដ៏ចម្រើន (ចាស់) និងភាពជាធំនុ៎ះឯងផង យក្ស និងទេវតាកម្លោះទាំងឡាយផងទាំងពួងទាំងអស់នោះឯង នៅក្នុងព្រៃហេមពាន្តនេះ ចូរស្ដាប់នូវពាក្យរបស់អាត្មាភាព ។ នន្ទបណ្ឌិតនោះ ឲ្យនូវសញ្ញាដល់បរិស័ទហើយ ធ្វើនមស្ការដល់ទេវតាទាំងឡាយដែលកើតក្នុងដងព្រៃនោះ ទើបពោលពាក្យនេះថា **នមោកាត្វាន** ។ អ្នកសិក្សាគប្បីជ្រាបសេចក្ដីអធិប្បាយនៃ

ពាក្យនោះដូច្នេះថា ទេវតាទាំងឡាយដ៏ច្រើនដែលជាអ្នក គប្បីមកហើយ ដើម្បីស្តាប់នូវធម្មកថានៃបងប្រុសរបស់ អាត្មាភាពក្នុងថ្ងៃនេះ ខ្ញុំនមស្ការនូវលោកទាំងឡាយ សូម្បី លោកទាំងឡាយក៏ចូរជាមិត្តរបស់ពួកយើង។ នន្ទតាបស នោះ ផ្គងនូវអញ្ជលីចំពោះទេវតាទាំងឡាយហើយ ញុំាង បរិស័ទឲ្យដឹងទើបពោលពាក្យជាដើមថា **ឥសី វក្ខាមិ** ដូច្នេះ ។ ក្នុងបាទព្រះគាថានោះ ពាក្យថា **ឥសី** គឺ នន្ទបណ្ឌិតពោលសំដៅដល់សោណបណ្ឌិត ។ បទថា **សម្មតោ** សេចក្តីថា ធម្មតាបងប្អូនរមែងមានខ្លួន គឺ នាទីស្មើគ្នា ព្រោះហេតុនោះ កោសិយគោត្តនោះ លោក សន្មតថា ខ្ញុំជាដើមដៃស្តាំរបស់លោក ។ សេចក្តីបំភ្លឺថា ព្រោះហេតុនោះ លោកដ៏ចម្រើន គួរតែអត់ទោសដល់ខ្ញុំ ។

បទថា **វីរ** ប្រែថា អ្នកមានព្យាយាម គឺថា មាន សេចក្តីប្រឹងប្រែងដ៏ធំធេង ។ ពាក្យថា **បុញ្ញមិទំ ឋានំ** មានសេចក្តីថា នន្ទបណ្ឌិតពោលថា ឈ្មោះថា ការបម្រើ មាតាបិតានេះ ជាបុណ្យ ជាហេតុជាដំណើរទៅកាន់ឋាន សួគ៌ សូមសោណបណ្ឌិតកុំហាមឃាត់នូវខ្ញុំដែលកំពុងធ្វើ

បុណ្យគឺការបម្រើមាតាបិតានោះអី ។ ពាក្យថា **សត្ថិ-ហោតំ** សេចក្តីថា ព្រោះថា ឈ្មោះថាការបម្រើមាតាបិតានុ៎ះ គឺពួកបណ្ឌិតបានដឹងច្បាស់ហើយ គឺចូលទៅដឹងហើយ បានដឹងច្បាស់លាស់ហើយផង ពោលសរសើរហើយផង ។ មួយបាទគាថាថា **មមេតំ ឧបនិស្សជ** សេចក្តីថា លោកចូរលះ គឺផ្ទេរនូវការទំនុកបម្រុងនេះឲ្យដល់ខ្ញុំម្តង ។ បទថា **ឧដ្ឋានចារិចរិយាយ** ប្រែថា ដោយការខំប្រឹងខ្នះខ្នែងផង ដោយការបម្រើទំនុកបម្រុងផង ។ បទថា **កាតំ** បានសេចក្តីថា លោកបានធ្វើកុសលអស់កាលដ៏អង្វែងហើយ ។ បទថា **បុញ្ញានិ** សេចក្តីថា ឥឡូវនេះ ខ្ញុំជាអ្នកមានប្រាថ្នាដើម្បីធ្វើបុណ្យទាំងឡាយដល់មាតាបិតា ។ ពីរបទថា **មម លោកទោ** សេចក្តីថា នន្ទបណ្ឌិតពោលថា ចូរលោកឲ្យនូវផ្លូវសួគ៌ទេវលោកដល់ខ្ញុំនោះ ព្រោះថា ខ្ញុំបានធ្វើនូវវត្ត គឺការបម្រើចំពោះលោកទាំងពីរនោះ នឹងបាននូវ(សិរី)យសដ៏ប្រមាណមិនបានឰដ៏ទេវលោក លោកចូរជាទាយករបស់ខ្ញុំនោះផងចុះ ។

បទថា **តថេវ** សេចក្តីថា លោកដឹងយ៉ាងណា មនុស្សទាំងឡាយសូម្បីដទៃក៏ដឹងយ៉ាងនោះដែរ តែងមាននៅក្នុងបរិស័ទនេះ ជនទាំងឡាយនោះ តែងពោលនូវចំណែកនៃធម៌ពោលគឺភារៈនៃការគោរព ត្រកូលរៀមច្បងនេះ ក្នុងធម៌មានប្រការផ្សេងៗ ។ សួរថា ដឹងនូវអ្វី ? ឆ្លើយថា ដឹងនូវផ្លូវនៃឋានសួគ៌ ទេវលោក ។ ពាក្យថា **សុខាវហំ** បានដល់ កិរិយានាំមកនូវសេចក្តីសុខដល់មាតាបិតាទាំងឡាយ ដោយការខ្នះខ្នែង និងការបម្រើ ។ ពីរបទថា **តំ មំ** សេចក្តីថា សោណបណ្ឌិតជាបងប្រុសហាមឃាត់នូវខ្ញុំនោះ សូម្បីបានប្រតិបត្តិហើយដោយល្អយ៉ាងនេះ ចាកបុណ្យនោះ ។ ពាក្យថា **អរិយមគ្គាវរោ** សេចក្តីថា សោណបណ្ឌិតនោះ កាលបើហាមឃាត់យ៉ាងនេះ នរៈនេះ ឈ្មោះថាជាអ្នករារាំងនូវផ្លូវនៃទេវលោក ពោលគឺផ្លូវដ៏ប្រសើរ ព្រោះសម្តែងនូវសេចក្តីស្រឡាញ់ពេញចិត្តរបស់ខ្ញុំ ដូច្នេះឯង ។

កាលដែលនន្ទបណ្ឌិតពោលយ៉ាងនេះហើយ ព្រះមហាសត្វកាលញុំាំងជនទាំងពួងឲ្យបានឮ ដោយពាក្យថា

ពាក្យរបស់តាបសនេះ គឺពួកយើងបានស្ដាប់ហើយដែរ តែឥឡូវនេះ ចូរអ្នកទាំងឡាយស្ដាប់ពាក្យ សូម្បីរបស់ខ្ញុំដែរ ទើបពោលតទៅថា ៖

៤៥. សុណន្តុ ភោន្តោ វចនំ
ភាតុរជ្ឈាវរា មម
កុលវំសំ មហារាជ
ពោរាណំ បរិហាបយំ
អធម្មចារី ជេដ្ឋេសុ
និរយំ សោ ឧបបជ្ជតិ ។

៤៦. យេ ច ធម្មស្ស កុសលា
ពោរាណស្ស ទិសំបតិ
ចារិត្តេន ច សម្បន្នា
ន តេ គច្ឆន្តិ ទុគ្គតឹ ។

៤៧. មាតា បិតា ច ភាតា ច
ភគិនី ញាតិពន្ធវា

សព្វេ ជេដ្ឋស្ស តេ ភាភា
ឯវំ ជាជាហិ ភារជ ។

៤៨. អាជិយិត្វា តរុំ ភារំ
ជាវិកោ វិយ ឧស្សហោ
ជម្មញ្ញ ជប្បមដ្ឋាមិ
ជេដ្ឋោ ចស្មិ រថេសភ ។

លោកដ៏ចម្រើនទាំងឡាយ ដែលជាបរិស័ទនៃប្អូនរបស់ខ្ញុំ សូមស្ដាប់ពាក្យខ្ញុំ បពិត្រមហារាជ អ្នកណាមិនប្រព្រឹត្តធម៌ ចំពោះបុគ្គលជាច្បងទាំងឡាយ ញុំាងប្រវេណីពីបុរាណឲ្យសាបសូន្យ អ្នកនោះរមែងទៅកើតក្នុងនរក ។ បពិត្រព្រះអង្គជាម្ចាស់នៃទិស ពួកជនណាឈ្លាសវៃក្នុងធម៌ (ជេដ្ឋាបចាយនធម៌) ជាប្រវេណីអំពីបុរាណ ព្រមទាំងបរិបូណ៌ដោយសណ្ដាប់ធ្នាប់ ពួកជននោះរមែងមិនទៅកាន់ទុគ្គតិទេ ។ បពិត្រព្រះអង្គជាអ្នកទ្រទ្រង់នូវបន្ទុក (ដែន) សូមព្រះអង្គជ្រាបយ៉ាងនេះថា មាតាបិតាបងប្អូនប្រុសស្រី ញាតិ និងផៅពង្សទាំងអស់នោះជាភារៈរបស់កូនច្បង ។ បពិត្រព្រះអង្គជាបុគ្គលប្រសើរលើរថ

**អាត្មាភាពដូចជានាយសំពៅអាចនាំយកនូវភារៈយ៉ាងធ្ងន់ អាត្មាភាពពុំប្រមាទនូវជេដ្ឋាបចាយនធម៌ទេ ព្រោះអាត្មាភាពជាច្បង ។**

អធិប្បាយក្នុងព្រះគាថាទាំងនោះ អ្នកសិក្សាគប្បីជ្រាបដូច្នេះ ៖

បទថា **ភាតុវជ្ជាវរា** សេចក្តីថា លោកដ៏ចម្រើនទាំងឡាយ ជាបរិស័ទនៃប្អូនប្រុសរបស់អាត្មាភាពមកហើយ ទាំងព្រះរាជាទាំងឡាយ សូម្បីទាំងអស់សូមទ្រង់ស្តាប់ពាក្យសូម្បីរបស់អាត្មាភាពសិន ។ ពាក្យថា **បរិហាបយំ** ប្រែថា កាលញុំាងប្រវេណីឲ្យសាបសូន្យទៅ ។ ពាក្យថា **ជេដ្ឋស្ស** បានដល់ ជេដ្ឋាបចាយនធម៌ គឺជាធម្មប្រវេណីនៃការគោរពត្រកូលរៀមច្បង ។ ពាក្យថា **កុសលា** ប្រែថា ឈ្លាសវៃ ។ បទថា **ចារិត្តេន ច** សេចក្តីថា ដល់ព្រមដោយសីលាចារ គឺសណ្តាប់ធ្នាប់ល្អ ។ បទថា **ភារា** សេចក្តីថា ភារកិច្ចទាំងអស់នុ៎ះ ដែលកូនច្បងគប្បីនាំទៅ គឺថាគប្បីគ្រប់គ្រងរក្សា ព្រោះហេតុនោះទើបឈ្មោះថា ជាភារៈនៃកូនច្បងនោះ ។ ពាក្យថា

**ជាវិកោ វិយ** អធិប្បាយថា នាយសំពៅតែងនាំយកនូវភារៈយ៉ាងធ្ងន់ដោយសំពៅ ហើយអត់ធ្មត់ព្យាយាមដើម្បីនាំនូវសំពៅទៅក្នុងកណ្ដាលសមុទ្រ ដោយសុវត្ថិភាពផង មនុស្ស និងទ្រព្យធនទាំងអស់ដែលទៅតាមសំពៅ តែងជាភារៈនៃនាយសំពៅនោះដោយពិតផង យ៉ាងណាមិញ ពួកញាតកាទាំងអស់ក៏ជាភារៈនៃអាត្មាភាពដោយពិត ក៏យ៉ាងនោះដែរ ព្រោះហេតុនោះ អាត្មាភាពហ៊ានប្រឹងប្រែងពុះពារដើម្បីពួកគេ អាត្មាភាពអាចដើម្បីគ្រប់គ្រងរក្សាបានផង អាត្មាភាពមិនប្រមាទនូវជេដ្ឋាបចាយនធម៌នោះផង ម្យ៉ាងទៀត អាត្មាភាពមិនមែនត្រឹមតែជាច្បងនៃពួកជនទាំងអស់នុ៎ះប៉ុណ្ណោះទេ ថែមទាំងជាច្បង សូម្បីនៃសកលលោកផងដែរ ព្រោះហេតុនោះ បានជាអាត្មាភាព សមគួរដើម្បីទំនុកបម្រុងមាតាបិតាជាមួយនឹងនន្ទបណ្ឌិត ។

ព្រះរាជាសូម្បីទាំងអស់អង្គនោះ បានទ្រង់ព្រះសណ្ដាប់ពាក្យនោះហើយ ទ្រង់មានព្រះទ័យរីករាយត្រាស់ថា យើងបានដឹងក្នុងថ្ងៃនេះថា បានឮថាភារៈចិញ្ចឹមមាតាបិតាដ៏សេសជាភារៈរបស់កូនច្បង ដូច្នេះ ក៏ចោលនន្ទបណ្ឌិតនាំគ្នាមកអង្គុយចោមជុំព្រះមហាសត្វ កាល

ស្ងើចសរសើរសោណបណ្ឌិតក៏ត្រាស់ពីរព្រះគាថាថា ៖

៤៩. អធិគម្ហា តមេ ញាណំ
ជាលំវ ជាតវេទតោ
ឯវមេវ នោ ភវំ ធម្មំ
កោសិយោ បវិទំសយិ ។

៥០. យថា ឧទយមាទិច្ចោ
វាសុទេវោ បភង្ករោ
បាណីនំ បវិទំសេតិ
រូបំ កល្យាណបាបកំ
ឯវមេវ នោ ភវំ ធម្មំ
កោសិយោ បវិទំសយិ ។

ពួកយើងបានញាណដូចបុគ្គលបានអណ្តាតភ្លើងអំពីភ្លើងក្នុងទីងងឹត ដោយកោសិយតាបសដ៏ចម្រើន បានផ្ចុះបញ្ចាំងធម៌ដល់ពួកយើងយ៉ាងនេះឯង ។ ព្រះអាទិត្យដែលបំភ្លឺនូវទ្រព្យ ធ្វើពន្លឺកាលរះឡើង តែងផ្ចុះបញ្ចាំងនូវរូបល្អអាក្រក់ ដល់សត្វទាំងឡាយយ៉ាងណា កោសិយៈ

ដ៏ចម្រើន បានផ្លុះបញ្ចាំងនូវធម៌ដល់ពួកយើង ក៏យ៉ាងនោះដែរ ។

បណ្តាបទទាំងនោះ បទថា **អជិតម្ហា** សេចក្តីថា ពួកយើងកាលពីមុនរាប់ពីពេលនេះទៅក្រោយ ប្រព្រឹត្តទៅក្នុងងងឹតដែលបិទបាំងនូវជេដ្ឋាបចាយនធម៌ ក៏មិនបានដឹង (តែ) ថ្ងៃនេះ ពួកយើងបាននូវ ញាណដូចជាគេបានអណ្តាតភ្លើងអំពីភ្លើងដូច្នោះ ។ ពីរបទថា **ឃរមេវ ឆោ** អធិប្បាយថា ភ្លើងដែលគេដុតឲ្យឆេះហើយលើកំពូលភ្នំក្នុងកាលងងឹតសូន្យសុង តែងផ្សាយនូវពន្លឺភ្លឺជះផ្លុះទៅជុំវិញឲ្យឃើញនូវរូបទាំងឡាយបាន មានឧបមាយ៉ាងណា កោសិយគោត្តដ៏ចម្រើន បានបំភ្លឺនូវធម៌ដល់ពួកយើង ក៏មានឧបមេយ្យយ៉ាងនោះដែរ ។ ពាក្យថា **វាសុទេវោ** សេចក្តីថា ព្រះអាទិត្យបង្កើតនូវពន្លឺ បំភ្លឺនូវទ្រព្យ ។

ព្រះមហាសត្វទំលាយសេចក្តីជ្រះថ្លាក្នុងនន្ទបណ្ឌិត ញុំាងព្រះរាជាទាំងឡាយនោះ ដែលមានព្រះទ័យជ្រះថ្លាក្នុងលោក ព្រោះបានឃើញនូវបាដិហារ្យរបស់នន្ទបណ្ឌិត អស់កាលមានប្រមាណប៉ុណ្ណោះ ឲ្យមកកាន់យកនូវកថា

របស់ខ្លួនធ្វើឲ្យព្រះរាជាសូម្បីទាំងអស់ សម្លឹងមកមើលមុខ របស់ខ្លួន ដោយកម្លាំងនៃព្រះញាណដោយប្រការដូច្នេះ ។ គ្រានោះ នន្ទបណ្ឌិតគិតថា បងប្រុសរបស់យើងជាបណ្ឌិត ឆ្លៀវឆ្លាស ជាធម្មកថិក បានបំបែកព្រះរាជាសូម្បីទាំងអស់ នេះឲ្យមកជាបក្សពួករបស់ខ្លួនហើយ លើកទុកតែបង ប្រុស នេះម្នាក់ចេញគ្មានបុគ្គលដទៃណាជាទីពឹងអាស្រ័យ នៃយើងបានទៀតទេ យើងមានតែអង្វរបងប្រុសនេះ ឯង តែម្យ៉ាង ទើបពោលគាថាដូច្នេះ៖

៤១. ឯវំ មេ យាចមានស្ស
អញ្ជលឹ នាវពុជ្ឈថ
តវ បទ្ធចរោ ហេស្សំ
វុដ្ឋិតោ បរិចារកោ ។

**កាលបើខ្ញុំអង្វរយ៉ាងនេះហើយ លោកនៅតែមិន ទទួលអញ្ជលីខ្ញុំនឹងជាអ្នកប្រព្រឹត្តតាមពាក្យ ជាអ្នកប្រឹង បម្រើលោក ។**

សេចក្តីអធិប្បាយនៃព្រះគាថានោះ អ្នកសិក្សាគប្បី ជ្រាបដូចនេះ ៖

ប្រសិនបើ កាលដែលខ្ញុំអង្វរលោកដ៏ចម្រើនយ៉ាងនេះហើយលោកនៅតែមិនអើពើ គឺថាមិនទទួលនូវអញ្ជលីដែលខ្ញុំផ្គងហើយដើម្បីខមាទោសទេ សូមលោកដ៏ចម្រើនបម្រើមាតាបិតាតែម្យ៉ាងចុះ ចំណែកខ្ញុំ នឹងជាអ្នកប្រព្រឹត្តតាមពាក្យគឺធ្វើសេចក្តីខ្វល់ខ្វាយចំពោះលោក ខ្ញុំនឹងក្រោកហើយដោយភាពមិនខ្ជិល ប្រអូសអស់យប់និងថ្ងៃទំនុកបម្រុងបម្រើនូវលោកដ៏ចម្រើនវិញ ។

ក៏តាមប្រក្រតីរបស់ព្រះមហាសត្វ ទោសកំហុសឬពៀរវេរាចំពោះនន្ទបណ្ឌិតមិនមានសោះឡើយ តែកាលដែលលោកពោលនូវពាក្យធ្ងន់ហាក់ប្រកាន់ លោកធ្វើយ៉ាងដូច្នោះដោយអំណាចការសង្កត់សង្កិន ក៏ដើម្បីឲ្យលះបង់ចោលនូវមានះប៉ុណ្ណោះ គ្រានេះ លោកបានស្តាប់ហើយនូវពាក្យរបស់នន្ទបណ្ឌិតនោះ ក៏មានចិត្តត្រេកអរ ញ៉ាំងចិត្តឲ្យជ្រះថ្លាហើយក្នុងនន្ទបណ្ឌិតនោះ ក៏ពោលថា ឥឡូវនេះយើងអត់ទោសឲ្យដល់ឯងផង ឯងនឹងបានដើម្បីទំនុកបម្រុងមាតាបិតាផងចុះ! កាលចង់ប្រកាសគុណនៃនន្ទ-បណ្ឌិតនោះ ក៏ពោលព្រះគាថាដូចតទៅ ៖

### ៥២. អទ្ធា នន្ទ វិជានាសិ

សទ្ធម្មំ សព្ភិ ទេសិតំ
អរិយោ អរិយសមាចារោ
ពាឡ្ហំ ត្វំ មម រុច្ចសិ ។
៤៣. ភវន្តំ វទាមិ ភោតិញ្ច
សុណាថ វចនំ មម
ឆាយំ ភារោ ភារមត្តោ
អហុ មយ្ហំ កុទាចនំ ។
៤៤. តំ មំ ឧបដ្ឋិតំ សន្តំ
មាតាបិតុ សុខាវហំ
នត្ថោ អញ្ញារំ កត្វា
ឧបដ្ឋានាយ យាចតិ ។
៤៥. យោ ចេ ឥច្ឆតិ កាមេន
សន្តានំ ព្រហ្មចារិនំ
នន្ទំ ភោ វទ ឯកោ
កំ នត្ថោ ឧបតិដ្ឋតុ ។

ម្នាលនន្ទ អ្នកស្គាល់ច្បាស់នូវព្រះសទ្ធម្មដែលពួកសប្បុរស សម្តែងហើយមែន អ្នកជាមនុស្សល្អ មានឫកពាល្អ ត្រូវចិត្តយើងហើយ ។ ខ្ញុំសូមនិយាយនឹងបិតាដ៏ចម្រើននិងមាតាដ៏ចម្រើន សូមលោកទាំងឡាយស្តាប់ពាក្យរបស់ខ្ញុំ ភារៈនេះមិនមែនគ្រាន់តែជាភារៈរបស់ខ្ញុំក្នុងកាលម្តង ៗ ទេ នន្ទៈធ្វើនូវខ្ញុំដែលជាអ្នកបម្រើ នាំមកនូវសេចក្តីសុខដល់មាតានិងបិតានោះ ឲ្យជាធំ ហើយសូមដើម្បីការបម្រើដែរបណ្តា (មាតានិងបិតា) ជាព្រហ្មចារី បើលោកណាម្នាក់ចង់បាន សូមលោកទទួលយកនន្ទៈ តាមប្រាថ្នាចុះ តើឲ្យនន្ទៈបម្រើលោកណា ។

បណ្តាបទទាំងនោះ បទថា **អរិយោ** ប្រែថា ជាមនុស្សល្អ ។ បទថា **អរិយសមាចារោ** ប្រែថា ជាអ្នកមានឫកពាល្អ ។ បទថា **ពាឡ្ហំ** សេចក្តីថា ឥឡូវនេះឯងជាទីពេញចិត្តនៃយើងក្រៃលែងហើយ ។ ពាក្យថា **សុណាថ** សេចក្តីថា បពិត្រមាតា បពិត្របិតា សូមលោកទាំងឡាយស្តាប់នូវពាក្យរបស់ខ្ញុំ ។ ពីរបទថា **ណាយំ ភារោ** សេចក្តីថា ភារៈនៃការបម្រើលោកទាំងពីរ

នេះមិនមែនគ្រាន់តែជាភារៈរបស់ខ្ញុំម្តងម្កាលទេ ។ ពីរបទ
ថា **តំ មំ** សេចក្តីថា លោកទាំងឡាយ បានសម្គាល់ហើយ
ថាការទំនុកបម្រុងនោះជាភារៈ របស់ខ្ញុំតែម្នាក់ឯងជាអ្នក
បម្រើលោកបាន ។ ពាក្យថា **ឧបដ្ឋានាយ យាចតិ**
សេចក្តីថា នន្ទបណ្ឌិត សូមខ្ញុំដើម្បីបានបម្រើលោកទាំង
ឡាយ ។ ពីរបទថា **យោ ចេ ឥច្ឆតិ** សេចក្តីថា
ព្រោះថា ខ្ញុំមិនគួរនឹង និយាយថា ឯងចូរបម្រើមាតា
ឬបិតានៃបងចុះ ដូច្នេះទេ តែថា បណ្តាលោកទាំងពីរ
ដែលជាអ្នកស្ងប់ ជាព្រហ្មចារី លោកមួយណាប្រាថ្នា,
ខ្ញុំនឹងប្រាប់នន្ទ លោកទាំងឡាយសូមទទួលនន្ទតាម
សេចក្តីប្រាថ្នារបស់លោកទាំងពីរចុះ, លោកទាំងឡាយ
ពេញចិត្តនន្ទជាប្អូនប្រុសរបស់ខ្ញុំនោះ បណ្តាលោកទាំងពីរ
តើឲ្យនន្ទ នុ៎ះបម្រើលោកណា ព្រោះថា យើងទាំងពីរនាក់
សុទ្ធតែជាបុត្ររបស់លោកទាំងឡាយដូចគ្នា ។

គ្រានោះ មាតានៃព្រះមហាសត្វនោះ ក្រោកចាក
អាសនៈពោលថា នៃសោណបណ្ឌិតកូនម៉ែ ប្អូនប្រុស
របស់កូនព្រាត់ទៅយូរហើយ ម៉ែក៏មិនហ៊ានដើម្បីសូមនូវ

កូននន្ទនោះសូម្បីមកហើយពីទីឆ្ងាយយ៉ាងនេះទេ ព្រោះថាយើងទាំងឡាយអាស្រ័យហើយនូវកូន ប៉ុន្តែ ឥឡូវនេះពួកយើងគឺកូនអនុញ្ញាតហើយ ម៉ែ គួរតែបានឱបនូវកូននន្ទនុ៎ះ ដែលជាព្រហ្មចារីដោយដៃទាំងពីរហើយថើបត្រង់ក្បាល ហើយកាលប្រកាស សេចក្ដីនោះទើបពោលគាថាដូចនេះ ៖

៨៦. តយា តាត អនុញ្ញាតា
សោណ តំ និស្សិតា មយំ
ឧបឃាតុំ លភេ នន្ទំ
មុទ្ធនិ ព្រហ្មចារិនំ ។

**នែសោណៈកូន យើងអាស្រ័យនឹងអ្នក អ្នកអនុញ្ញាតហើយ គួរបានដើម្បីចូលទៅថើបក្បាលនន្ទៈ ជាព្រហ្មចារី ។**

គ្រានោះ ព្រះមហាសត្វក៏តបថា បពិត្រអ្នកម្ដាយបើដូច្នោះ ខ្ញុំអនុញ្ញាត អ្នកមេទៅចុះ ចូរឱបនូវនន្ទ ជាកូនហើយថើបក្បាលញ្រក់ញី ដើម្បីរម្ងាប់សេចក្ដីសោកក្នុងចិត្តរបស់អ្នកមេចុះ ។ នាងក៏ស្ទុះទៅកាន់សំណាក់កូនប្រុសពៅហើយ ឱបនូវនន្ទបណ្ឌិតក្នុងកណ្ដាលបរិស័ទនោះឯង

នាងបើបក្បាលញក់ញី   ដើម្បីរម្ងាប់សេចក្តីសោកក្នុងចិត្ត ហើយរៀបរាប់ប្រាប់ទៅមហាសត្វថា ៖

៥៧. អស្សត្ថស្សេវ តរុណំ
បវាឡំ មាលុតេរិតំ
ចិរស្សំ នន្ទំ ទិស្វាន
ហទយំ មេ បវេធតិ ។

៥៨. យថា សុត្តាបិ សុប្បន្តេ
នន្ទំ បស្សាមិ អាគតំ
ឧទគ្គា សុមនា ហោមិ
នន្ទោ នោ អាគតោ អយំ ។

៥៩. យថា ច បដិពុជ្ឈិត្វា
នន្ទំ បស្សាមិ នាគតំ
ភិយ្យោ អាវិសតិ សោកោ
ទោមនស្សញ្ចនប្បកំ ។

៦០. សាហំ អជ្ជ ចិរស្សំបិ

នដ្ឋំ បស្សាមិ អាគតំ
ភត្តុ ច មយ្ហញ្ច បិយោ
នដ្ឋោ នោ ចារិសី ឃរំ ។

៦១. បិតុ ច នដ្ឋោ សុប្បិយោ
យំ នដ្ឋោ នប្បវសេ ឃរា
លភតុ តាត នដ្ឋោ តំ
មំ នដ្ឋោ ឧបតិដ្ឋតុ ។

ដួងហឫទ័យរបស់ម្តាយរំជួល ព្រោះខានឃើញនន្ទៈអស់កាលយូរហើយ ដូចជាស្លឹកខ្ចីរបស់អស្សត្ថព្រឹក្សដែលត្រូវខ្យល់បក់ ។ វេលាណា ម្តាយដេកលក់យល់សប្តឃើញនន្ទៈមក ក៏មានចិត្តត្រេកអរ មានចិត្តរីករាយ (ដោយគិតថា) នន្ទៈរបស់យើងនេះមកហើយ ។ វេលាណា ម្តាយភ្ញាក់ឡើង មិនឃើញនន្ទៈមកទេ សេចក្តីសោកនិងទោមនស្សជាច្រើន រឹងរឹតតែបណ្តាលឡើង ។ យូរណាស់ហើយ ស្រាប់តែក្នុងថ្ងៃនេះ ម្តាយនោះឃើញនន្ទៈមកដល់ នន្ទៈជាទីស្រឡាញ់នៃស្វាមីរបស់ម្តាយផង នៃម្តាយផង បានចូលមកកាន់ផ្ទះ របស់ពួកយើង ។

**នន្ទៈជាទីស្រឡាញ់ក្រៃលែងរបស់បិតាកុំឲ្យនន្ទៈទៅប្រាស ចេញអំពីផ្ទះ នែកូន ឯនន្ទៈ (ចង់បានអ្នកណា) ចូរបាន អ្នកនោះចុះ នន្ទៈចូរបម្រើនូវអញចុះ ។**

ជំនុំបទទាំងនោះ បទថា **មាលុតេរិតំ** សេចក្ដីថា មាតារបស់ព្រះមហាសត្វពោលថា ត្រួយនៃអស្សត្ថព្រឹក្ស (ដើមពោធិ៍) ដែលត្រូវខ្យល់បក់មកប៉ះតែងតែរញ្ជួយញ័រ យ៉ាងណាមិញ ថ្ងៃនេះ ដួងហឫទ័យរបស់ម្ដាយក៏រំជួល ព្រោះបានឃើញកូននន្ទ ដែលព្រាត់ទៅអស់កាលដ៏យូរ យ៉ាងនេះ ក៏យ៉ាងនោះដែរ ។ បទថា **សុត្តា** សេចក្ដីថា នែសោណៈកូន សូម្បីម្ដាយដេកលក់ម្ដាយយល់សប្ដ ឃើញកូននន្ទមកក្នុងសុបិន ក្នុងកាលណា ក្នុងកាលនោះ ក៏ម្ដាយសប្បាយរីករាយដែរ ។ បទថា **ភត្តុ ច** សេចក្ដីថា ជាទីស្រឡាញ់នៃស្វាមីរបស់ម្ដាយផង នៃម្ដាយផង ។ បាទគាថាថា **ឯត្វោ ឯោ ចាវិសី ឃរំ** សេចក្ដីថា នែកូន! កូននន្ទរបស់ម្ដាយ ចូរបានចូលមកកាន់ បណ្ណសាលាចុះ ។ សព្ទថា **យំ** មានសេចក្ដីថា នន្ទជា ទីស្រឡាញ់ក្រៃលែង សូម្បីនៃបិតា ដោយប្រការណា នន្ទ

មិនគប្បីប្រាសចេញចាកផ្ទះនេះម្តងទៀត ដោយប្រការនោះ ។ ពីរបទថា **ឥច្ឆោ តំ** សេចក្តីថា នៃកូន! នន្ទចង់បានអ្នកណា ចូរបានអ្នកនោះចុះ។ ពីរពាក្យថា **មំ ឥច្ឆោ** គឺថា នៃសោណៈកូន ឯងចូរបម្រើបិតារបស់ឯងចុះ ឲ្យនន្ទបម្រើម្តាយវិញ ។

## សោណបណ្ឌិតបរិយាយគុណមាតា

ព្រះមហាសត្វ ទទួលតាមពាក្យម្តាយថា ចូរយ៉ាងហ្នឹងចុះ ហើយឲ្យឱវាទទៅនន្ទបណ្ឌិតថា នៃនន្ទ ចំណែកជាច្បងគឺប្អូនបានហើយ ធម្មតាម្តាយមានគុណដែលគេធ្វើបានដោយលំបាក ចូរប្អូនកុំប្រមាទទំនុកបម្រុងគាត់ចុះ ហើយកាលប្រកាស នូវគុណនៃមាតាបានពោលពីរគាថាដូចតទៅ ៖

៦២. **អនុកម្បិកា បតិដ្ឋា ច**
**បុព្វេ រសទទី ច នោ**
**មគ្គោ សគ្គស្ស លោកស្ស**
**មាតា តំ វរតេ ឥសេ ។**

៦៣. បុព្វេ រសទទី គោត្តី
មាតា បុញ្ញូបសញ្ហិតា
មគ្គោ សគ្គស្ស លោកស្ស
មាតា តំ វរតេ ឥសេ ។

ម្នាលឥសី មាតាជាអ្នកឈឺឆ្អាល ជាទីពឹង ជាអ្នកឲ្យរស (ទឹកក្សីរ) ដល់ពួកយើងជាមុន ជាផ្លូវនៃសួគ៌ទេវលោក ចង់បានអ្នក ។ មាតាជាអ្នកឲ្យរសជាមុន ជាអ្នកគ្រប់គ្រង ដែលយើងចូលទៅអាស្រ័យបុណ្យ ជាផ្លូវនៃសួគ៌ទេវលោក ម្នាលឥសី មាតាចង់បានអ្នក ។

បណ្ដាបទទាំងនោះ បទថា អង្កុកាម្បិកា បានដល់ មានហ្ឫទ័យទន់ភ្លន់ ។ ពីរបទថា បុព្វេ រសទទី សេចក្ដីថា មាតាជាអ្នកឲ្យនូវរសពោលគឺទឹកក្សីររបស់ខ្លួនមុនជាងគេមែនពិត។ ពីរបទថា មាតា តំ សេចក្ដីថា ម្ដាយរបស់ខ្ញុំមិនត្រូវការខ្ញុំ គាត់ចង់បានអ្នក ។ បទថា គោត្តី ប្រែថា អ្នកគ្រប់គ្រងរក្សា ។ ពាក្យថា បុញ្ញូបសញ្ហិតា សេចក្ដីថា ជាអ្នកដែលយើងចូលទៅ

អាស្រ័យបុណ្យ គឺថាជាអ្នកឲ្យបុណ្យ ។

ព្រះមហាសត្វបានពោលនូវគុណរបស់ម្ដាយ ដោយគាថាទាំងឡាយពីរយ៉ាងនេះហើយ កាលដែលមាតានោះត្រឡប់មកអង្គុយលើអាសនៈវិញ ក៏ពោលថា នែនន្ទ ប្អូនបាននូវមាតា ជាអ្នកធ្វើនូវការដែលគេកម្រនឹងធ្វើបាន មាតាចិញ្ចឹមបីបាច់យើងទាំងពីរ ឲ្យធំចម្រើនក៏លំបាកណាស់ ឥឡូវនេះ ប្អូនចូរកុំប្រមាទ ថែទាំគាត់ចុះ កុំឲ្យលោកពិសាផលាផលនៅខ្ចីដែលមិនទាន់ទុំល្អ មានរសមិនផ្អែមឆ្ងាញ់ទៀតឡើយ ហើយកាលនឹងប្រកាសនូវអំពើដែលមាតាធ្វើហើយដោយលំបាក ក្នុងកណ្ដាលបរិស័ទនោះឯង ទើបពោលគាថាទាំងនេះ ៖

៦៨. អាកង្ខមានា បុត្តផលំ
ទេវតាយ នមស្សតិ
នក្ខត្តានិ ច បុច្ឆតិ
ឧតុសំវច្ឆរានិ ច ។

៦៩. តស្សា ឧតុសិ ន្ហាតាយ
ហោតិ គព្ភស្ស វក្កមោ

តេន លោហឡ្ឃិនី ហោតិ
សុហជា តេន វុច្ចតិ ។
៦៦. សំវច្ឆរំ វា ឩនំ វា
បរិហរិត្វា វិជាយតិ
តេន សា ជនយន្តីតិ
ជនេត្តី តេន វុច្ចតិ ។
៦៧. ថនក្ខីរេន គីតេន
អង្គចាវុរណេន ច
រោទន្តំ បុត្តំ តោសេតិ
តោសេន្តី តេន វុច្ចតិ ។
៦៨. តតោ វាតាតបេ ឃោរេ
មម្មំ កត្វា ឧទិក្ខតិ
ទារកំ អប្បជានន្តំ
ចោសេន្តី តេន វុច្ចតិ ។
៦៩. យញ្ច មាតុជនំ ហោតិ

យញ្ច ហោតិ បិតុទ្ធនំ
ឧភយម្បេតស្ស គោបេតិ
អបិ បុត្តស្ស ណោ សិយា ។
៧០. ឯវំ បុត្ត អធុំ បុត្ត
ឥតិ មាតា វិហញ្ញតិ
បមត្តំ បរឃរេសុ
និស្សិរេ បត្តយោព្វនេ
សាយំ បុត្តំ អឃាយន្តំ
ឥតិ មាតា វិហញ្ញតិ ។
៧១. ឯវំ កិច្ឆាភតោ ចោសោ
មាតុ អបរិចារកោ
មាតរិ មិច្ឆា ចរិត្វាន
និរយំ សោបបជ្ជតិ ។
៧២. ឯវំ កិច្ឆាភតោ ចោសោ
បិតុ អបរិចារកោ

បិតរិ មិច្ឆា ចរិត្វាន
និរយំ សោបបជ្ជតិ ។

៧៣. ជនម្បិ ជនកាមានំ
នស្សុតិ ឥតិ មេ សុតំ
មាតរំ អបរិចរិត្វាន
កិច្ចំ វា សោ និគច្ឆតិ ។

៧៤. ជនាបិ ជនកាមានំ
នស្សុតិ ឥតិ មេ សុតំ
បិតរំ អបរិចរិត្វាន
កិច្ចំ វា សោ និគច្ឆតិ ។

៧៥. អានន្ទោ ច បមោទោ ច
សទា ហសិតកីឡិតំ
មាតរំ បរិចរិត្វាន
លព្ភមេតំ វិជានតោ ។

៧៦. អានន្ទោ ច បមោទោ ច

សភា ហសិតកីឡិតំ
បិតរំ បរិចរិត្វាន
លព្ភមេតំ វិជានតោ ។
៧៧. ទានញ្ច បិយវាចា ច
អត្ថចរិយា ច យា ឥធ
សមានត្តតា ច ធម្មេសុ
តត្ថ តត្ថ យថារហំ ។
ឯតេ ខោ សង្គហា លោកេ
រថស្សាណីយាវ យ តោ
៧៨. ឯតេ ច សង្គហា នាស្សុ
ន មាតា បុត្តការណា
លភេថ មានំ បូជំ វា
បិតា វា បុត្តការណា ។
៧៩. យស្មា ច សង្គហា ឯតេ
សមវេក្ខន្តិ បណ្ឌិតា

តស្មា មហត្តំ បប្បោន្តិ
បាសំសា ច ភវន្តិ តេ ។

៨០. ព្រហ្មាតិ មាតាបិតរោ
បុព្វាចរិយាតិ វុច្ចរេ
អាហុនេយ្យា ច បុត្តានំ
បជាយ អនុកម្បកា ។

៨១. តស្មា ហិ តេ នមស្សេយ្យ
សក្ករេយ្យ ច បណ្ឌិតោ
អន្នេន អថោ បានេន
វត្ថេន សយនេន ច
ឧច្ឆាទនេន ន្ហានេន
បាទានំ ធោវនេន ច ។

៨២. តាយ នំ បារិចរិយាយ
មាតាបិតូសុ បណ្ឌិតា
ឥធេវ នំ បសំសន្តិ

បេច្ច សគ្គេ បមោទតីតិ ។

មាតាកាលប្រាថ្នាចង់បានផ្លែគឺកូន រមែងនមស្ការទេវតាសួរនក្ខត្តឫក្សទាំងឡាយផង សួររដូវ និងឆ្នាំទាំងឡាយផង ។ កាលមាតានោះ មានរដូវលាងស្អាតហើយ សត្វក៏ចុះមកកាន់គភ៌ស៊ប់ មាតាជាស្ត្រីមានសេចក្តីចាញ់ផ្ទៃដោយហេតុនោះ ព្រោះហេតុនោះ បានជាបណ្ឌិតហៅថា សុហទា (មានដួងហ្ឫទ័យល្អ) ។ មាតារក្សា (ផ្ទៃ) អស់មួយឆ្នាំ ឬថយពីមួយឆ្នាំ ហើយប្រសូតបុត្រមក ព្រោះហេតុនោះ បានជាបណ្ឌិតហៅមាតានោះថា ជនយន្តី ផង ជនេត្តី ផង (អ្នកបង្កើតកូន) ។ មាតាញុំាងកូនដែលកំពុងយំឲ្យត្រេកអរ ដោយទឹកក្សីរផង ដោយការបំពេរផង ដោយការឱបក្រសោបផង ព្រោះហេតុនោះ បានជាបណ្ឌិតហៅថា តោសេន្តី (អ្នកញុំាងកូនឲ្យត្រេកអរ) ។ តពីនោះមក មាតាធ្វើនូវសេចក្តីស្រឡាញ់រាប់អាន ហើយក្រឡេកមើលទារក ដែលនៅពុំទាន់ដឹងក្តីក្នុងទីមានខ្យល់និងកំដៅថ្ងៃដ៏ពន្លឹក ព្រោះហេតុនោះ បានជាបណ្ឌិតហៅថា បោសេន្តី (អ្នកចិញ្ចឹមកូន) ។ ទ្រព្យណាខាងមាតាផង ទ្រព្យណាខាងបិតាផង មាតា

ក៏គ្រប់គ្រងទ្រព្យទាំងពីរចំណែកដើម្បីកូននោះ (ដោយបំណងថាទ្រព្យនេះ) ត្រូវមានដល់កូនរបស់យើង ។ មាតារមែងលំបាកដោយការបង្ហាត់បង្រៀនកូន ដូច្នេះថា ម្នាលកូន (ឯងចូរកុំប្រមាថក្នុងរាជត្រកូលជាដើម) យ៉ាងនេះ ម្នាលកូន (ឯងចូរធ្វើការ) ឯណោះ ។ កាលបើកូនមានវ័យចម្រើនឡើងហើយ មាតា (បានដឹង) កូននោះប្រមាថក្នុងប្រពន្ធអ្នកដទៃក្នុងពេលអធ្រាត្រ ហើយមិនមកក្នុងវេលាល្ងាច ក៏រមែងលំបាកចិត្តដូច្នេះ ។ សត្វដែលមាតា ចិញ្ចឹមដោយត្រដាបត្រដួសយ៉ាងនេះ ហើយមិនបម្រើមាតា ប្រព្រឹត្តខុសក្នុងមាតានោះតែងទៅកើតក្នុងនរក ។ សត្វដែលបិតាចិញ្ចឹមដោយត្រដាបត្រដួសយ៉ាងនេះ ហើយមិនបម្រើបិតា ប្រព្រឹត្តខុសក្នុងបិតានោះ តែងទៅកើតក្នុងនរក ។ យើងបានឮមកថា សូម្បីតែទ្រព្យរបស់កូនអ្នកចង់បានទ្រព្យ តែងវិនាសទៅវិញ ឬកូននោះរមែងក្រីក្រលំបាកព្រោះមិនបម្រើមាតា ។ យើងបានឮមកថា សូម្បីតែទ្រព្យរបស់កូនដែលចង់បានទ្រព្យតែងវិនាសទៅវិញ ឬកូននោះរមែងក្រីក្រលំបាកព្រោះមិនបម្រើបិតា។ បណ្ឌិតបម្រើមាតា គប្បីបាននូវ

សុខន្ទុំៈ គឺសេចក្ដីត្រេកអររីករាយ ការសើចលេងសព្វៗ កាល។ បណ្ឌិតបម្រើបិតា គប្បីបាននូវសុខន្ទុំៈ គឺ សេចក្ដីត្រេកអររីករាយ ការសើចលេងសព្វៗកាល។ ទាន ១ វាចាជាទីស្រឡាញ់ ១ ការប្រព្រឹត្តិជាប្រយោជន៍ក្នុង លោកនេះ១ ភាពនៃបុគ្គលមានខ្លួនប្រព្រឹត្តស្មើ ក្នុង ជេដ្ឋាបចាយនធម៌នោះៗតាមសមគួរ១ ។ សង្គហធម៌ទាំង ៤ ន្ទុំៈឯង រមែងប្រព្រឹត្តទៅក្នុងលោក ដូចជាភ្លៅ នៃកង់រថដែលវិលទៅ បើសង្គហធម៌ទាំងន្ទុំៈមិនមានទេ មាតាមិនត្រូវបាននូវសេចក្ដីរាប់អាននិងការបូជា ព្រោះ ហេតុនៃកូន ទាំងបិតាក៏មិនត្រូវបាននូវសេចក្ដីរាប់អាន និងការបូជា ព្រោះហេតុនៃកូន ។ ពួកបណ្ឌិតរមែងឃើញ ដោយល្អនូវសង្គហធម៌ទាំងន្ទុំៈ ព្រោះហេតុនោះ បណ្ឌិត ទាំងនោះរមែងដល់នូវភាពជាធំ ទាំងជាអ្នកគួរសរសើរ ។ មាតាបិតាជាអ្នកអនុគ្រោះដល់ពួកសត្វគឺ បុត្រ បណ្ឌិត ហៅថា ព្រហ្មផង បុព្វាចារ្យផង អាហុនេយ្យៈផង របស់កូនទាំងឡាយ ។ ព្រោះហេតុនោះ បណ្ឌិតគប្បី នមស្ការ ធ្វើសក្ការៈចំពោះមាតាបិតានោះដោយបាយ ទឹក សំពត់ ទីដេក គ្រឿងអប់ ដោយការផ្ងូតទឹក និងការលាង

**ដើង ។ បណ្ឌិតទាំងឡាយ រមែងសរសើរនូវបុគ្គលនោះ ព្រោះតែការបម្រើ ចំពោះមាតាបិតានោះ លុះបុគ្គលនោះ លះលោកនេះទៅ រមែងរីករាយក្នុងឋានសួគ៌ ។**

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាទាំងនោះដូចតទៅនេះ ៖

បទថា **បុត្តផលំ** បានដល់ ផ្លែ ពោលគឺកូន ។ បាទព្រះគាថាថា **ទេវតាយ នមស្សតិ** សេចក្ដីថា មាតាតែងបួងសួងសុំដល់ទេវតាយ៉ាងនេះថា សូមឲ្យកូនចូលមកកើតក្នុងផ្ទៃរបស់ខ្ញុំ ។ បទថា **បុច្ឆតិ** សេចក្ដីថា មាតាតែងសួរនូវនក្ខត្តឫក្សទាំងឡាយយ៉ាងនេះថា កូនដែលកើតដោយនក្ខត្តឫក្សដូចម្ដេច ទើបមានអាយុវែង កើតដោយនក្ខត្តឫក្សដូចម្ដេចមានអាយុខ្លី ។ បាទគាថាថា **ឧតុសំវច្ឆរានិ ច** សេចក្ដីថា មាតាតែងសួរនូវរដូវ និងឆ្នាំទាំងឡាយយ៉ាងនេះថា បណ្ដារដូវទាំង ៦ កូនដែលកើតក្នុងរដូវណា ទើបមានអាយុវែង កើតក្នុងរដូវណាមានអាយុខ្លី ឬថា កូនកើតនៅពេលម្ដាយមានអាយុប៉ុន្មានទើបមានអាយុវែង (មានសុខភាពល្អ) ម្ដាយមានអាយុប៉ុន្មានមានអាយុខ្លី ។ ពីរបទថា **ឧតុសិ ន្ហាតាយ**

សេចក្តីថា កាលដែលផ្កាគឺរដូវកើតឡើងហើយលាងស្អាតហើយ ។ ពាក្យថា **វត្តោ មោ** សេចក្តីថា សត្វចុះ កាន់គភ៌ព្រោះការប្រជុំគ្នាស្រេចនៃហេតុបីយ៉ាង[១០] គឺថា មានគភ៌តាំងស៊ប់នៅក្នុងផ្ទៃ ។ បទថា **តេឆ** សេចក្តីថា មាតានោះ

---

[១០] សុត្តន្ត. មជ្ឈិមនិកាយ មូលបណ្ណាសកៈ ភាគ ២២ ទំព័រ ១៨០ ព្រះមានព្រះភាគត្រាស់ថា៖

ម្នាលភិក្ខុទាំងឡាយ កិរិយាចុះចាប់បដិសន្ធិ របស់សត្វដែលកើតក្នុងផ្ទៃ ព្រោះប្រជុំហេតុ ៣ ប្រការ ។ល។ ម្នាលភិក្ខុទាំងឡាយ លុះតែកាលណាមាតាបិតាមកប្រជុំគ្នាផង មាតាជាស្ត្រីមានរដូវផង សត្វដែលគួរកើតក៏មានប្រាកដក្នុងឱកាសនោះផង លុះប្រជុំហេតុទាំង៣ ប្រការនេះឯង ទើបសត្វចុះចាប់បដិសន្ធិក្នុងផ្ទៃនៃមាតាបាន។ ម្នាលភិក្ខុទាំងឡាយ មាតាពគភ៌នោះដោយផ្ទៃ អស់ខែ ៩ ឬខែ ១០ ដោយសេចក្តីសង្ស័យ (ក្នុងជីវិត គឺសង្ស័យក្នុងពេលប្រសូតកូនថា អាត្មាអញមានរោគ ឬកូនអាត្មាអញ មានរោគ) ជាច្រើន ម្នាលភិក្ខុទាំងឡាយ លុះកន្លងខែ ៩ ឬខែ ១០ ទៅ មាតាក៏ប្រសូតគភ៌នោះដូចជាភារៈធ្ងន់ដោយសេចក្តីសង្ស័យជាច្រើន កាលបើគភ៌ដូចជាភារៈដ៏ធ្ងន់នោះប្រសូតរួចហើយ ក៏ចិញ្ចឹមដោយឈាម (គឺទឹកដោះ) របស់ខ្លួន ។ ម្នាលភិក្ខុទាំងឡាយ ទឹកដោះរបស់មាតាណា ដែលតថាគតពោលហើយ ក្នុងអរិយវិន័យ ទឹកដោះនុ៎ះគឺឈាមហ្នឹងឯង ។

ជាស្ត្រីមានសេចក្តីចាញ់ផ្ទៃដោយគភ៌នោះ ។ បទថា **តេន** ដោយអត្ថថា គ្រានោះ កាលដែលមានសត្វចុះមកចាប់កំណើតក្នុងផ្ទៃនៃម្តាយហើយ សេចក្តីស្រឡាញ់ក៏កើតឡើង ព្រោះហេតុនោះ បណ្ឌិតទើបហៅមាតាថា **សុហទា** មានហឫទ័យល្អ ។ (មួយទៀត) បទថា **តេន** មានសេចក្តីថា ព្រោះហេតុនោះ បណ្ឌិតហៅមាតានោះថា **ជនយន្តី** ផង **ជនេត្តី** ផង គឺអ្នកបង្កើតកូន ។

ពាក្យថា **អង្គចារុរណោន ច** សេចក្តីថា ដោយការឱបក្រសោប គឺឱបកាយនោះឯង គឺថា មាតាផ្តេកកូនត្រង់ចន្លោះស្តនហើយផ្សាយនូវសរីរសម្ផស្សសព្វទួទៅ ។ បទថា **តោសេន្តី** សេចក្តីថា ញ៉ាំងកូនឲ្យចាំទុក ឲ្យរីករាយ ។ បាទព្រះគាថាថា **មម្មំ កាត្វា ឧជិក្ខតិ** សេចក្តីថា ម្តាយធ្វើនូវសេចក្តី ស្រឡាញ់រាប់អានយ៉ាងមាំយ៉ាងនេះថា ខ្យល់តែងបក់ទៅលើកូនរបស់យើង កម្តៅថ្ងៃតែងចែងចាំងទៅលើកូនរបស់យើង ហើយសម្លឹងមើលដោយហឫទ័យដ៏ស្រឡាញ់ស្និទ្ធ ។ ពាក្យថា **ឧភយមេ្ប-**

**តស្ស** សេចក្តីថា មាតានោះមិនបង្ហាញទ្រព្យនុ៎ះ សូម្បីទាំងពីរចំណែកប្រាប់ដល់បុគ្គលដទៃណាឡើយ តែគ្រប់គ្រង រក្សាក្នុងទីដ៏មានសុវត្ថិភាពទាំងឡាយមានបន្ទប់ដ៏ប្រសើរជាដើម ទុកដើម្បីប្រយោជន៍ដល់កូននុ៎ះ ។ បាទគាថាថា **ឯវំ បុត្ត អទុំ បុត្ត** សេចក្តីថា មាតាតែងល្វិតល្វៃតែងលំបាកបង្ហាត់បង្រៀនកូនដូច្នេះថា នៃកូនសម្លាញ់មាសម្តាយ កូនចូរកុំប្រមាថក្នុងត្រកូលទាំងឡាយមានត្រកូលស្តេចជាដើមយ៉ាងនេះផង កូនចូរកុំធ្វើនូវអំពើឯណោះផង ។ បទថា **បត្តយោព្វនេ** សេចក្តីថា កាលកូនធំពេញវ័យហើយ ប្រមាថក្នុងកូន ប្រពន្ធអ្នកដទៃក្នុងពេលអធ្រាត្រ ព្រោះដឹងថាកូននោះមិនត្រឡប់មកវិញក្នុងពេលព្រលប់ ម្តាយមាននេត្រាទាំងគូទទឹកជោកដោយទឹកភ្នែក នៅទន្ទឹងចាំមើលផ្លូវកូនទាំងខ្វល់ខ្វាយលំបាកចិត្តឆ្អិតទ្រូង ។

ពីរបទថា **ភិដ្ឋា ភតោ** សេចក្តីថា ដែលចិញ្ចឹមថែរក្សាដោយត្រដាបត្រដួស ។ ពីរបទថា **មិច្ឆា ចរិត្វាន** បានន័យថា មិនទំនុកបម្រុងបម្រើម្តាយ ។ បទថា

**ធនម្បិ** ប្រែថា សូម្បីតែទ្រព្យ ពាក្យបាលីនេះឯង បានប្រាកដ តែកន្លែងខ្លះបាលីជា **ធនាបិ** ។ ពាក្យនេះជាពាក្យដែលសោណបណ្ឌិត ពោលហើយថា យើងបានឮមកថា សូម្បីទ្រព្យដែលប្រុងនឹងកើតឡើងហើយដល់កូនដែលចង់បានទ្រព្យ ក៏នឹងវិនាសបាត់ទៅវិញបាន ព្រោះតែកូនដែលមិនចិញ្ចឹមម្តាយ ។ ពាក្យថា **ភិជ្ជំ វា សោ** សេចក្តីថា ទ្រព្យរបស់កូននោះតែងវិនាសទៅវិញ ឬបុរស(ជាកូន)នោះរមែងប្រសព្វនូវទុក្ខលំបាកក្រៃក្រ ។ ពាក្យថា **លព្ភមេតំ** នុ៎ះ មានអធិប្បាយថា បណ្ឌិតកាលបម្រើនូវមាតា គប្បីបាននូវសេចក្តីសុខមានការ រីករាយទូទៅជាដើម ក្នុងលោកនេះផង ក្នុងបរលោកផង គឺថាអាចដើម្បីនឹងបានពិតដោយការបម្រើមាតា ប្រាកដដូចនោះ ។

ពាក្យថា **ទានញ្ច** បានដល់ ទានដែលត្រូវជូនដល់មាតាបិតា,គប្បីពោលវាចាជាទីស្រឡាញ់ទៅរកមាតាបិតា, គប្បីប្រព្រឹត្តនូវប្រយោជន៍ ដោយការជួយសម្រាលការងារដែលកើតមានឡើងដល់មាតាបិតា។ ពាក្យថា **ធម្មេសុ**

សេចក្តីថា ភាពនៃបុគ្គលមានខ្លួនប្រព្រឹត្តស្មើ ត្រូវតែធ្វើក្នុង ជេដ្ឋាបចាយនធម៌ទាំងឡាយ ដោយការថ្វាយបង្គំជាដើម ទោះបីត្រង់កណ្តាលបរិស័ទនោះៗ ឬនៅទីស្ងាត់កំបាំង ក៏ដោយ ឬមិនធ្វើការថ្វាយបង្គំក្នុងទីស្ងាត់ ហើយមិនធ្វើ ក្នុងបរិស័ទនោះទេ គឺគប្បីជាអ្នកស្មើក្នុងទីទាំងពួងមែន ពិត ។ បាទគាថា ថា **ឯតេ ច សង្គហា នាស្សុ** សេចក្តីថា ប្រសិនបើ សង្គហធម៌ទាំង ៤ នេះ មិនគប្បី មាននៅ ។ បទថា **សមវេក្ខន្តិ** សេចក្តីថា ពួកបណ្ឌិត តែងឃើញដោយន័យ គឺថាដោយហេតុដ៏ល្អ ។ បទថា **មហត្តំ** ប្រែថា នូវភាពជាអ្នកប្រសើរ ។ បណ្ឌិតហៅថា **ព្រហ្មា** សេចក្តីថា មាតាបិតាស្មើដោយព្រហ្ម ដ៏ឧត្តម ដ៏ប្រសើរ នៃកូនទាំងឡាយ ។ ពាក្យថា **បុព្វាចារ្យ** គឺជា អាចារ្យដំបូង។ ពាក្យថា **អាហុនេយ្យ** គឺជាបដិគ្គាហកៈ ជាអ្នកទទួលដ៏សមគួរ គឺសមគួរបំផុតសម្រាប់ទទួលនូវ សក្ការបូជាណាមួយ ។ ពីរបទថា **អន្នេន អថោ** សេចក្តីថា សេចក្តីត្រូវការដោយបាយហ្នឹងផង ទឹកផង ។

បទថា **បេច្ច** គឺកាលធ្វើកាលកិរិយាទៅ គឺថាក្នុងកាលជាទីបំផុតទៅអំពីលោកនេះ រមែងរីករាយក្នុងឋានសួគ៌ដូច្នេះឯង ។

ព្រះមហាសត្វបញ្ចប់នូវធម្មទេសនា ដោយប្រការយ៉ាងនេះ ហាក់បីដូចជាកាលបង្វិលនូវភ្នំសុនេរុ ដូច្នោះ ។ ព្រះរាជាសូម្បីទាំងអស់នោះផង កងទ័ពទាំងឡាយផង បានស្តាប់ពាក្យនោះហើយ ក៏មានចិត្តត្រេកអរជ្រះថ្លា ។ គ្រានោះ សោណបណ្ឌិតបានញុំាំងជនទាំងឡាយនោះក្នុងសីលទាំង ៥ ហើយទូន្មានថា លោកទាំងឡាយ ចូរកុំប្រមាទក្នុងការឲ្យទានទាំងឡាយជាដើមចុះ ហើយបញ្ជូនពួកគេឲ្យត្រឡប់វិញហើយ ព្រះរាជាសូម្បីទាំងអស់សោយរាជ្យប្រកបដោយធម៌ កាលសោយព្រះទិវង្គត ក៏បានទៅបំពេញទេវនគរ ។ ចំណែកឯ សោណបណ្ឌិត និងនន្ទបណ្ឌិត បម្រើមាតាបិតាដរាបដល់អស់អាយុកាលបានទៅកាន់ព្រហ្មលោកហើយ ។

## ព្រះសាស្តាទ្រង់ប្រជុំជាតក

**សត្ថា** ព្រះបរមសាស្តា ទ្រង់នាំនូវធម្មទេសនានេះ

មក ហើយទ្រង់ប្រកាសនូវសច្ចៈទាំងឡាយ ទើបទ្រង់ប្រជុំជាតក ក្នុងកាលជាទីបំផុតនៃសច្ចធម៌ មាតុបោសកភិក្ខុបានតាំងនៅក្នុងសោតាបត្តិផល ។

**តទា មាតាបិតរោ មហារាជកុលានិ អហេសុំ នន្ទបណ្ឌិតោ អានន្ទោ មនោជរាជា សារីបុត្តោ ឯកសតរាជានោ អសីតិមហាថេរា ចេវ អញ្ញតរថេរា ច ចតុវីសតិ អក្ខោភិនិយោ ពុទ្ធបរិសា សោណបណ្ឌិតោ បន អហមេវ អហោសិ ។**

មាតាបិតា (នៃតថាគត) ក្នុងកាលណោះ បានមកជាមហារាជត្រកូល (ព្រះស្រីសុទ្ធោទនៈ និងមហាមាយា) នន្ទបណ្ឌិត បានមកជាព្រះអានន្ទ ព្រះបាទមនោជ បានជាព្រះសារីបុត្រ ស្តេច ១០១ អង្គ បានមកជាអសីតិមហាថេរហ្នឹងផង ព្រះថេរៈទាំងឡាយដទៃទៀតផង កងទ័ព ២៤ អក្ខោភិនី បានមកជាពុទ្ធបរិស័ទ (ពេលនេះ) ឯសោណបណ្ឌិតបានមក ជាអង្គអញតថាគតហ្នឹងឯង ។

ពណ៌នាសោណនន្ទជាតក ទី ២ ចប់ ៕

# អវសានកាព្យ

១. អវសានកាព្យាលាគ្នាគ្រាចប់
ម្រាមខ្ញុំទាំងដប់ដាក់ដល់សិរសី
បង្គំដល់គុណនៃព្រះជិនស្រី
ទ្រង់ជាអធិបតីនៃត្រៃលោកា ។
២. បង្គំរំឭកនឹកភ្នករកធម៌
ប្រសើរបវរទាំងពីរប្រការ
គឺព្រះបរិយត្តិវិសុទ្ធិថ្លៃថ្លា
និងលោកុត្តរាទាំងប្រាំបួនអង្គ ។
៣. បង្គំភ្ជុំម្រាមក្នុងនាមកូនប្រុស
ផ្គងគោរពឆ្ពោះអស់គម្ដែងសង្ឃ
ទាំងពីរប្រការប្រពៃផ្ទូរផង់
អរិយវង្ស និងអង្គសម្មតិ ។
៤. បង្គំនឹកគុណមាតាបិតា
ឧបជ្ឈាយាចារ្យត្រាប្រោសញត្តិ
បង្ហាត់បង្រៀនឈានមានសតិ
ស្មារតីភ្ញាវភ្ញាក់ដាក់ចិត្តជិតនៅ ។
៥. ម្យ៉ាងខ្ញុំរំឭកនឹកដល់ពួកញាតិ

ដែលបានបែកឃ្លាតនាខែផុតទៅ
ពីអង្គសក្កៈដាក់ចារសំដៅ
កាព្យពិតជិតនៅកូនចៅរាល់គ្នា ។

៦. គ្រានេះ គ្រាថ្មីកវីចាប់ចារ
ពីគុណមាតាបិតាស្ងួនភ្ងា
ដែលមានរ៉ាយរ៉ាប់ស្រេចស្រាប់នាមា
ក្នុងរឿងពណ៌នានាខាងដើមស្រាប់ ។

៧. តែគ្រាចុងក្រោយបង្ហើយសំណេរ
ខ្ញុំចាប់សរសេរកាព្យមេសាសព្ទ
រៀបរាប់រឿងរ៉ាវឃ្លាខ្លីស្រួលស្ដាប់
រំឭកតឿនប្រាប់ចាប់ចិត្តជាថ្មី ។ 06/24/15

៨. សោណនន្ទជាតក ដោយនាម
មួយជាព្រះរៀម មួយអនុជស្ដី
រ៉ាយរ៉ាប់ប្រាប់គុណប្រសើរឥតបី
នៃព្រះឥសី មាតាបិតា ។

៩. សោណៈជាបង ប៉ងដាក់ក្នុងចិត្ត
ទៅទីឆ្ងាយជិត សម្លឹងបរិហារ
រកផ្លែ មើមឈើ ទុំល្អពិសា

មានរសស្រស់ថ្លាថ្លឹងថ្លៃមិនបាន ។
១០. តែនន្ទជាប្អូន ខ្លួនចង់បានបុណ្យ
តែមិនមានគុណវិសេសហោះធ្យាន
ក៏រកផ្លែឈើនៅទីក្បែរស្ថាន
រសនោះមិនបានផ្អែមពិសាឡើយ ។
១១. បងប្រុសដឹងក្តី បានស្តីបន្ទោស
ថានែ៎ប្អូនប្រុស កុំធ្វើច្នោះឡើយ
ចាំបងបេះយកផ្លែទុំល្អហើយ
រៀបចំបង្អើយជូនលោកពិសា ។
១២. តែនន្ទមិនស្តាប់ច្បាប់បងបរិយាយ
សម្ងំរៀងអាយលៃបេះផលា
មិនទាន់ទុំល្អជូនលោកពិសា
សម្បុរកាយាប្រែប្រុងស្រអាប់ ។
១៣. សោណៈមិនអាចនឹងហាមឃាត់បាន
ក៏បានបណ្តេញនន្ទចេញយ៉ាងឆាប់
នន្ទភ័យញ័រកាយមិនអាចសាសព្វ
គេចចេញប្រញាប់ចូលក្នុងបន្ទប់ ។
១៤. បានចម្រើនឈានមានគុណសង្វេគ

ចិត្តឈប់អល់អែកប្លែកបានក្តីស្ងប់
សម្រេចនូវឈានលោកិយគ្រប់សព្វ
ក៏គិតបញ្ឈប់ឈប់ប្រព្រឹត្តខុស ។
១៥. តែមិនហ៊ានទៅសុំខមាទោស
បងប្រុសសន្តោសឲ្យអត់កំហុស
ក៏ទៅកៀរគររកអ្នកចំណុះ
ស្តេច ១០១ ស្មោះ ចុះមកជាគ្នា ។
១៦. ស្តេច ១០១ ព្រមទាំងបរិវារ
ច្រើនក្រៃរាប់ណាឥតបើគណនា
ចូលមកបង្គំសុំខមាលា
ទោសដែលនន្ទាបណ្ឌិតគិតខុស ។
១៧. សោណបណ្ឌិតពិតប្រាជ្ញឧត្តម
ទទួលតាមសុំពុំប្រកាន់ខុស
តែបានទូន្មានតាមធម៌ឥតខ្ចោះ
ឲ្យនន្ទស្ម័គ្រស្មោះបម្រើអ្នកមេ ។
១៨. ដែលគាត់មានគុណពន់ពិតបរិយាយ
នាមាភិធេយ្យ ក្រៃលែងលើសគេ
បណ្ឌិតគួរដឹងគុណកុំគ្នាន់គ្នេរ

គួរគិតរិះរៀបរាប់រីករាយ ។
១៩. មាតាលោកឲ្យនាមយ៉ាងពីរោះ
សុហទា ឈ្មោះថា មានហឫទ័យ
ល្អបរិសុទ្ធលើសអ្នកដទៃ
គ្មានមកនិយាយថាល្អដូចម៉ែ ។
២០. ព្រោះម៉ែមានចិត្តគិតល្អប្រពៃ
លើកូនប្រុសស្រីតាំងពីមកខែ
ចង់បានបុត្រថ្លៃ រីរាល់រូបម៉ែ
រាប់ថ្ងៃរាប់ខែ រាប់ឫក្ស រាប់ផ្កាយ ។
២១. បណ្ឌិតឲ្យនាមថា ជនេត្តី
ជនយន្តី ស្រីបង្កើតកាយ
និងបោសេន្តី ស្រីស៊ូចំណាយ
ឈាមចេញពីកាយឲ្យកូនរស់រាន ។
២២. មាតាមាននាមថា បុព្វទេវា
រក្សាបុត្រភ្វា ទោះបីអត់ឃ្លាន
មើលអភិរក្សដាក់ដាមិនមាន
ប្រហែសធ្វេសញ្ញាណដល់ម្តងសោះឡើយ ។
២៣. មាននាមមួយទៀតថា បុព្វាចារ្យ

បង្រៀនកូនង៉ា ឲ្យបានល្ហែល្ហើយ
បាននូវចំណេះចេះដឹងកោះត្រើយ
មុនប្រគល់ឲ្យចូលទៅសាលា ។
២៥. មួយទៀតមាននាមថា ព្រះព្រហ្ម
បង្កើតការពារធ្វើបរិហារ
ចុងក្រោយឲ្យនាម អាហុនេយ្យា
គួរដល់សក្ការគួរកូនគោរព ។
២៦. បូជាដោយទេយ្យវត្ថុទាំងឡាយ
កូនអាចក្រាបថ្វាយបង្គំដៃដប់
ក្រៃលែងដោយបុណ្យកូននឹងប្រសព្វ
លើសលុបជាងទេពព្រហ្មមារទៅទៀត ។
២៧. ប៉ុណ្ណោះជាដើម សោណផ្ដើមបរិយាយ
បរិស័ទរីករាយ វែងរួចចង្អៀត
មិនមានតឹងចិត្ត នន្ទគិតរវាត
ទើបទ្រង់សរជាតិប្រាប់ដល់បរិស័ទ ។
២៨. ថា នន្ទបណ្ឌិតពិតគឺអានន្ទ
រីឯព្រះសោណបណ្ឌិតល្អក្អាត់
ដែលជាតួអង្គបរមពោធិសត្វ

អណ្ដែតរសាត់មកជាព្រះអង្គ ។
២៩. អរហំ សម្មាសម្ពុទ្ធ លើលោក
ព្រះដ៏មានជោគ ជិនស្រីផ្លូវផង់
រំដោះសត្វលោកឲ្យរួចផុតផង់
មន្ទិលរហង់ក្នុងសន្ដានសត្វ ។
៣០. ណ្ហើយ ! ខ្ញុំបរិយាយអធិប្បាយបន្ថែម
កាព្យដូចបង្អែមថែមថមថ្នមចាត់
ចារចែងប៉ុណ្ណោះ ស្លេះដោយបរមត្ថ
ថា ចប់គ្រប់ម៉ាត់ អស់អាចំសេចក្ដី ។
៣១. អង្គារ ១៤ រោច ខែទីមួយ
អាសាឡ្ហ មុនក្រោយ មមែសិរី
២៥៥៩ ស្ដី
ចប់ដោយអត្ថន័យខ្លីប៉ុណ្ណោះឯង ៕

ភិក្ខុធម្មសិរី អនុបណ្ឌិត ទស្សនវិជ្ជាព្រះពុទ្ធសាសនា

# គុណពុកម៉ែ

១. អហំវីខ្ញុំ លើកហត្ថបង្គំ ប្រណម្យវន្ទា
កូនសូមបរិយាយ រាយរាប់ពណ៌នា គុណធ្ងន់មហិមា
នៃលោកទាំងពីរ ។
២. ម៉ែឪមានគុណ គុណសែនមហាធ្ងន់ ធ្ងន់លើសប្រឹថពី
ធំជាងសមុទ្រ ធ្ងន់ជាងគិរី គុណលោកទាំងពីរ
គ្មានអ្វីប្រៀបទេ ។
៣. តាំងពីកកើត កូនចាប់កំណើត ក្នុងផ្ទៃអ្នកមេ
អ្នកម្ដាយថ្នាក់ថ្នម ឥតមានគ្នាន់គ្នេរ ខិតខំរិះរេ
រក្សាបុត្រថ្លៃ ។
៤. លុះកូនកើតហើយ ម្ដាយមិនកន្តើយ ខំប្រឹងលកលៃ
ចិញ្ចឹមបីបាច់ បញ្ចុកចំណី ដល់កូនប្រុសស្រី
ដោយក្ដីមេត្តា ។
៥. រីឯពុកវិញ ក៏មិនទោម្នេញ ចរចេញធ្វើការ
ខំប្រឹងរកប្រាក់ ផ្គត់ផ្គង់គ្រួសារ ទោះហត់យ៉ាងណា
ក៏ឥតរួញរា ។
៦. ពុកម៉ែថ្នាក់ថ្នម តែងតែបីបម សន្ដោសកូនភ្ងា
អប់រំទូន្មាន ឲ្យរៀនវិទ្យា លើកស្ទួយបុត្រភ្ងា

ក្លាយជាមនុស្សល្អ ។
៧. ពេលកូនមានទុក្ខ ម៉ែមិនស្រណុក ពុកមិនត្រេកអរ
ហ៊ានប្ដូរជីវិត ដោយចិត្តស្មោះសរ ដើម្បីកូនល្អ
ស៊ូលះមិនស្ដាយ ។
៨. កូនសូមបង្គំ លើកហត្ថប្រណម្យ បន្ទន់ទាំងកាយ
សំពះបាទា លោកពុកអ្នកម្ដាយ កូនដាក់មិនណាយ
ភ្លេចគុណអ្នកឡើយ ៕

# ទឹកចិត្តម្ដាយ

បទពាក្យ ៩ បែបផ្កាឈូករីក

១. ទឹកចិត្តម្ដាយ តែងខ្វល់ខ្វាយ សាយមេត្តា
ទឹកចិត្តម្ដាយ តែងករុណា កូនប្រុសស្រី
ទឹកចិត្តម្ដាយ តែងសន្ដោស ប្រោសប្រណី
ទឹកចិត្តម្ដាយ តែងអភ័យ កូនគ្រប់គ្រា ។
២. ទឹកចិត្តម្ដាយ ស៊ូលំបាក ដើម្បីកូន
ទឹកចិត្តម្ដាយ ស៊ូក្រាបលូន ព្រោះបុត្រា
ទឹកចិត្តម្ដាយ ស៊ូស្លាប់កាយ មិនរួញរា
ទឹកចិត្តម្ដាយ ស៊ូវេទនា ឲ្យកូនល្អ ។
៣. ទឹកចិត្តម្ដាយ ពោរពេញដោយ ក្ដីមេត្តា

ទឹកចិត្តម្ដាយ　តែងករុណា　ដោយស្មោះសរ
ទឹកចិត្តម្ដាយ　បានសប្បាយ　ឃើញកូនល្អ
ទឹកចិត្តម្ដាយ　សែនបវរ　ល្អគ្មានពីរ ។

៤.　អរគុណម៉ែ　បីបាច់ថៃ　រក្សាកូន
អរគុណម៉ែ　ដែលថៃថ្នួន　ផ្ដល់ជីវី
អរគុណម៉ែ　ដែលថ្នមថៃ　ថៃមពលី
អរគុណម៉ែ　ដូចធរណី　ទ្រូវរូបកូន ។

៥.　អរគុណម៉ែ　កូនមិនកែ　ប្រែក្រឡាស់
អរគុណម៉ែ　កូនពិតច្បាស់　គោរពគុណ
អរគុណម៉ែ　កូនក្រាបលំ- - អុតលំឱន
អរគុណម៉ែ　កូនថ្វាយលូន　លាលាងទោស៕

ថ្ងៃពុធ ៩ កើត ខែបឋមាសាឍ ឆ្នាំមមែ ព.ស.២៥៥៩
ត្រូវនឹងថ្ងៃទី ២៤ មិថុនា ២០១៥
រស្មីដួងចន្ទ

# ករម្រងកំណាព្យសន្ទនា
# ពណ៌នាពីព្រហ្មវិហារធម៌ទាំងបួន

ដោយព្រះភិក្ខុ ធម្មសិរី សែម ចន្ទធីរ៍

១. ហេតុអ្វីអាណិតនាំចិត្តទន់ជ្រាយ
ហាក់ដូចរាយមាយចិត្តមិនរឹងប៉ឹង
អង្វរបន្តិចចិត្តក៏បាត់ខឹង
បើតែយ៉ាងហ្នឹងរឹងរឹតសោកា ។

២. ពូកែអាណិតនាំចិត្តហ្មងសៅ
មេត្តាពេកទៅមានតែបញ្ហា
គិតចង់កម្ចាត់អាណិតមេត្តា
ទើបចប់បញ្ហាមិនមានអាស្រូវ ។ (ដួងចន្ទ)

៣. មេត្តាអាណិតពិតមានហេតុផល
បើគិតមិនដល់យល់មិនបានត្រូវ
កម្ចាត់មេត្តាពិតជាអាស្រូវ
មេត្តានាំផ្លូវទៅរកក្ដីល្អ ។

៤. អាហ្នឹងមិនមែនតួមេត្តាចំ
អាណិតលាយឡំផ្សំទន់ទោររក៏

អាណិតឲ្យមានសន្ដានចិត្តធម៌
កុំល្អក់កករនឹងទន់ជ្រាយឡើយ ។
៥. តួមេត្តាតែងតែមិនតឹងត្អឹង
មេត្តាមិនខឹងមិនគុំកួនឡើយ
មេត្តាអាណិតគិតសង្គ្រោះឲ្យ
គេបានសុខហើយមិនជាប់ជំពាក់ ។
៦. ករុណាអាសូរប្ដូរសុខនិងទុក្ខ
ឃើញសត្វនឹងមុខទុក្ខទួលអួលអាក់
ករុណាអាណិតមិនគិតមិត្តភក្ដិ
ជួយមិនជំពាក់រាក់ទាក់រកគុណ ។
៧. មុទិតាទន់ភ្លន់គន់មើលសម្លស្ស
ពួកសត្វបានរស់ដោយសុខពេកពន់
ចិត្តមិនច្រណែនមិនរមិលគុណ
សប្បាយជួយបន់ឲ្យសាធុការ ។ (ចន្ទធីរ៍)
៨. អារម្មណ៍សោកសៅពៅលេងសុទ្ធកាព្យ
ចារចែងកំណាព្យខាបចិត្តសោកា
បងគ្មានអារម្មណ៍តបតទេណា
ចិត្តមិនស្រស់ថ្លាហាក់សុញគំនិត ។

៩.	រឿងរ៉ាវខ្វាយខ្វល់រកកលឈឺក្បាល
ហាក់ដូចហែលហាលធុញថប់ក្នុងចិត្ត
គិតចង់បើកទ្បានចេញដើរបន្តិច
ឬមួយបើកគេចឲ្យផុតលោកា ? (ដួងចន្ទ)
១០.	មិនឲ្យតបទេឲ្យត្រឹមតែស្តាប់
ធម៌ប្អូនប្អូនប្រាប់ឲ្យបានច្បាស់ក្លា
មិនឲ្យប្រទូ្បំតួធម៌មេត្តា
ធម៌ករុណា មុទិតាផង ។
១១.	នៅធម៌មួយទៀតនាមឧបេក្ខា
មានចិត្តចាស់ក្លាមិនទន់ជ្រាយម្តង
យល់ធម្មៈពិតគិតហេតុផលផង
ព្រមតាមគន្លងនៃហេតុបច្ច័យ ។
១២.	ដើរដល់ទីណាក៏មិនបានថ្វី
តែបើបងស្រីចាប់ដងប៉ាកា
សរសេររៀបរាប់រឿងក្នុងចិន្តា
រ៉ាយរ៉ាប់សព្វសាប្អូនថាល្អជាង ។
១៣.	ឬមួយទាញយកសៀវភៅមកអាន
កំណត់អំណានលំអានឥតស្ទៀង

សញ្ចប់វោហារកវីសំនៀង
សញ្ចប់តាមទៀងសៀងសំនួននៅ ។
១៤. ពាក្យពេចន៍កវីពោលស្ដីប្រដៅ
ពោរពេញដោយនូវអត្ថន័យសែនជ្រៅ
ក្រេបយករសពាក្យពីក្នុងសៀវភៅ
គ្រាន់ជាងដើរទៅទាំងមិនមានខ្លួន ។
១៥. តើបងយល់ទេពាក្យថាគ្មានខ្លួន ?
ឬមួយមាសសួនមិនជូនដំណឹង
អាចសួរតបបានប្អូនមិនដែលខឹង
បើបានបងខឹងប្អូននឹងមិនអី ។
១៦. កុំដើរផ្ដេសផ្ដាស កាលណាយើងខឹង
មិនត្រូវទៅនឹងទំនៀមយើងអ្វី
សក្កៈពោលថា កាលគាត់ខឹងអី
គាត់នឹងមិនស្ដីនិយាយអ្វីឡើយ ។
១៧. មិននឹងធ្វើការណាអ្វីទាំងអស់
ត្រូវនឹកសន្ដោសដល់ក្ដីល្ហែល្ហើយ
ខន្តីអត់ធន់យើងមានយូរហើយ
ចូរកុំបណ្ដោយឲ្យខឹងដឹងកល ។ (ចន្ទធីរ៍)

១៨.　មិនហាមិនស្តីស្រីប្រេះទ្រូងស្លាប់
ពិតជាចុកចាប់ស្លាប់ព្រោះកង្វល់
គិតចុះគិតឡើងកាន់តែវិលវល់
កើតក្តីអំពល់ខ្វល់ខ្វាយគុណាទ្វេ ។

១៩.　ឲ្យនៅស្ងៀមស្ងាត់បាត់មិនចេញស្តី
ថែមមិនធ្វើអ្វីស្រីរឹតគ្នាន់គ្នេរ
ត្រូវរកអ្វីធ្វើកុំឲ្យទំនេរ
ទើបមិនគ្នាន់គ្នេររេរេកកង្វល់ ។ ( ដួងចន្ទ )

២០.　ចឹងបានឲ្យចាប់ប៉ាកាសរសេរ
រៀបរាប់សំណេរសរសេរកង្វល់
កុំទុកក្នុងចិត្ត ដ្បិតរឹតសោកសល
សរសេរតម្កល់ផលល្អថ្ងៃក្រោយ ៕

១៨ មិនា ១៥

# កម្មវិធីកូនប្រុសស្រី

១. សូមលើកហត្ថាក្រាបថ្វាយបង្គំ
អ្នកម្ដាយភិរម្យជាទីជ្រះថ្លា
ធ្លាប់បីថ្នាក់ថ្នមថៃទាំរក្សា
ដោយចិត្តមេត្តាមិនដែលសៅហ្មង
កាលនៅពីតូចមិនទាន់ដឹងក្ដី
បញ្ចុកចំណីបំបៅដោះផង
ផ្ងូតទឹកដុសលាងសម្អាតច្រើនដង
លើកឡើងត្រកងដាក់លើកម្រាល
ពេលគេងអ្នកម្ដាយនៅជិតអាត្មា
មិនហ៊ានទៅណាឃ្លាតឆ្ងាយខុសកាល
សម្ងំស្ងៀមស្ងាត់មើលអភិបាល
ធ្វើការស្រាលៗខ្លាចភ្ញាក់ពិសី ។

២. ក្រាបថ្វាយបង្គំ

៣. សូធ្យបទស្រណោះព្រលឹងម៉ែអាសូរចិត្តម្ដាយ

៤. ភ្នំព្រះសុមេរុគឺជាមេភ្នំ
ធំក្រៃលែងធំទ្រៃត្រៃត្រិង្សឋាន

តែគង់នៅតូចជាងម៉ែកល្យាណ
ព្រោះម៉ែទ្រឋានព្រះព្រហ្មមុខបួន
ម៉ែពិតជាធំនៅក្នុងលោកា
មេទ័ពខ្លាំងក្លាសំពះម៉ែខ្លួន
ទោះស្ដេចចក្រពត្តិគ្រងទ្វីបទាំងបួន
អំណាចមាំមួនតែនៅខ្លាចម៉ែ ។
ពាក្យមេក្នុងលោកមានច្រើនពេកក្រៃ
មេជើងមេដៃមេស្រុកមេស្រែ
ពាក្យមេទាំងនោះប្រដូចនឹងម៉ែ
ពាក្យមេហូរហែគឺម៉ែទាំងអស់ ។
ព្រោះម៉ែជាធំម៉ែអ្នកបង្កើត
ម៉ែឲ្យកំណើតម៉ែឲ្យបៅដោះ
ម៉ែបង្ហាត់កូនម៉ែមានចិត្តស្មោះ
ម៉ែគឺជាកោះនៃជីវិតកូន ។

៥. ជូនទេយ្យវត្ថុដល់ម្ដាយ

៦. សូធ្យបទសុំខមាទោស

៧. អ្វីៗក្នុងលោកកើតព្រោះហេតុ
ឃើញច្បាស់ក្រឡេតគុណម៉ែឪ

កូនរស់ធំឡើងត្រូវរកផ្លូវ
សងគុណម៉ែឪទើបត្រូវច្បាប់ ។

៨. ម្តាយឪពុកជូនពរសព្វសាធុការ

៩. ហៃ!អស់កូនម៉ែប្រុសស្រីទាំងឡាយ
ចូរកូនស្តាប់ម្តាយណាកូនមាសស្ងួន
ឥឡូវធំហើយត្រូវថែខ្លួន
កុំខឹងរត់ពួនដូចនៅកុមារ ។
កាលកូននៅតូចកូនខឹងអាងយំ
ពេលនេះកូនធំកុំប្រើហឹង្សា
ដ្បិតមនុស្សសព្វថ្ងៃច្រើនខ្វះមេត្តា
កូននៅទីណាប្រយ័ត្នសំដី ។

១០.ម្តាយឪពុកប្រោះព្រំទឹកសុគន្ធវារី
ដោយមានព្រះសង្ឃស្វាធ្យាយ **ជយន្តោ** ផង!

ចប់

***អត្ថបទពំនោលរបស់លោកគ្រូ អគ្គបណ្ឌិត ប.ស.វ.***

*រៀបចំកម្មវិធីដោយភិក្ខុ ធម្មសិរី អនុបណ្ឌិត*

# ស្រណោះព្រលឹងម៉ែអាសូរចិត្តម្ដាយ

កាលវ័យទារក ម៉ែថ្នមម៉ែបក់ មិនឲ្យមានឆ្គង
អង្អែលស្រវ៉ា ហត្ថាទាំងសង ធ្វើជាបង្គង
ទ្រនំជីវិត ។

ពេលម៉ែមានទុក្ខ បណ្ដាញស្មាញស្មុគ ថ្លុកភពងងឹត
បានយល់ភ័ក្រ្តា បុត្រភ្វាពិសិដ្ឋ ម្ដាយសប្បាយចិត្ត
ផុតទុក្ខមួយគ្រា ។

រីមួត្រលាមក គម្រើលក្អួតឈ្លក់ ក្រខ្វក់ម្ដេចម្ដា
ម៉ែគ្មានខ្ពើមស្អប់ ឥតថប់ចិន្ដា វិស័យដូចផ្កា
ពិដោរធម្មជាតិ ។

ពេលមានរោគា ឈឺថ្កាត់នានា ម៉ែមិនចង់ឃ្លាត
ទ្រូងម្ដាយខ្លោចផ្សា ឱរ៉ាចង្អៀត បែបន់អភិវាទ
ឲ្យតែកូនជា ។

គ្រាកុមារវ័យ ចិត្តម្ដាយរំពៃ ឲ្យកូនសិក្សា
រៀនលេខអក្ខរៈ សិល្បៈវិទ្យា រៀបចំវាសនា
អនាគតរុងរឿង ។

ទោះក្រយ៉ាងណា ធ្វើស្រែចំការ កាយស្រូវចំបើង
យកប្រាក់ឲ្យរៀន ឲ្យប្រសើរឡើង ឲ្យបានកូនថ្កើង

ស្មើមុខនឹងគេ ។
ពេលវ័យបឋម កំលោះក្រមុំ ពេញដូចដួងខែ
ចិត្តម្តាយស្រទន់ គយគន់គ្នាន់គ្នេរ ចិត្តកួចលួចស្នេហ៍
សម្ពស្សសោភ័ណ ។
ពេលកូនប្រុសស្រី មានប្រពន្ធប្តី ចិត្តម្តាយគ្នេរគ្នាន់
ចង់ឲ្យបានសុខ ស៊ីចុកគ្រប់គ្រាន់ កុំបីរិះគន់
ឈ្លោះទាស់ទែងគ្នា ។
កូនសុខសប្បាយ ស្រុះស្រួលស្រស់ស្រាយ
ម៉ែសប្បាយចិន្តា ត្រង់ម្តាយអត់ឃ្លាន
ម្តាយគ្មានទាមទារ ឱះ!ឱ! អនិច្ចា
អាសូរម្តាយខ្ញុំ ៕
*ស្រង់ចេញពីសៀវភៅកំណាព្យលោកតា ធឹង កាន*

# បទសុំខមាទោសមាតាបិតា

បពិត្រលោកអ្នកមាតាបិតា
កូននឹកខ្លោចផ្សាពេកអម្បាយ
តាំងពីកូនកើតមានរូបកាយ
អ្នកតែងខ្វល់ខ្វាយថែរក្សា ។
ឱះឱ! ម្ចាស់ថ្លៃវិសេសលន់
អ្នករងទុក្ខធ្ងន់ពន់ពេកណា
អ្នកខំបីបាច់កូនស្ងួនភ្ងា
ឥតបីគណនាឲ្យអស់បាន ។
ពេលនេះកូនសូមផ្គងអញ្ជលី
លើកហត្ថទាំងពីរបន្ទន់ប្រាណ
បង្គំបាទាព្រះក្សេមក្សាន្ត
ទោសខុសប៉ុន្មានសូមប្រណី ។
ម្ចាស់អើយកាលកូនទ្រហោយំ
អ្នកស្ទុះមកថ្នមត្រកងបី
ច្រៀងបំពេកូនដោយប្រិមប្រិយ
ដោយចិត្តភក្ដីផ្ដេកកូនណា ។

ទឹកមូត្រទឹកមាត់លាមកផង
ទាំងគ្រឿងសៅហ្មងផងនានា
អ្នកចាប់អ្នកកាន់អ្នកស្រវា
លាងដោយហត្ថាឥតដិនធ្អន់ ។
បពិត្រ អ្នកម្ដាយមានករុណា
បិតាមានគុណវិសេសលន់
កូនសូមគោរពព្រះគុណធ្ងន់
សូមព្រះសោភ័ណបានក្សេមក្សាន្ត ។
ហេតុនេះ កូនសូមឧទ្ទិសផល
តំកល់ចេតនាដោយក្លាហាន
ទានសីលភាវនាដែលកូនបាន
សាងធ្វើប៉ុន្មានជូនទៅអ្នក ។
សូមលោកទទួលដោយសោមនស្ស
ចិត្តកូនត្រង់ស្មោះចំពោះដាក់
ដូចកូនបានពោលពាក្យសច្ចៈ
សូមជូនទៅអ្នកគ្រានេះហោង ៕
*សូមអភ័យទោសផង ដែលមិនស្គាល់នាមអ្នកនិពន្ធ*

# កម្មវិធីស្រោចស្រពសុគន្ធវារី

១. ករិយាថ្វាយបង្គំលោកទាំងពីរ

២. ករិយាពណ៌នាគុណស្វាមី

៣. ស្វាមីវិយោគ

៤. សុំខមាទោស

៥. ជូនទេយ្យវត្ថុ

៦. ស្វាមីឲ្យពរជ័យ

៦. ព្រះសង្ឃ និងញាតិមិត្ត ស្រោចស្រពសុគន្ធវារី និងជយន្តោ

**កម្មវិធីបុណ្យចម្រើនព្រះជន្មជូនស្វាមី នៅវត្ត ធិតាពុទ្ធិការាម រដ្ឋអារីហ្សូណា សហរដ្ឋអាមេរិច**

ដោយភិក្ខុ ធម្មសិរី អនុបណ្ឌិតទស្សនវិជ្ជាព្រះពុទ្ធសាសនា

# ភរិយាពណ៌នាគុណរបស់ស្វាមី

១. នាងខ្ញុំសូមលើកហត្ថប្រណម្យ
ខ្ពស់ផុតក្បាលខ្ញុំឱនសិរសី
សំពះបាទាព្រះស្វាមី
ជាម្ចាស់ចិត្តស្រីថ្លៃប្រសើរ ។

២. ម្ចាស់ថ្លៃថ្លើមចិត្តជីវិតស្ងួន
ចាប់តាំងពីនួននាងបម្រើ
ចេញចាកត្រកូលចោលជណ្តើរ
ផ្ទះស្រីហើយហើរហោះតាមប្តី ។

៣. អ្នកប្រៀបបីដូចជាមាតា
ដូចជាបិតាការរូបស្រី
រាំងរាឧបសគ្គស្ម័គ្រយប់ថ្ងៃ
មិនឲ្យពិសីនាងស្រពោន ។

៤. រូបប្តីតែងជួយរាល់កិច្ចការ
មានទុក្ខក្តីណាការពារស្ងួន
អូនស្រីនឹកម្តាយប្តីរ៉ាប់ខ្លួន
បំពេអង្រួនអូនឲ្យស្បើយ ។

៥. បើស្រីមិនយល់រាល់ការងារ
ប្រុសបងជានាជួយបង្ហើយ
មិនមើលបំណាំស្រីសោះឡើយ
ឱះឱ! គ្រាណាត្រើយនេះហើយគុណ ។

៦. គ្រាកាលស្រីខ្វល់អំពល់ចិត្ត
ប្រុសបងអាណិតគិតគយគន់
កំប្លែងចាក់ត្លុករកទីកមន្ត
សម្តីទន់ភ្លន់បន្ទន់ចិត្ត ។

៧.	ថាបើពេលស្រីអូនត្រូវការ
ចង់បានអ្វីណាប្រុសវរមិត្រ
ស្វែងរកមកប្រគល់មិនគិត
នឿយហត់ល្វែល្វិតស្វិតក្រៀមទេ ។

៨.	ឱះឱ! ស្វាមីថ្លៃអូនអើយ
គុណប្រុសត្រាណត្រើយច្រើនម្ល៉េះទេ
អូនរាប់មិនអស់ទេមាសស្នេហ៍
គុណធំជាងគេគឺស្នេហ៍ស្មោះ ។

៩.	ឲ្យតម្លៃអូនស្ងួនពិសី
ថ្កើងជាស្ត្រីប្ដីសន្តោស
មិនទៅចោលស្រីម្ដងណាសោះ
ប្រុសបងជាប្រុសស្មោះមេត្រី ។

១០. ហេតុនេះជាដើមអូនសូមក្រាប
ស្រីឱនឲ្យទាបបាទាថ្ងៃ
បង្គំនឹកគុណាប្រុសចរណៃ
ដែលផ្តល់កក្តីដល់ស្រីង៉ា ។

១១. សូមថ្ងៃទទួលការគោរព
បង្គំម្រាមដប់គ្រានេះណា
ដូចស្រីបានពោលគ្រប់វាចា
សូមព្រះភស្តាបានថ្កើងថ្កាន ៕

## ស្វាមីវិយោគតប

១. ឱះឱ! នាងស្រីថ្ងៃបរិសុទ្ធ
រៀមសែនរន្ធត់ចិត្តពេកក្រៃ
បងស្ទើរតែទប់មិនបានណាថ្ងៃ
ព្រោះតែចរណៃនាងពណ៌នា ។

២.　បងសូមអរគុណពន់អនេក
កុំបីទឹកភ្នែកណាពុំងា
រៀមក៏បានថ្ងៃមកជាគ្នា
ធ្វើការនាវាជីវិតណា ។

៣.　យើងអាស្រ័យគ្នាធ្វើលំបាក
លំបិនតោកយ៉ាកចិត្តកាយា
បានស្រីនៅក្បែរជួយអាសា
រាល់ទុក្ខណាៗរសាយបាត់ ។

៤.　សូមស្រីប្រសព្វតែក្ដីសុខ
កុំឲ្យមានទុក្ខក្ដីវិបត្តិ
រៀមត្រូវការនាងក្រៃពេកក្លាត់
មិនអាចផ្ដាច់កាត់ព្រាត់បានទេ ។

៥.		សូមស្រីកុំភ័យភិត
បណ្ដូលចិត្តកុំគ្នាន់គ្នេរ
គ្មានអ្នកណាប្រៀបទេ
មានតែស្នេហ៍រៀមតែមួយ		៕

# ភរិយាខមាទោសស្វាមី

១.	បពិត្រព្រះស្វាមី	ខ្ញុំជាស្រី ខ្ចីគំនិត
បើមានជាគ្គង់ចិត្ត សូមវរមិត្របង់ប្រណី ។
ខ្ញុំសូមបង្គំកាយ	ឱនក្រាបថ្វាយព្រះស្វាមី
បើមានកំហុសអ្វី ដោយទ្វារបីណានីមួយ ។
ទ្វារកាយក្រហាយចិត្ត វាចាពិតឲ្យប្រុសព្រួយ
ទោះបីទោសតូចមួយ សូមឲ្យហើយណាម្ចាស់ថ្លៃ។
កុំបីមានបើខឹង	ពីថ្ងៃហ្នឹងណាចរណៃ
ស្រីនឹងខំកែខៃ	មិនឲ្យថ្លៃខុសចិត្តឡើយ ។

ស្រីសូមតាមបម្រើ   មើលដំណើរថ្ងៃត្រាណត្រើយ
មានតែម្ចាស់ប្ដីហើយ   ជួយបានស្បើយពីសោកា
ឥឡូវគ្រានេះឯង   ស្រីបានបែងចាត់កិច្ចការ
ធ្វើបុណ្យជូនភស្ដា   សូមប្រាថ្នាជួបអ្នកទៀត។
នាងខ្ញុំបាននិមន្ត   ព្រះតេជគុណនិងពួកញាតិ
ទាំងលែខំខ្មីឃ្មាត   ស្រីខំធ្វៀតតាមធ្វើបាន
មានជូនញាតិពិសា   ភោជនាហារយ៉ាងចំណាន
រួចរៀបចំខ្លួនប្រាណ   ចិត្តនឹកប្ញាន នមស្សការ
សមាទាននិច្ចសីល   កាត់មន្ទិលធម៌ហឺនា
និងស្ដាប់ព្រះធម្មា   លោកទេសនាសាសព្ទក្ដី
ព្រមទាំងមានទេយ្យទាន ជូនអ្នកមានគុណលើស្រី
ធ្វើបុណ្យពូនបារមី   ខ្ញុំនិងប្ដី ធ្វងផុតទុក្ខ
នៅក្នុងសង្សារវដ្ដ   សូមកុំបត់បែកចាកសុខ

សូមជួបរាល់ជាតិមុខ ស្រីចាំទុក តទៀងទៅ ។
ណ្ហើយស្រីសូមខមា ទោសនោះណាតូចពេកកូវ
កុំឲ្យមានសល់នៅ សូមឆោមឆ្មៅ បងប្រណី
ស្រីប្ដេជ្ញាសង្រួម ឈប់ឲ្យជួនជួបទៀតអី
ចិត្តបាបទោះតិចក្ដី លើស្វាមីឈប់គិតហើយ ៕

## ស្វាមីអត់ទោសឲ្យ

១. ឱះឱ! ភរិយាថ្លៃបវរ
រៀមសែនត្រេកអរ ពេកពន្លឹក
ស្មើរតែផងផឹតមុខព្រោះភ្ញឹក
ដោយសូរសន្ទឹកនឹកដល់ស្រី ។

២. នាងរៀបពិធីការ
ឲ្យភស្ដាបានសិរី
ច្រើនផងយសមិនតិចអី

ញាតិប្រុសស្រី នៅត្រៀបត្រា ។

៣. បងសូមអរគុណនាង

សូមកុំឃ្លាងគ្នាឡើយណា

សូមអស់ពួកទេវតា

សាធុការ ដល់នាងផង ។

៤. ម្យ៉ាងបើបងមានខុស

ទោសកំហុស មិនទំនង

សូមស្រីអត់ទោសផង

កុំគុំចងទុកក្នុងចិត្ត ។

៥. សូមស្រីប្រពៃសុខ

ស្រួលស្រណុក កុំរិបរិត

សូមនៅជាប់ក្នុងចិត្ត

ប្ដីអាណិត ស្រឡាញ់ណាស់ ។

៦. មេឃាជាសាក្សី
ធរណីដី ភ្នំធំក្រាស់
ចូរអ្នកចាំឲ្យច្បាស់
មិនក្រឡាស់ ផ្លាស់ចិន្តា ។

៧. សូមជួបគ្នាគ្រប់ជាតិ
ជរាបឃ្លាតចាកសង្សារ
ចូលកាន់និព្វានណា
អស់តណ្ហា រលត់ទុក្ខ ។

៨. ថ្ងៃសៅរ៍សុខសិរី
៦ កើតជ័យ ខែជេស្ឋមុខ
រីករាយសប្បាយជោគ
រួចចាករោគ រាគរៀងទៅ ។

ថ្ងៃសៅរ៍ ២៣ ឧសភា ២៥៥៩/ ២០១៥

# នាមសប្បុរសជនចូលរួមបោះពុម្ព
## សាមីដើមបុណ្យ

| | | |
|---|---|---|
| ១. | ឧបាសក ជា សុថារី | ២០០ $ |
| ២. | ឧបាសិកា គឹម លីម | ២០០ $ |
| ៣. | ជា សុដាលីណា និងស្វាមី ព្រមទាំងបុត្រ | ១០០ $ |
| ៤. | ជា សុដាលីណែត និងស្វាមីព្រមទាំងបុត្រ | ២០០ $ |
| ៥. | ជា សុថារិទ្ធ និងភរិយា ព្រមទាំងបុត្រ | ១០០ $ |
| ៦. | លោកស្រី គិត ស៊ីមន | ១០០ $ |
| ៧. | លោក អ៊ុច អមរ៉ា | ២០០ $ |
| ៨. | ឧបាសិកា ជា សុដាលីន | ៣០០ $ |
| ៩. | កូនស្រី អ៊ុច សាន់ត្រាវី | ៥០ $ |
| ១០. | កូនស្រី អ៊ុច ដារីយ៉ែន | ៥០ $ |
| ១១. | កូនស្រី អ៊ុច វិដ្ឋរ៉ា | ៥០ $ |
| ១២. | ប្អូនស្រី សំអូន ផាត់និងគ្រួសារ | ១០០ អឺរ៉ូ |
| ១៣. | ប្អូនស្រី ឱណា ស្រី និងក្រុមគ្រួសារ | ៩០ អឺរ៉ូ |
| ១៤. | ឧបាសិកា ម៉ម នរម និងស្វាមី | ៥០ អឺរ៉ូ |
| ១៥. | ប្អូនស្រី ផារី ហាំ ព្រមទាំងគ្រួសារ | ៤០ អឺរ៉ូ |
| ១៦. | លោក អាន លី និងភរិយា | ២០ អឺរ៉ូ |

## ពុទ្ធបរិស័ទនៅសហរដ្ឋអាមេរិច

១៧. ព្រះគ្រូ វិនយធរោ មហា ឃិន នឿន CA ១០០ $

១៨. ព្រះធម្មាចារ្យ ឱវាទរក្ខិតោ ហោ គឹមសាន ១០០ $

១៩. ព្រះមហា វិមលពុទ្ធិ ទី ប៊ុនថា PA ១០០ $

២០. ព្រះធម្មាចារ្យ អគ្គទិន្នោ នូវ បូរា IR ៥០ $

២១. ព្រះមហា ធម្មសិរី សែម ចន្ទធីរ៍ AZ ១០០ $

២២.ព្រះមហា រតនសោភនោ ជិន ចាន់ធន AZ ៥០ $

២៣.ឧបាសិកា នូ សុខា &ស្វាមី អាវ ស្រ៊ុន AR ២៥០ $

២៤. ឧបាសិកា ឃួន ខាំង CA ៥០ $

២៥. លោកអាចារ្យ រីក វ៉ាតសាយ ៤០ $

២៦. ឧបាសិកា ត្រា ស្រឿង ៤០ $

២៧. លោក ហាន ហឿន & ផុន សុភ័ក្រ និងបុត្រ ៣០ $

២៨. លោក ឥន អាន និងអ្នកស្រី ស្មៃ ណាំ ២៥ $

២៩. អរិយ៉ា សុន, ជូដេត សូ និង រ៉ូឡិច ២០ $

៣០. គ្រួសារ ប៉ា ដេន្នី ២០ $

៣១. ឧបាសិកា វួន មួយហៀង ១៥ $

មាតាបិតា គឺពិតជាព្រះ

ប្រាកដណាស់ ច្បាស់សង្គ្រោះបុត្តធីតា

បណ្ឌិតឲ្យនាមជាបុញ្វាចារ្យ
អាហុនេយ្យា ថា ព្រហ្មផង ។

ជាទេវតាដើមអ្នកផ្តល់កំណើត
គំនិតល្អផើតបង្កើតចម្លង

បីបមថ្នមថ្នាក់អភិរក្សហ្មត់ហ្មង

មោះមិនមួហ្មងមឹតពុតពាំពាក្យ ៕





ISBN: 978-99963-844-6-2